# សិទ្ធិអំណាចរបស់អ្នកជឿ



លោក**ដុកទ័រ អេ.អែល ហ្គីល** គឺជាកំពូលអ្នកនិពន្ធសៀវភៅដែលលក់ដាច់បំផុតដែលបានបោះពុម្ពជិត ២០លានក្បាល ។ ការងារជាសាវ័កផ្នែកអន្តរជាតិរបស់គាត់នេះ គឺបានចាប់យកមនុស្សជាង៨០ជនជាតិ ។ គាត់បានអធិប្បាយទៅដល់ហ្វូងមនុស្សជាងម្ភៃម៉ឺននាក់ ដោយមានការបញ្ជាក់មកពីព្រះ និងព្រះបន្ទូលរបស់ព្រះអង្គ ជាមួយនឹងទីសម្គាល់នៃការប្រោសឱ្យជា និងការអស្ចារ្យផ្សេងៗ ។ ការអនុវត្តន៍ដែលមានពេញដោយអំណាចចេស្តារបស់គាត់ សេចក្តីបង្រៀនដែលមានពេញដោយជីវិតផ្លាស់ប្រែ និងដែលមានលទ្ធភាព នោះគឺតាមរយៈ វីឌីអូ អូឌីយ៉ូ និងសៀវភៅជាច្រើនភាសា នោះសូមមើលទៅក្នុងវិបសាយ: www.gillministries.com

*១. ការស្គាល់ខ្មាំងសត្រូវរបស់លោកអ្នក.................. ០៧៣*
*២. សិទ្ធិអំណាចនៅលើផែនដីនេះ ........................... ០៨៣*
*៣. ព្រះយេស៊ូវទ្រង់ជាគំរូរបស់យើង ....................... ០៩៧*
*៤. ពួកជំនុំ និងសិទ្ធិអំណាចរបស់វា ......................... ១០៩*
*៥. យុទ្ធសាស្ត្ររបស់សាតាំងសម័យសព្វថ្ងៃនេះ......... ១១៩*
*៦. កូនសោរសម្រាប់ចាក់នគរស្ថានសួគ៌ .................. ១២៩*
*៧. ព្រះនាមព្រះយេស៊ូវ ...................................... ១៣៧*
*៨. ជ័យជម្នះលើសង្គ្រាមខាងវិញ្ញាណ.................. ១៤១*

# សិទ្ធិអំណាចរបស់អ្នកជឿ

## *មេរៀនទី ១: ការស្គាល់ខ្មាំងសត្រូវរបស់លោកអ្នក*

### I. យើងស្ថិតនៅក្នុងសង្គ្រាម

#### ក. ការធ្វើសង្គ្រាម

យើងជាគ្រីស្ទាន គឺយើងត្រូវតែរស់នៅក្នុងសង្គ្រាមជាការពិត គឺដែលយើងត្រូវបានចូលរួមនៅក្នុងសង្គ្រាមនោះឯង ។ យុទ្ធសាស្ត្រដ៏សំខាន់មួយ បណ្តាយុទ្ធសាស្ត្រទាំងឡាយរបស់សាតាំង គឺបានត្រូវចងភ្នែកយើងជាប់ គឺវាធ្វើឱ្យយើងមានការវង្វាទចិត្តផ្សេងៗ ក្នុងការប្រឆាំងទាស់នឹងការប្រយុទ្ធប្រឆាំងរបស់វា ។ ប៉ុន្តែ ព្រះទ្រង់បានប្រទានឱ្យយើងនូវគ្រប់គ្រឿងសឹក

ដើម្បីដណ្តើមយកជ័យជម្នះលើខ្មាំងសត្រូវរបស់យើងនោះឯ!

ព្រះគម្ពីរ ២កូរិនថូស ១០:៣-៤

#### ខ. អំពីខ្មាំងសត្រូវរបស់យើង

យើងបានស្ថិតនៅក្រោមចម្បាំង ពួពួកខ្មាំងសត្រូវគឺនៅក្នុងតំបន់នៃការរស់នៅប្រចាំថ្ងៃរបស់យើង និងការប្រកបទាក់ទងរបស់យើង ដែលនៅក្នុងយើងនោះឯង: ដូចជានៅក្នុងក្រុមគ្រួសារ នៅកន្លែងធ្វើការងារ អ្នកជិតខាង រូបកាយ (ផ្នែកសុខភាព) ថវិកាជាដើម ។

ព្រះគម្ពីរ ១ធីម៉ូថេ ៦:១២

### II. តើអ្នកណាជាខ្មាំងសត្រូវរបស់យើង?

ប្រសិនបើយើងដឹងថា យើងស្ថិតនៅក្នុងចម្បាំង វាគឺជាការសំខាន់ ដើម្បីយកឈ្នះលើអ្នកណាដែលជាខ្មាំងសត្រូវ

របស់យើងនោះ ។ លោកសាវ័កប៉ុលបានពណ៌នាអំពីខ្មាំងសត្រូវរបស់យើង ដែលបានគូសវាសក្នុងការប្រឆាំងជាមួយយើងដ៏ពិតប្រាកដនោះ ។ វាបាននិយាយថា យើងមិនអាចធ្វើការបោកចំបាប់ប្រឆាំងទាស់ជាមួយនឹងសាច់ឈាមបានទេ ។

ព្រះគម្ពីរអេភេសូរ ៦:១២

យើងកំពុងតែបានធ្វើការប្រយុទ្ធប្រឆាំង នៅសមរភូមិកំហុស គឺរវាងខ្មាំងសត្រូវកំហុស ជាមួយនឹងគ្រឿងសាស្ត្រាវុធកំហុសនោះ ។ យើងត្រូវការស្គាល់នូវអ្នកណាជាខ្មាំងសត្រូវនោះឯង ។

### ក. វិញ្ញាណអាក្រក់

លោកសាវ័កពេត្រុស ក៏បានធ្វើការបញ្ជាក់ពីការនេះថា អ្នកដែលខ្មាំងសត្រូវយើងគឺជាវិញ្ញាណអាក្រក់នោះឯង ។

ព្រះគម្ពីរ ១ពេត្រុស ៥:៨

### ខ. គម្រោងផែនការ

កលល្បិចយ៉ាងប៉ិនប្រសប់របស់វិញ្ញាណ គឺជាគម្រោងផែនការ យុទ្ធសាស្ត្រ និងផែនការនៃការឆបោករបស់វានោះឯង ដែលវាប្រើប្រាស់ប្រឆាំងទាស់នឹងយើង ។ នៅពេលដែលយើងបានត្រឡប់មកជាដឹងខ្លួន ដោយសារផែនការរបស់វានោះ យើងត្រូវតែមានការដឹងខ្លួនបន្ថែមទៀត និងត្រូវតែពាក់នូវគ្រឿងសឹកដែលព្រះទ្រង់បានប្រទានឱ្យ សម្រាប់សមរភូមិរបស់យើងនោះ ។ ការពាក់គ្រឿងសឹកគឺសម្រាប់ជាគ្រឿងការពាររបស់យើង ។ គ្រឿងសឹកគឺសម្រាប់ជាជ័យជម្នះរបស់យើងក្នុងការការពារទាស់ទទឹងនឹងខ្មាំងសត្រូវរបស់យើង ។

ព្រះគម្ពីរយ៉ូហាន ៨:៣២

## III. សាតាំងប្រើប្រាស់នូវការឆបោក ការប៉ិនប្រសប់ គម្រោងផែនការ និងយុទ្ធសាស្ត្រ ។

ព្រះគម្ពីរអេភេសូរ ៦:១១

### ក. ការព្រមាន

ចូរធ្វើការកាន់កាប់ជាមួយនឹងព្រះយេស៊ូវ ចូរដឹងពីសិទ្ធិអំណាចរបស់លោកអ្នក មិនត្រូវមានការប្រកបស្និទ្ធស្នាលជាមួយនឹងវិញ្ញាណអាក្រក់ឡើយ ចូរដឹងស្គាល់នូវព្រះបន្ទូលរបស់ព្រះ ប្រសិនបើយើងចង់បានទទួលនូវជ័យជម្នះនោះ ។ យើងមិនត្រូវបានត្រឡប់មកជាការអំពល់ ឬត្រូវបានបង្ខំឱ្យចូលរួមជាមួយនឹងវិញ្ញាណអាក្រក់ ពពួកវិញ្ញាណ ឬក៏ត្រូវជាប់នៅក្នុងគម្រោងផែនការរបស់វានោះឡើយ ។ ជំនួសឱ្យនូវការនេះ យើងត្រូវតែបានទទួលនូវការដណ្តើមយក ជាមួយនឹងព្រះយេស៊ូវវិញ ។ ពេលដែលយើងបានត្រឡប់ទៅជាអ្នកមានសម្បជញ្ញៈថា យើងមានសិទ្ធិអំណាចក្នុងការកែជាថ្មីតាមរយៈព្រះយេស៊ូវហើយ នោះភាពអង់អាចនឹងងើបឡើង ចូលទៅក្នុងវិញ្ញាណរបស់យើងហើយ ។ យើងនឹងមិនមានការប្រកបស្និទ្ធស្នាល ដោយសារវិញ្ញាណអាក្រក់ ឬក៏ដោយសារគម្រោងផែនការរបស់វាតទៅទៀតហើយ ។

## IV. ព្រះទ្រង់បានបង្កើតពួកទេវតាឱ្យមាននៅ

### ក. ព្រះទ្រង់គង់នៅដ៏អស់កល្ប

ព្រះទ្រង់គង់នៅដ៏អស់កល្បជានិច្ច ។ ទ្រង់គឺតែងតែមាននៅ ហើយទ្រង់គឺជាអ្នកបង្កើតគ្រប់របស់ទាំងអស់ ។

ព្រះគម្ពីរយ៉ូហាន ១:១-៣

**ខ. ព្រះទ្រង់បានបង្កើតពួកទេវតា**

១. ទ្រង់គឺជាព្រះរាជបុត្រារបស់ព្រះ:

ព្រះយេស៊ូវ ទ្រង់បានបង្កើតគ្រប់របស់ទាំងអស់ រួមទាំងពួកទេវតាផងដែរ ។ ពួកគេគឺមិនមែនគ្រាន់តែត្រូវបានបង្កើតមក ដោយសារព្រះអង្គប៉ុណ្ណោះទេ គឺត្រូវបានបង្កើតមកសម្រាប់ជាគោលបំណង ខាងទេវភាពរបស់ព្រះអង្គថែមទៀតផង ។

ព្រះគម្ពីរកូល៉ុស ១:១៦,១

២. ពេលដែលលោកសាវ័កប៉ុលបានកត់បញ្ជី នូវបល្ល័ង្ក អំណាចគ្រប់គ្រង គោលការណ៍ និងអំណាចចេស្ដា: វាគឺជាការជំនួសឱ្យពួកទេវតា ។ គាត់បានប្រើប្រាស់ទម្រង់ដែលបានផ្ដល់ឱ្យទៅតាមមុខងាររបស់ពួកគេ។

៣. ពួកគេមានតួនាទីផ្សេងៗពីគ្នា:

ក. មហាទេវតា

ខ. ចេរ៉ូប៊ីន

គ. សេរ៉ូភីម

ឃ. ស្នាព្រះហស្តដ៏មានជីវិតរស់នៅ

៤. ពួកគេមុខងារផ្សេងៗគ្នា:

ក. អ្នកថែរក្សាបល្ល័ង្ក

ខ. អ្នកគ្រប់គ្រង

គ. ទេវតានៃព្រះអម្ចាស់

ឃ. ទេវតានៃអំណាចចេស្ដា

## V. ព្រះទ្រង់បានបង្កើតទេវតាលុស៊ីហ្វើរ

ចាប់តាំងពីយើងដឹងថា ព្រះយេស៊ូវទ្រង់បានបង្កើតគ្រប់របស់ទាំងអស់មក នោះយើងបានដឹងថា ទ្រង់ក៏បានបង្កើតទេវតាលុស៊ីហ្វើរមកដែរ ។

**ក. ទម្រង់ការតួនាទីរបស់លុស៊ីហ្វើរ**

ព្រះគម្ពីរអេសាយ ១៤:១២

ព្រះគម្ពីរយ៉ូប ៣៨:៧

**ខ.ការពណ៌នាពីលុស៊ីហ្វើរ**

១. ហោរាអេសេគាល និងហោរាអេសាយបានផ្ដល់ ឱ្យយើងនូវការយល់ដឹងនូវការពណ៌នាពីលុស៊ីហ្វើរនេះ ។

ព្រះគម្ពីរអេសេគាល ២៨:១២ខ

២. ការគ្របបាំងដោយត្បូងដ៏មានតម្លៃ

ព្រះគម្ពីរអេសេគាល ២៨:១៣ក

៣. មានសម្លេងដ៏ពិរោះ

ព្រះគម្ពីរអេសេគាល ២៨:១៣ខ

ឈឹងគឺជាប្រដាប់សម្រាប់គោះឧបករណ៍ភ្លេង ។ ប៉ី គឺជាគ្រឿងឧបករណ៍ខ្យល់ ។

ព្រះគម្ពីរអេសាយ ១៤:១១ក

ការបញ្ចេញសម្លេងរបស់វា គឺដូចជាវង់ភ្លេងដ៏អស្ចារ្យមួយ ដែលរួមបញ្ចូលទាំងឧបករណ៍ភ្លេងដែលមាន ខ្សែ ។

**គ. មុខងាររបស់លុស៊ីហ្វើរ**

ហោរាអេសេគាលបានសរសេរពីអ្វី ដែលជាមុខងារដើមរបស់លុសុហ្វើរនោះ ។

**១. ជាអ្នកការពារបល្ល័ង្ក**

ព្រះគម្ពីរអេសេគាល ២៨:១៤ ចេរូប៊ីនបានគ្របបាំងនូវទីសន្ដោសប្រោស គឺបានគ្របបាំងហឹបនៃសេចក្ដីសញ្ញា (និក្ខមនំ ២៥:១៨-២២) លូស៊ីហ្វើរ

នេះឯងគឺជាអ្នកដែលនៅបន្ទាប់ពីព្រះ គឺពីកន្លែងដ៏ល្អបំផុតរបស់ព្រះ ។ គឺជាតារាប្រចាំថ្ងៃ ឬជាកូននៃអរុណរះ គឺវានោះហើយជាអ្នកការពារបល្ល័ង្ករបស់ព្រះ ព្រមទាំងជាអ្នកបញ្ចេញនូវពន្លឺ និងសិរីល្អរបស់ផងព្រះ ។ វាគឺជាអ្នកដែលត្រូវបានចាក់ប្រេងតាំងឱ្យជាអ្នកយាម គឺជាចេរូប៊ីនោះឯង ។ វាត្រូវបានទទួលការផ្ទុកផ្តាក់ដោយព្រះ គឺត្រូវបានដាក់ឱ្យទទួលការខុសត្រូវ នៅកន្លែងដ៏ប្រសើរបំផុតនោះឯង ។

**២. ជាអ្នកដឹកនាំការសរសេរតម្កើង**

ក្រៅពីការពណ៌នាពីសម្លេងច្រៀងរបស់វា គឺវាបានលេចមុខមកជានាំពួកទេវតាទាំងអស់ ក្នុងការសរសើរ និងថ្វាយបង្គំដល់ព្រះ ហើយវាបានដើរយាមល្បាតបល្ល័ង្ករបស់ព្រះ ជាមួយនឹងការគ្របបាំងនូវការសរសើរ និងការថ្វាយបង្គំនោះទៀត ។

## VI. សង្គ្រាមនៅស្ថានសួគ៌ លូស៊ីហ្វើរត្រូវបានទម្លាក់ចុះ

**ក. ត្រូវបណ្តាសាដោយសេចក្តីអំនួត និងការបះបោរ**

ព្រះគម្ពីរអេសេគាល ២៨:១៥,១៧

លូស៊ីហ្វើរបានទទួលនូវការគ្រប់លក្ខណ៍ រហូតដល់ពេលវាបាននៅជាកណ្តាល ក្នុងការប្រុងប្រយ័ត្នរបស់វាទៅលើភាពដ៏ស្រស់ស្អាតផ្ទាល់ខ្លួនរបស់វា ជំនួសឱ្យនូវភាពដ៏ស្រស់ស្អាតដែលព្រះទ្រង់បានបង្កើតវាមកនោះក៏ធ្វើមានសេចក្តីអំនួតបានចូលមកដល់ខ្លួនវា ។ វាក៏បានគិតអំពីភាពដ៏ភ្លឺចិញ្ចែងផ្ទាល់របស់វានោះហើយ ដែលវាបានភ្លេចនូវការប្រុងប្រយ័ត្ន ទៅលើភាពដ៏ភ្លឺថ្លាស្រស់ប្រិមប្រិយ មកពីព្រះអង្គទ្រង់ផ្ទាល់នោះទៅវិញ ។

**ខ. "អញនឹង"**

មានបំណងមួយបានកើតឡើង បំណងព្រះហឫទ័យរបស់ព្រះដែលបានគ្រប់គ្រងលើសកលលោកទាំងមូល រហូតដល់សេចក្តីអំនួតបានចូលមកក្នុងលូស៊ីហ្វើរនោះទៅ ។

ព្រះគម្ពីរអេសាយ ១៤:១២-១៤

***អញនឹងឡើងទៅឯស្ថានសួគ៌ អញនឹងសោយរាជ្យលើ***

***បល្ល័ង្ករបស់អញ ឱ្យខ្ពស់ជាងផ្កាយរបស់ព្រះ***

***អញនឹងអង្គុយលើភ្នំជាទីប្រជុំជំនុំ នៅទីបំផុតនៃទិសខាងជើង***

***អញនឹងឡើងទៅផុតទីខ្ពស់នៃពពក***

***អញនឹងលើកខ្លួនឱ្យបានដូចជាព្រះដ៏ខ្ពស់បំផុត ។***

**គ.លូស៊ីហ្វើរត្រូវជាប់ជំនុំជម្រះ**

ព្រះគម្ពីរអេសាយ ១៤:១៥-១៧

នៅក្នុងការបះបោរ លូស៊ីហ្វើរបានអនុវត្តនូវបំណងរបស់វា ដោយការធ្វើផ្ទុយជំទាស់ទៅនឹងបំណងព្រះហឫទ័យរបស់ព្រះ ។ វាបានធ្វើការបញ្ជាក់ទៅនឹងចំនួន៥ចំណុចនៃពាក្យថា "អញនឹង" នេះគឺជាពាក្យរបស់លូស៊ីហ្វើរ ជាអ្នកឆបោក គឺជាការបញ្ជាក់ពីការបះបោររបស់វានោះឯង ដែលបានជឿនទៅជាលំដាប់ ទៅដល់ចំណុចដែលវាព្យាយាមប្រឹងប្រែងនឹងជំនួសកន្លែងរបស់ព្រះ នៅលើបល្ល័ង្កនៅឯនគរស្ថានសួគ៌នោះ ។

**ឃ. នៅសមរភូមិ**

ព្រះគម្ពីរវិវរណៈ ១២:៧-១០

ព្រះគម្ពីរអេសេគាល ២៨:១៦

លូស៊ីហ្វើរនិងពួកទេវតារបស់វា ត្រូវបានបណ្តេញចេញពីនគរស្ថានសួគ៌ហើយ ។

### ង. លទ្ធផលនៃសង្គ្រាម

១. ទេវតាមួយភាគបីត្រូវបានទម្លាក់ចុះ

ទេវតាមួយភាគក្នុងបី គឺនៅក្រោមការបញ្ជាត្រួតត្រារបស់លូស៊ីហ្វើរ ហើយពួកគេក៏ត្រូវបានទម្លាក់ចុះមកជាមួយនឹងវាដែរ ។ រីឯទេវតាដទៃទៀត ដែលនៅក្រោមការបញ្ជារបស់មីកែល និងកាព្រីយ៉ែល គឺស្ថិតនៅក្នុងការស្មោះត្រង់ជាមួយនឹងព្រះ ។ ព្រះគម្ពីវិវរណៈ ១២:៤ក

២. ការទម្លាក់ចុះមកផែនដី

លូស៊ីហ្វើរនិង "ពួកទេវតារបស់វា" ត្រូវបានគ្រវែងចោលមកលើភពផែនដី ។

ព្រះគម្ពីវិវរណៈ ១២:៩

### ច. ការផ្លាស់ប្តូរឈ្មោះ

ឈ្មោះរបស់លូស៊ីហ្វើរ គឺត្រូវបានផ្លាស់ប្តូរហើយ ។ តើវាដែលជាអ្នកត្រូវបានប្រទានឱ្យនូវមុខងារដ៏ជាទីស្រឡាញ់របៀបនេះ គឺដែលវាបានធ្វើជាកូននៃផ្កាយព្រឹក និងទទួលការចាក់ប្រេងតាំងជាទេវតាចេរូប៊ីន រីឯឈ្មោះរបស់វានោះ គឺបានត្រឡប់ទៅជា: នាគ ពស់ពីបុរាណ អារក្ស សាតាំង ។

ពួកទេវតាដែលនៅក្រោមសិទ្ធិអំណាចរបស់កូស៊ីហ្វើរ គឺជាអស់អ្នកដែលបានដើរតាមវាក្នុងការបះបោរនោះ ដែលបានកាន់ខ្ជាប់តាមរចនាសម្ព័ន្ធ នៃអង្គការរបស់ពួកគេ គឺជាបល្ល័ង្កអំណាច ការគ្រប់គ្រង និងសិទ្ធិអំណាចនោះឯង ប៉ុន្តែ ឈ្មោះរបស់ពួកគេ គឺត្រូវបានផ្លាស់ប្តូរឱ្យទៅជាការឆ្លុះបញ្ចាំងនូវធម្មជាតិធ្លាក់ចុះរបស់ពួកគេនោះទៅវិញ ។ ឥឡូវនេះពួកគេគឺត្រូវបានហៅឈ្មោះថា ពពួកវិញ្ញាណ វិញ្ញាណអាក្រក់ និងពួកវិញ្ញាណសាតាំងវិញ ។

### ឆ. ការផ្លាស់ប្តូរធម្មជាតិ

ធម្មជាតិទាំងស្រុងរបស់សាតាំង គឺបានផ្លាស់ប្តូរហើយ ។

**១. វាគឺជា:**

ផ្កាយព្រឹក ជាកូនរបស់ផ្កាយព្រឹក ជាម្នាក់ដែលធ្លាប់បានទទួលការអនុញ្ញាត ឱ្យធ្វើជាអ្នកសរសើរតម្កើង ធ្វើជាអ្នកយាមល្បាត និងជាអ្នកការពារបល្ល័ង្ករបស់ព្រះ ។

**២. វាបានត្រឡប់ទៅជា:**

ពុករលួយ អាម៉ាសមុខ ត្រូវបណ្តេញចេញពីនគរស្ថានសួគ៌ ។

**៣. វាជាអ្នកដែលបាត់បង់**

ភាពដ៏ស្រស់ស្អាតរបស់វា មុខងារដ៏ខ្ពង់ខ្ពស់របស់វាដែល នៅក្នុងនគរស្ថានសួគ៌របស់ព្រះ ។

**៤. ធម្មជាតិរបស់វា**

ត្រឡប់ទៅជាសេចក្តីសេចក្តីងងឹត ទៅជាសេចក្តីអាក្រក់ វិញ្ញាណអាក្រក់ ពេញដោយសេចក្តីសម្អប់ជាដើម ។ នេះគឺជាលទ្ធផលនៃអំពើបាបរបស់វា គឺជាសេចក្តីអំនួត និងការបះបោរនោះឯង ។

## VII. ផែនដីដែលបានបង្កើតឡើងដោយព្រះ

នៅក្នុងព្រះគម្ពីរលោកុប្បត្តិបានប្រាប់យើងថាព្រះទ្រង់បានបង្កើតផែនដី ។

ព្រះគម្ពីរលោកុប្បត្តិ ១:១

### ក.ដែលអាចមានមនុស្សនៅបាន

ព្រះគម្ពីរអេសាយ ៤៥:១៨

**ខ. បានត្រឡប់ជា ដោយគ្មានទម្រង់**

ទោះជាយ៉ាងណាក៏ដោយ ក៏មានព្រះគម្ពីរលោកុប្បត្តិ ១:២ បានពណ៌នាពីផែនដី ដោយគ្មានទម្រង់ នៅទទេ និងងងឹត ។ នៅក្នុងភាសាហេព្រើរ ពាក្យដែលបានបកប្រែជាភាសាអង់គ្លេស ដូចជា "មាន នៅ គឺជា" នោះគឺគ្រាន់តែជាការពិតត្រង់ គឺដែលត្រូវបកប្រែថា "បានត្រឡប់មកជា" ។

ព្រះគម្ពីរលោកុប្បត្តិ ១:២

នៅក្នុងព្រះគម្ពីរយេរេមា យើងបានរកឃើញនូវពាក្យជាភាសាហេព្រើរ ដែលបានប្រើដូចៗគ្នា ។

ព្រះគម្ពីរយេរេមា ៤:២៣-២៧

**គ. សាតាំងបានទម្លាក់ចុះមកផែនដី**

វាជាការមានលទ្ធភាព ដែលសាតាំងត្រូវបានបណ្តេញមកផែនដីរវាងព្រះគម្ពីរលោកុប្បត្តិ ១:១ និង ១:២ (សូមមើលសេចក្តីពន្យល់នៅទំព័រទី៥) ។ ចូរព្យាយាមស្រមើស្រមៃទៅលើសាតាំង នៅពេលដែលវាត្រូវបានបណ្តេញចេញមកកាន់ផែនដីនេះ ។ វាបានទទួលនូវការគាំទ្រមួយនូវមុខងារដ៏ខ្ពស់បំផុតនៅឯនគរស្ថានសួគ៌ ។ វាបានទទួលនូវការពណ៌នាជាបន្តបន្ទាប់មកហើយ ។ វាគឺជាអ្នកឆ្លុះបញ្ចាំងបញ្ចេញនូវសិរីល្អរបស់ព្រះ ។ ទោះជាយ៉ាងក៏ដោយ ក្នុងការបះបោររបស់វា គឺវាបានសម្រេចចិត្តបន្ថែមហើយបន្ថែមទៀត ។ វាសម្រេចចិត្តចង់គ្រប់គ្រងលើនគរស្ថានសួគ៌ ។

មានសមរភូមិមួយដ៏ក្តៅគគុក ។ វានិងពួកទេវតារបស់វាដែលដើរតាមវេ នោះក៏បានបណ្តេញមកផែនដីផងដែរ ។ សាតាំង បានដើរក្រវែលគ្រប់ទីកន្លែង គឺវាបានដើររំឭកដល់ស្នាព្រះហស្តរបស់ គឺចំពោះអស់អ្នកណាដែលវាស្អប់ ប្រសិនណាជាបាន ។ វាតែងតែបានដើររំឭកដល់គ្រប់គ្នាទាំងអស់ដែលបាននាំឱ្យបាត់បង់តាមការបះបោររបស់វានោះ ។

ពិតប្រាកដណាស់សាតាំង គឺជាម្នាក់ដែលមកប្រយោជន៍តែនឹងលួច សម្លាប់ និងបំផ្លាញ ដោយនូវសេចក្តីងងឹតរបស់វា សេចក្តីសម្អប់ និងសេចក្តីកំហឹងរបស់វា គឺវាចង់បំផ្លាញផែនដីនេះដ៏ពិតប្រាកដ ។ មានតែរឿងមួយទេដែលសាតាំងបានចាកចេញទៅគ្រប់គ្រងលើ គឺដែលវាបានទទួលដោយទទេ គឺនៅក្នុងលំហ ហើយវាមាននោះគឺជាសេចក្តីងងឹតទាំងស្រុង ។ រីឯលូស៊ីហ្វើរវាបានសម្រេចចិត្តគ្រប់គ្រង លើចក្រវាឡទាំងមូលនេះឯង ។ ឥឡូវនេះ គ្រប់ទាំងអស់វាបានទទួលនូវការបាត់បង់អស់ហើយ វាទៅជាអ្នកដ៏តូចមួយ ងងឹត ទទេ គឺនៅក្នុងភពទទេនោះឯង ។

**ឃ. ផែនដីត្រូវបានព្រះកែជាថ្មីឡើងវិញ**

នៅក្នុងព្រះគម្ពីរលោកុប្បត្តិ ១:២ ដែលយើងបានអានគឺព្រះវិញ្ញាណនៃព្រះក៏រេរានៅពីលើទឹក ។ ព្រះគម្ពីរលោកុប្បត្តិ ១:៣ ចាប់ផ្តើមថា ព្រះទ្រង់មានបន្ទូលថា "ចូរឱ្យមានពន្លឺឡើង" ។ សាតាំងបានស្គាល់នូវសម្លេងនេះ! ចូរធ្វើការស្រមើស្រមៃពីរបៀបដែលវាត្រូវតែមានការស្លន់ស្លោ គឺនៅដែលវាបានឮនូវសម្លេងរបស់ព្រះនេះ ។ សូម្បីតែនៅលើផែនដ៏នេះក៏វាមិនអាចនឹងពីព្រះបានដែរ ។ សូម្បីតែនៅពេលឥឡូវនេះព្រះទ្រង់ក៏មិនបានទុកវាឱ្យនៅតែឯងដែរ ។ ឱចំពោះសាតាំងដែលវាមានការរន្ធត់យ៉ាងណាទៅហ្ន៎ ដែលវាបានឃ្លាំមើលថាតើព្រះទ្រង់បានកែផែនដី នូវភាពស្រស់ស្អាតដើមរបស់វាដែលនៅក្នុងពេល៥ថ្ងៃបន្ទាប់នោះ ។

**១. ព្រះទ្រង់មានផែនការ "ព្រះទ្រង់មានបន្ទូលថា ..."**

ផែនដីត្រូវបានបង្កើតសារជាថ្មីឡើងវិញ តាមរយៈព្រះបន្ទូល ។ វាគឺជាការសំខាន់ដើម្បីឱ្យយល់ថា ព្រះទ្រង់មានបន្ទូល ត្រឡប់ចូលទៅក្នុងអត្ថិភាពទាំងអស់ ដែលបានទទួលនូវការបំផ្លាញនោះ ។ ព្រះគម្ពីរលោកុប្បត្តិ ១:៣,៦,៩,១១,១៤,២០,២៤ ។

ចូរស្រមើស្រមៃមើលទៅសាតាំង ដែលវាបានបន្លឺឧទាន ទៅពពួកវិញ្ញាណអាក្រក់របស់វាថា "ហេតុអ្វីបានជាព្រះ ទ្រង់មិនបានទុកយើងឱ្យនៅតែឯង? ទ្រង់មានចក្រវាឡទាំងមូលជារបស់ផងទ្រង់ ចូររត់គ្រប់ការទាំងអស់ដែលយើងអាចធ្វើបាន ពីព្រោះយើងមានតែភពដ៏តូចមួយនេះប៉ុណ្ណោះ!" ភាពភ័យស្លន់ស្លោ និងសេចក្តីកំហឹងត្រូវតែបានទទួលនូវការទុក្ខសោក ដែលសាតាំងវាបានអន្ទះសារ ក្នុងថ្ងៃទាំង៥នៃការស្តាប់ឮសម្លេង ដែលព្រះទ្រង់មានបន្ទូលនោះ ។ នៅពេលដែលព្រះទ្រង់មានព្រះបន្ទូលនោះផែនដីក៏ត្រូវបានទទួលនូវការកែជាថ្មីឡើងវិញ ។ រីឯប្រពលភាពនៃសេចក្តីកំហឹងរបស់សាតាំង ចំពោះព្រះនោះ ត្រូវតែមានការគម្រាមជារៀងរាល់ថ្ងៃ ។

## ២. កំណត់ចំណាំ

ព្រះគម្ពីរផ្តត់ផ្គង់ឱ្យយើងមិនត្រឹមតែ ជាការឯកភាពទៅលើព្រឹត្តិការណ៍អ្វីៗដែលបន្តទំនាក់ទំនង ទៅនឹងការធ្លាក់ចុះរបស់សាតាំង និងការបង្កើតមនុស្សឡើងនោះទេ ។ សម្ភារៈនៅក្នុងមេរៀននេះ គឺឈរលើមូលដ្ឋាន "ទ្រឹស្តីច្រឡោះប្រហោង" ដែលបង្រៀនថាមាន "ទីចន្លោះ" នេះ នៅចន្លោះពេល ខ.១ និង ខ.២ នៅក្នុងជំពូកដំបូងនៃព្រះគម្ពីរលោកុប្បត្តិនេះ ។ ទ្រឹស្តីនេះបង្រៀនថា សាតាំងត្រូវបានបណ្តេញចេញមកផែនដី គឺបន្ទាប់ពីមានការបះបោរដូច្នេះហើយ ផែនដីក៏បានត្រឡប់ជាខូចទ្រង់ទ្រាយ នៅទទេ និងមានសុទ្ធតែងងឹតនៅគ្របលើជម្រៅទឹក ដូចជាបានពណ៌នានៅក្នុងខ.២រួចមកហើយ ។

ការបង្រៀនដទៃទៀតដែលជាការបះបោរ និងការធ្លាក់ចុះរបស់សាតាំង គឺបានកើតឡើងបន្ទាប់ពីមនុស្សត្រូវបានបង្កើតមកនោះដែរ ។ រីឯការផ្តត់ផ្គង់ដទៃទៀត ក៏មិនមែនជាការព្រមព្រៀង នៅក្នុងការដាក់ពេលបណ្តេញចេញរបស់សាតាំងពីស្ថានសួគ៌ មកកាន់ផែនដីនោះដែរ ។

វាមិនមែនជាការសំខាន់ ក្នុងការព្រមព្រៀងជាមួយនឹងព្រឹត្តិការណ៍ជាបន្ត ដែលបានពណ៌នានៅក្នុងមេរៀននេះរួចមកហើយនោះទេ គឺវាគ្រាន់តែឱ្យបានយល់ថា មនុស្ស គឺត្រូវបានបង្កើតមកឱ្យចំនឹងរូបអង្គព្រះនោះឯង គឺដែលត្រូវបានប្រទានមកដោយនូវសិទ្ធិអំណាច និងអំណាចគ្រប់គ្រងដ៏មាំមួននៅលើផែនដីនេះតែប៉ុណ្ណោះ ។ វាក៏ជាការសំខាន់ក្នុងការយល់ថា នេះគឺជាហេតុផល ដែលសាតាំងស្អប់មនុស្សជាតិដ៏ខ្លាំងដល់ម្ល៉េះនោះឯង ។

# VIII. សិទ្ធិអំណាចដែលបានប្រទានឱ្យដល់មនុស្សជាតិ

## ក. ការបង្កើតឱ្យរូបភាពរបស់ព្រះ

នៅថ្ងៃទី៦ទ្រង់បានបង្កើតមនុស្សជាប្រុសជាស្រី ឱ្យមានរូបភាពដូចជាទ្រង់ហើយទ្រង់បានប្រទានពរដល់ពួកគេឱ្យមាន

សិទ្ធិអំណាចលើគ្រប់ទាំងអស់ ដែលមានជីវិតរស់នៅលើផ្ទៃនៃផែនដីទាំងមូល ។

## ខ. ចូរឱ្យពួកគេមានអំណាចគ្រប់គ្រង

នៅក្នុងព្រះគម្ពីរលោកុប្បត្តិជំពូកទីមួយ បានប្រាប់យើងថា មនុស្សជាតិត្រូវបានបង្កើតមកនៅក្នុងរូបភាពរបស់ព្រះ ។ នៅក្នុងព្រះគម្ពីរលោកុប្បត្តិជំពូកទី៩ ក៏បានប្រាប់យើងម្តងទៀតដូចគ្នានេះដែរ ។

ព្រះគម្ពីរលោកុប្បត្តិ ១:១២

ព្រះគម្ពីរលោកុប្បត្តិ ៩:៦

ការដឹងថាមនុស្សប្រុសស្រីដែលត្រូវបានបង្កើតមក គឺដូចជាកញ្ចក់ឆ្លុះរូបរបស់ព្រះ គឺជាការសំខាន់ក្នុងការយល់ដឹងទៅលើប្រធានបទ ពីព្រោះរូបភាពរបស់ព្រះគឺជារូបភាពមួយដែលមានសិទ្ធិអំណាច ។

ព្រះគម្ពីរលោកុប្បត្តិ ១:២៧ ។

## គ. ជីវិតដែលបានប្រទានមកពីព្រះ

ព្រះទ្រង់បានសូនរូបកាយរបស់មនុស្សមកពីធូលីដី ដោយព្រះហស្តរបស់ទ្រង់ ហើយបន្ទាប់មកទៀតទ្រង់បានផ្លុំខ្យល់ដង្ហើមចូលទៅក្នុងមនុស្សនោះ គឺជាដង្ហើមដែលមកពីព្រះនោះឯង ។ ព្រះទ្រង់បានផ្លុំដង្ហើមចូលទៅក្នុងមនុស្សជាតិ នោះហើយគឺជាធម្មជាតិរបស់ព្រះ ។

ទ្រង់បានប្រទានជីវិតរបស់ទ្រង់មកឱ្យយើងរាល់គ្នា ។ គឺជាជីវិតរបស់ព្រះនោះឯងដែលមាននៅក្នុងយើង!

ព្រះគម្ពីរលោកុប្បត្តិ ២:៧

## ឃ. សិទ្ធិអំណាចលើសាតាំង

បន្ទាប់ពីមានសង្គ្រាមនៅលើស្ថានសួគ៌មក សាតាំងត្រូវបានបណ្តេញចេញពីស្ថានសួគ៌មកផែនដី ។ តើលោកអ្នកអាចគិតស្រមើស្រមៃមើលទៅលើការដ៏គួរឱ្យរន្ធត់របស់វា ដូចជាវាបានឃ្លាំមើលដល់ព្រះ ដែលទ្រង់បានបង្កើតមនុស្សជាតិមក ហើយទ្រង់បានផ្លុំខ្យល់ដង្ហើម ចូលទៅក្នុងគេធ្វើឱ្យគេជីវិតរបស់ព្រះ បន្ទាប់មកទៀតទ្រង់ក៏បានប្រទានឱ្យគេនូវការកើតជាថ្មី ឱ្យបានគ្រប់ មានអំណាចគ្រប់គ្រងលើគ្រប់ជីវិតទាំងអស់ដែលនៅលើផ្ទៃនៃផែនដីនេះឬទេ? សាតាំងកំពុងតែរស់នៅលើផែនដីនេះ! រីឯអំណាចគ្រប់ត្រូវបានប្រទានឱ្យដល់មនុស្ស រួមបញ្ចូលទាំងសិទ្ធិអំណាចគ្រប់គ្រងលើសាតាំង និងអ្នកដើរតាមវាផងដែរ។ ប្រពលភាពរបស់របស់សាតាំងគឺជាសម្អប់ដល់ ហើយក៏វាបែរត្រឡប់មកស្អប់ដល់អ្នកដែលបានកើតឡើងជាថ្មី ដែលមើលទៅហាក់ដូចជាព្រះនោះផងដែរ ហើយដែលពួកគេក៏មានជីវិតរបស់នៅជាមួយផងដែរ ។ នោះគឺជាហេតុដែលយើងស្ថិតនៅក្នុងសង្គ្រាមនោះឯង ។ គោលដៅរបស់វាគឺបានត្រឡប់ទៅជាការសម្លាប់ លួច និងការបំផ្លាញនូវការកើតជាថ្មីនេះ ដែលវាបានចាប់ផ្តើមប្រើប្រាស់ឆបោកធ្វើឱ្យមនុស្សត្រូវបរាជ័យ ។ នោះហើយគឺជាមូលហេតុដែលសាតាំងស្អប់ដល់យើង ។ នោះហើយគឺជា មូលហេតុដែលយើងស្ថិតនៅក្នុងសង្គ្រាមនោះឯង ។

## ក្រុមពិភាក្សា

១. តើគ្រឿងសាស្ត្រាវុធគឺជាអ្វី ដែលព្រះទ្រង់បានប្រទានឱ្យសម្រាប់សមរភូមិរបស់យើង ប្រឆាំងទប់ទល់នឹងអារក្ស?

២. ចូរធ្វើការពិភាក្សានូវពាក្យ "អញនឹង" ទាំង៥ចំណុចរបស់លូស៊ីហ្វើរ (អេសាយ ១៤:១២-១៤) ដែលវាបង្កប់នូវសេចក្តីអំនួតដាក់នៅពីក្រោយយើងម្នាក់ៗ ។

៣. ហេតុអ្វីបានជាសាតាំងស្អប់ដល់មនុស្សជាតិខ្លាំងម្ល៉េះ?

## ការសិក្សាដោយខ្លួនឯង

១. តើមនុស្សម្នាក់អាចបញ្ឈប់អ្នកដែលចូលនៅមុន គឺជាអារក្ស ហើយអាចបានត្រឡប់មកជាអ្នកនៅក្នុងព្រះយេស៊ូវបានដោយរបៀបណា?

២. រូបភាពរបស់ព្រះគឺជារូបភាព ដែលមានសិទ្ធិអំណាច ។ យើងត្រូវបានបង្កើតមកនៅក្នុងរូបភាពរបស់ផងព្រះ ។ តើអ្វីទៅគឺជាសេចក្តីពិតទាំងពីរនេះ ដែលប្រាប់យើងអំពីរូបភាពរបស់យើងនោះ?

៣. ហេតុអ្វីបានជាគោលដៅរបស់សាតាំង គឺជាការ សម្លាប់ លួច និងបំផ្លាញដល់មនុស្សជាស្នាព្រះហស្តរបស់ព្រះ?

# សិទ្ធិអំណាចរបស់អ្នកជឿ

## *មេរៀនទី ២: សិទ្ធិអំណាចនៅលើផែនដីនេះ*

## I. “ចូរឱ្យពួកគេមានអំណាចគ្រប់គ្រងលើផែនដី និងរបស់សព្វសាររពើនៅលើផែនដី”

### ក. គោលបំណងរបស់ព្រះ

គោលបំណងនៃការបង្កើតរបស់ព្រះ គឺជាកាសូនធ្វើ ដោយទ្រង់មានបន្ទូលបញ្ជាថា "ចូរឱ្យពួកគេមានអំណាចគ្រប់គ្រងលើផែនដីទាំងអស់ និងគ្រប់របស់ទាំងអស់នៅលើផែនដី" ព្រះគម្ពីរលោកុប្បត្តិ ១:២៦-២៨ក ។

### ខ. ព្រះទ្រង់បានជប់សូននាងអេវ៉ា

ប៉ុន្តែ វាមិនជាការល្អទេដល់មនុស្សប្រុសដែលរស់នៅតែម្នាក់ឯងនោះ ។

ព្រះគម្ពីរលោកុប្បត្តិ ២:២១-២៤

សាតាំងគឺមានការក្តៅចិត្ត ។ ឥឡូវនេះ អ្នកទាំងពីរនាក់គឺជាអ្នកមានរូបភាព ***ដូចជាព្រះ*** ដើរដូចជាព្រះ និងនិយាយស្តីដូចជាព្រះ ។

ព្រះគម្ពីរលោកុប្បត្តិ ១:២៨

### គ. គ្រប់ទាំងអស់គឺនៅក្រោមបាទជើងរបស់ពួកគេ

ព្រះគម្ពីរទំនុកដំកើង ៨:៤-៦

នៅក្នុងភាសាហេព្រើរ ពាក្យដែលបានប្រើសម្រាប់ពួកទេវតាគឺជា**អេឡូហ៊ីម** ។

ព្រះគម្ពីរទំនុកដំកើង ១១៥:១៦

ព្រះគម្ពីរទំនុកដំកើង ២៤:១

ឥឡូវនេះព្រះទ្រង់បានធ្វើឱ្យសិទ្ធិអំណាច និងអំណាចគ្រប់គ្រងនៅក្នុងចក្រវាឡទាំងមូលនេះ លើកលែងតែភពផែនដីនេះចេញ ។ នេះហើយគឺជាព្រះដែលទ្រង់បានប្រទានពរនូវសិទ្ធអំណាច ដើម្បីឱ្យការបង្កើតឡើងជាថ្មីនេះ មានភាពដូចជាព្រះគឺជាមនុស្សប្រុស-ស្រីនេះឯង ។ មនុស្សប្រុសគឺមិនមានសិទ្ធិអំណាចគ្រប់គ្រងលើអ្នក ដែលដើរតាមមនុស្សនោះទេ ។ គេត្រូវបានទទួលនូវសិទ្ធិអំណាច គ្រប់គ្រងលើគ្រប់ស្នាព្រះហស្តទាំងអស់របស់ព្រះនៅលើផែនដីនេះ និងលើសាតាំង ព្រមទាំងលើពួកវិញ្ញាណរបស់វា ។

ភាពនៃការគ្រប់គ្រងគឺត្រូវបានប្រទានឱ្យមកមនុស្ស ព្រះទ្រង់ក៏នៅតែជាម្ចាស់នៃភពផែនដីនេះដែរ ។ ឥឡូវនេះ ព្រះទ្រង់មិនអាចធ្វើនៅលើផែនដីនេះបាន ដោយគ្មានការយល់ព្រមមកពីមនុស្ស ដើម្បីឱ្យបានសម្រេចការងារនៅលើផែនដីនេះបានឡើយ ។

### ឃ. ប្រពលភាពរបស់សាតាំងគឺជាការសម្អប់

សាតាំងបានស្អប់ដល់លោកអ័ដាម និងនាងអេវ៉ា ពីព្រោះពួកគេគឺជាស្នាព្រះហស្តនៅក្នុងរូបភាពរបស់ព្រះ ។ ក្នុងពេលដែលពួកគេបានកើតជាថ្មីភ្លាម ពួកគេត្រូវបានទទួលនូវការប្រទានពរគ្រប់បែបយ៉ាង ដែលវាបានព្យាយមចាប់យកដោយបង្ខំនោះឯង ។

***ពួកគេគឺមានភាពដូចជាព្រះ ។***

***ពួកគេបានដើរដូចជាព្រះ និងនិយាយស្តីដូចជាព្រះ ។***

ពួកគេបានត្រូវទទួល នូវការប្រទានអំណាចគ្រប់គ្រងលើរបស់ទាំងអស់នៅលើផែនដីនេះ និងរួមទាំងសាតាំងផងដែរ ។ ដោយសាររួមទាំងរបស់គ្រប់យ៉ាង ដែលវា គឺជាសាតាំងបាន

មានអំណាចគ្រប់គ្រងពីលើនោះឯង ។ គឺជាការដែលរួមបញ្ចូលទាំងនគរទាំងមូលមូល "របស់វា" នោះឯង ។

**ង. "អញនឹង" គឺជាពាក្យរបស់សាតាំងដែលធ្វើខុសគ្នាជាមួយនឹងផែនការរបស់ព្រះសម្រាប់មនុស្ស ។**

ចូរចងចាំថាពាក្យ "អញនឹង" គឺជាពាក្យរបស់សាតាំងដែលមាននៅក្នុងព្រះគម្ពីរអេសាយ ១៤:១៣-១៥ ។

***អញនឹងឡើងទៅឯស្ថានសួគ៌ អញនឹងដំកើងបល្ល័ង្កអញឱ្យខ្ពស់ជាងអស់ទាំងផ្កាយរបស់ព្រះ ។***
***ហើយអញនឹងអង្គុយលើភ្នំជាទីប្រជុំជំនុំ***
***នៅទីបំផុតនៃទិសខាងជើង***
***អញនឹងឡើងទៅផុតទីខ្ពស់នៃពពក***
***អញនឹងលើកខ្លួនឱ្យបានដូចជាព្រះដ៏ខ្ពស់បំផុត***
***តែឯងបានត្រូវទំលាក់ចុះដល់ស្ថានឃុំព្រលឹងមនុស្សស្លាប់វិញ***
***គឺដល់ទីជំរៅនៃជង្ហុកធំ ។***

**ច. គ្រប់យ៉ាងដែលសាតាំងមានប្រាថ្នា គឺត្រូវបានប្រទានឱ្យដល់មនុស្ស ។**

គ្រប់យ៉ាងដែលសតាំងមានបំណង គឺត្រូវបានទៅជាអ្នកបះបោរវិញ ព្រះទ្រង់បានប្រទានពររបស់នីមួយៗឱ្យទៅដៅមនុស្សហើយ!

**១. សាតាំងនិយាយថា "អញនឹងឡើងទៅឯស្ថានសួគ៌" ។**

មនុស្សជាតិបានបង្កើតមក ឱ្យមានការប្រកបទាក់ទងជាមួយនឹងព្រះ ដើរជាមួយនឹងព្រះ និយាយជាមួយនឹងព្រះ ព្រមតាំសោយរាជ្យជាមួយនឹងព្រះអង្គ ។

ព្រះគម្ពីរវិវរណៈ ២០:៦

**២. សាតាំងនិយាយថា "អញនឹងដំកើងបល្ល័ង្កអញ ឱ្យខ្ពស់ជាងអស់ទាំងផ្កាយរបស់ព្រះ" ។**

ផ្កាយរបស់ព្រះគឺបានបញ្ជូនពួកទេវតាដ៏សំខាន់ៗចុះមក ។

ព្រះគម្ពីរ ១កូរិនថូស ៦:២-៣

**៣. សាតាំងនិយាយថា "ហើយអញនឹងអង្គុយលើភ្នំជាទីប្រជុំជំនុំ នៅទីបំផុតនៃទិសខាងជើង" ។**

យើងត្រូវបានអង្គុយនៅក្នុងនគរស្ថានសួគ៌ ជាមួយនឹងព្រះ យេស៊ូវដ៏ពិតប្រាកដ ។

ព្រះគម្ពីរអេភេសូរ ២:៦

សាតាំងនិយាយថា "អញនឹងឡើងទៅផុតទីខ្ពស់នៃពពក" ។

យើងនឹងជួបជាមួយនឹងព្រះយេស៊ូវ នៅនាអាកាស នៅក្នុងពពក ។

ព្រះគម្ពីរ ១ថែស្សាឡូនិច៤:១៦-១៧

**៤. សាតាំងនិយាយថា "អញនឹងលើកខ្លួនឱ្យបានដូចជាព្រះដ៏ខ្ពស់បំផុត" ។**

មនុស្សដែលបានបង្កើតមក ឱ្យមានរូបភាពដូចជាព្រះ ។ តើលោកអ្នកនៅតែមានចម្ងល់ថា ហេតុអ្វីបានជាសាតាំងស្អប់ដល់មនុស្សជាតិ?

យើងបានត្រូវបង្កើតមក ឱ្យមានរូបភាពដូចជាព្រះ ឱ្យនិយាយជាមួយនឹងព្រះ ឱ្យដើរជាមួយនឹងព្រះ ឱ្យបានគ្រប់គ្រងជាមួយនឹងព្រះ!

ឱតើការបន្ទាបខ្លួន វាត្រូវតែមានចំពោះសាតាំងដែលយើងបានត្រូវទទួលនូវការប្រទាន ពីគ្រប់បែបយ៉ាង ដែលវាបានព្យាយាមក្នុងការចាប់យកនូវការ

បះបោរនេះ ។ សាតាំងបានឃើញលោកអ័ដាម និងនាងអេវ៉ា ហើយវាក៏បានដឹងពីមនុស្សជាតិយ៉ាងដូច្នោះ គឺដែលពួកគេបានទទួលនូវការប្រទាននូវជីវិតដែលដូចទៅនឹងធម្មជាតិរបស់ព្រះ នោះពិតជាបានសម្រេចមែន។ សាតាំងត្រូវតែបានទទួលនូវការរន្ធត់ ដែលមនុស្សជាតិឥឡូវនេះមានសិទ្ធិអំណាច គ្រប់គ្រងលើគ្រប់បែបយ៉ាងនៅលើផែនដីនេះ ។ ដូច្នេះសាតាំងក៏បានប្រឌិតឡើង នូវគម្រោងផែនការផ្ទាល់របស់វា!

## II. គម្រោងផែនការរបស់សាតាំង

### ក. មនុស្សបានប្រទាននូវឆន្ទៈសេរី

ព្រះទ្រង់បានប្រទានដល់លោកអ័ដាម ឱ្យមានឆន្ទៈសេរី។ លោកអ័ដាមបានមានអំណាចដើម្បីនឹងជ្រើសរើស រវាងការស្ដាប់បង្គាប់ និងការមិនស្ដាប់បង្គាប់ ។ ដោយការជ្រើសរើសដោយសេរីនោះហើយ ដែលព្រះទ្រង់ក៏បានប្រទាននូវទោសបញ្ញត្តិសម្រាប់ការមិនស្ដាប់បង្គាប់នោះ ។ មនុស្សគឺមិនមែនជាម៉ាស៊ីនយន្តទេ ។ គេត្រូវបានបង្កើតមកនៅក្នុងរូបភាពរបស់ព្រះ ។

ព្រះគម្ពីរលោកុប្បត្តិ ២:១៧

### ខ. រូបមន្តរបស់សាតាំង

សាតាំងបានឆបោកដល់ពួកទេវតា នៅក្នុងនគរស្ថានសួគ៌ ហើយមួយភាគបីនៃទេវតាទាំងនោះ ក៏បានដើរតាមវាក្នុងការបះបោរនោះ ។ វាធ្លាប់មានការពិសោធន៍ក្នុងការប្រេប្រាស់នូវការឆបោកនេះ ។

### គ. វាបានលាក់បាំងខ្លួនវា និងបានសួរទៅព្រះ

សាតាំងបានជ្រើសរើសលាក់ខ្លួនវា ធ្វើជាសត្វពស់ដើម្បីវាបានចូលមកឯសួនច្បារអេដែន ដោយមិនអាចកត់ចំណាំវាបាន ។ វាគ្មានសិទ្ធិអ្វីទេក្នុងការចូលមកក្នុងសួនច្បារនេះ លោកអ័ដាមមានសិទ្ធិបណ្ដេញវាបាន ប្រសិនបើសាតាំងវាចូលមកដោយគ្មានការលាក់ខ្លួននោះ ។

ព្រះគម្ពីរលោកុប្បត្តិ ៣:១ក

"ការប៉ិនប្រសប់" មានន័យថាវាងវៃ ឬឆ្លាត ។ សាតាំងបាននៅក្នុងរូបកាយរបស់សត្វពស់ នៅពេលដែលវាបាននិយាយទៅកាន់នាងអេវ៉ា ។វិញ្ញាអាក្រក់គឺនៅតែធ្វើសម្រេចនៅក្នុងរូបកាយនៅសម័យសព្វថ្ងៃនេះ ។ នោះហើយគឺជាការលាក់ខ្លួន និងការបិទបាំងសម្រាប់វិញ្ញាណអាក្រក់ ដែលពួកគេចង់បានទទួលនូវការបម្រើយនេះ ។

ព្រះគម្ពីរលោកុប្បត្តិ ៣:១ខ

សាតាំងបានសួរនូវអ្វីដែលព្រះទ្រង់មានបន្ទូល ហើយនៅពេលដដែលនោះ ក៏បានចាកចេញពីទោសបញ្ញត្តិចំពោះអំពើបាបនោះ ។

### ឃ. ការកំណត់ចំពោះព្រះ

ចូរកំណត់ចំណាំថា សាតាំងបានកំណត់នូវព្រះបន្ទូលរបស់ព្រះជាលំដាប់លំដោយ ដែលបានត្របាញ់បញ្ចូលពួកគេទៅក្នុងការឆបោករបស់វានោះ ។

ព្រះគម្ពីរលោកុប្បត្តិ ៣:២-៣

នាងអេវ៉ាបានបន្ថែមថា "ប៉ះពាល់" ទៅលើអ្វីដែលព្រះទ្រង់បានមានបន្ទូលដ៏ច្បាស់លាស់ ប៉ុន្តែ នាងនៅតែបានចងចាំនូវទោសបញ្ញត្តិនោះ ។

### ង. ការកុហករបស់សាតាំង

ព្រះគម្ពីរលោកុប្បត្តិ ៣:៤ខ ចែងថា "អ្នកនឹងមិនស្លាប់ជាពិតមែនទេ" ។ សាតាំងបាននិយាយជំទាស់ទៅនឹងអ្វីដែលព្រះទ្រង់បានមានបន្ទូលមកនោះ ប៉ុន្តែ នាងអេវ៉ាបានបន្តស្តាប់ដល់វាទៅវិញ ។ បន្ទាប់មក សាតាំងក៏បានធ្វើការសន្ទនាជាមួយនឹងរង្វាន់អំពើបាបនោះទៅទៀត ។

### ច. អ្នកនឹងបានដូចជាព្រះដែរ

ព្រះគម្ពីរលោកុប្បត្តិ ៣:៥

សាតាំងនិយាយទៅកាន់លោកអ័ដាម និងនាងអេវ៉ាថា "ភ្នែករបស់អ្នកនឹងបានភ្លឺ នោះអ្នកនឹងបានដូចជាព្រះដែរ!" ។ រឿងនោះហើយ គឺមិនមែនជាការបង្កើតវិញ្ញាណនោះទេ ។ ពួកគេគឺបានដូចជាព្រះរួចទៅហើយ ប៉ុន្តែសាតាំងបានបញ្ចេញល្បិចកលដល់ពួកគេ ឱ្យគេបានមានចំណង់បន្ថែមទៀត ។ សាតាំងមិនមែនបង្កើតវិញ្ញាណជាចាំបាច់នោះទេ ។

## III. លោកអ័ដាមនិងនាងអេវ៉ាបានធ្វើបាប

### ក. ទាំងពីរនាក់បានធ្វើបាប

ជាច្រើនដងមកហើយ យើងមានគំរូពីនាងអេវ៉ាតែម្នាក់ឯងគត់ គឺនៅពេលដែលសាតាំងបានលាក់ខ្លួននៅនឹងសត្វពស់មួយនោះ ក៏បានចូលមកឯនាង ។ នោះគឺមិនមែនជាអ្វីដែលព្រះគម្ពីរបានចែងមកនោះទេ ។ នៅក្នុងខ.៦ យើងបានអានថា "នាងក៏បានចែកឱ្យប្តីរបស់នាង គាត់ក៏បរិភោគតាម" ។ ពួកគេទាំងពីរនាក់ក៏បានឈប់ធ្វើតាមព្រះបន្ទូលរបស់ព្រះ គឺបានធ្វើតាមវិញ្ញាណខាងសាច់ឈាមរបស់ពួកគេទៅវិញ គឺពួកគេបានស្តាប់តាមសាតាំង ព្រមទាំងបានទទួលទានផ្លែឈើនោះទៅ ។ ព្រះគម្ពីរលោកុប្បត្តិ ៣:៦ ។

នៅពេលដែលលោកអ័ដាម និងនាងអេវ៉ាមិនបានស្តាប់បង្គាប់ដល់ព្រះ ព្រមទាំងបានទទួលទានផ្លែឈើនោះ នោះធម្មជាតិរបស់ព្រះក៏បានចាកចេញពីពួកគេ ។ ពួកគេត្រូវបានទទួលនូវការស្លៀកពាក់ឱ្យនូវពន្លឺនៃសិរីល្អ នូវធម្មជាតិរបស់ព្រះ ឥឡូវនេះពួកគេត្រូវបាននៅជាអាក្រាតវិញ ។ ការប្រើប្រាស់ដើមឈើដឹងខុសត្រូវ គឺដឹងល្អដឹងអាក្រក់ នោះសាតាំងបានធ្វើការបោកប្រាស់ទេ ។ លោកអ័ដាម និងនាងអេវ៉ា និងឧបាយបញ្ឆោត ព្រមទាំងការធ្វើឱ្យពួកគេបរាជ័យ ។ ពួកគេបានប្រគល់នូវកូនសោរខាងសិទ្ធិអំណាច និងអំណាចគ្រប់គ្រងទៅសាតាំហើយ ។ សាតាំងមិនដែលមានការផ្លាស់ប្រែទេ ។ គាត់ទិចរបស់វា គឺដូចគ្នានៅសម័យសព្វថ្ងៃនេះ! ពួកគេបានទម្លាក់ចោល នូវសិរីល្អរបស់ព្រះឱ្យខ្ចីទៅហើយ ។

### ខ. ពួកគេត្រូវបានចាកចេញ

**១. សាតាំងបានបោកបញ្ឆោតដល់ពួកគេ ហើយមនុស្សជាតិក៏ត្រូវបានធ្វើឱ្យមានស្លាកស្នាម នូវការបិទបាំងអំណាចគ្រប់គ្រង និងសិទ្ធិអំណាច ។**

ព្រះគម្ពីរលោកុប្បត្តិ ៣:៧

ព្រះគម្ពីរលោកុប្បត្តិ ៣:១០

ពួកគេមានសេចក្តីភ័យខ្លាច ក៏លាក់ខ្លួន និងព្យាយាមបិទបាំងខ្លួនគេពួក ។ សាតាំងបានធ្វើឱ្យលោកអ័ដាម និងនាងអេវ៉ាត្រូវបរាជ័យ ។ ពួកគេក៏បានទទួលនូវការស្លាប់ខាងវិញ្ញាណ ។

**២. សាសនាដែលមានការបិទបាំងខ្លួនដោយស្លឹកល្វា**

ឥឡូវនេះ ទម្រង់ការគ្រប់គ្រងនៅលើផែនដីនេះ គឺត្រូវការបិទបាំង និងលាក់ខ្លួនដោយនៅពីក្រោយ

គុម្ពឈើ! មនុស្សជាតិនៅតែបន្តព្យាយាមបិទបាំងខ្លួនគេ មកដល់សព្វថ្ងៃនេះ ។ ស្លឹកល្វាដែលលោកអ័ដាម និងនាងអេវ៉ាបានប្រើក្នុងការបិទបាំងខ្លួនគេ គឺជារូបមន្តនៃការខឹតខំប្រឹងប្រែងរបស់មនុស្ស ក្នុងការគ្របបាំងនូវអំពើបាបរបស់គេផ្ទាល់នោះឯង ។ ពួកគេបានយកសាសនា ធ្វើជារូបមន្តដោយការរៀបចំរបស់មនុស្ស ។ គឺមានតែឈាមរបស់កូនចៀមនៃព្រះតែប៉ុណ្ណោះ ដែលអាចដោះអំពើបាបរបស់មនុស្សជាតិចេញបាន ។

**៣. ព្រះទ្រង់បានយាងមកដោយដើរនៅលើផែនដី ។**

ព្រះគម្ពីរលោកុប្បត្តិ ៣:៨

**៤. ការកោតខ្លាចនូវសេចក្តីស្លាប់ខាងឯវិញ្ញាណ**

ព្រះគម្ពីរលោកុប្បត្តិ ៣:១០

វាគឺជាការសំខាន់ក្នុងការយល់ដឹងថា សូម្បីតែបន្ទាប់ពីលោកអ័ដាម និងនាងអេវ៉ា បានធ្វើបាបមក ពួកគេបាននៅតែមានរូបភាពរបស់ព្រះដដែល ។ ទោះជាយ៉ាងណាក៏ដោយ ពួកគេក៏មិនបានមានជីវិតរបស់ព្រះនៅក្នុងពួកគេដែរ ។ គឺពួកគេបានស្លាប់ខាងឯវិញ្ញាណហើយ ។ តាមរយៈអំពើបាប និងការមិនស្តាប់របស់ពួកគេ គឺពួកគេបានប្រគល់នូវអំណាចគ្រប់គ្រងរបស់ពួកគេឱ្យទៅសាតាំងដែរ ។ ដូច្នេះ សាតាំង ត្រឡប់ទៅជាអ្នកគ្រប់គ្រងលើពិភពលោកយើងនេះ ។

**៥. ផែនការរបស់ព្រះមិនដែលប្រែប្រួលឡើយ ។**

ព្រះគម្ពីរលោកុប្បត្តិ ៩:១,២,៦

មនុស្សនៅតែៈ បង្កើតផល ជាពហុគុណ ពាសពេញលើផែនដី បង្ក្រាបដោយការមានអំណាចគ្រប់គ្រងលើ និងគ្រប់គ្រងលើផែនដីដដែល ។ ឥឡូវនេះ ទោះជាយ៉ាងណាក៏ដោយ ការនេះនឹងត្រូវបានទៅជាមានការឈឺចាប់ ដោយការផ្អែមល្ហែមរបស់រោមចិញ្ចើម និងគ្រប់ទាំងជីវិត ដែលមានការរស់នៅដោយមានការកោតញញើតរបស់មនុស្សជាតិនោះ ។

**៦. ការរំឭកឡើងវិញ**

ព្រះទ្រង់បានបង្កើតលោកអ័ដាម និងនាងអេវ៉ាមក គឺឱ្យបានគ្រប់គ្រងលើផែនដីនេះ ។ ទោះជាយ៉ាងណាក៏ដោយ នៅពេលដែលមនុស្សមិនស្តាប់បង្គាប់ដល់ព្រះ និងសាកល្បងធ្វើតាមបំណងចិត្តរបស់គេ គឺបានធ្វើការផ្ទុយទៅនឹងបំណងព្រះហឫទ័យ នោះគេក៏ត្រូវស្លាប់ខាងឯវិញ្ញាណទៅ ។ សាតាំងបានប្លន់យក នូវការប្រទានសិទ្ធិអំណាចរបស់ព្រះ និងអំណាចគ្រប់គ្រងដែលព្រះទ្រង់បានប្រទានឱ្យគេនោះឯង ។ ទោះជាយ៉ាងណាក៏ដោយ ក៏ផែនការរបស់ព្រះមិនដែលប្រែប្រួលឡើយ ។

***បំណងព្រះហឫទ័យរបស់ព្រះ គឺចង់ឱ្យមនុស្សប្រុស-ស្រី មានសិទ្ធិអំណាច និងអំណាចគ្រប់គ្រង ។***
***រីឯបំណងរបស់ សាតាំងវិញ***
***គឺចង់ឱ្យមនុស្សជាតិបះបោរទាស់នឹងព្រះ ។***

***លោកអ័ដាម និងនាងអេវ៉ា***
***បានជ្រើសរើសធ្វើការនោះ គឺពួកគេបានគិតថា***
***នឹងធ្វើការសាកល្បង ។***

***ពួកគេបានធ្វើតាមសាតាំង***
***ដោយនូវការបរបោររបស់គេ ។***
***សាតាំងបានលួចពីលោកអ័ដាម និងនាងអេវ៉ា***
***នូវតួនាទីជាអ្នកគ្រប់គ្រងលើលោកិយនេះ***
***និងធ្វើជាម្ចាស់នៃលោកិយនេះ ។***

## IV. បន្ទាប់ពីមនុស្សបានធ្វើបាប

### ក. បណ្តាសានឹងបានយ៉ាងដូច្នោះ

**១. ចំពោះសត្វពស់** - ព្រះគម្ពីរលោកុប្បត្តិ ៣:១៤
មនុស្សនៅតែមានអំណាចគ្រប់គ្រងលើលោកិយនេះ ។

**២. ចំពោះផែនដី** - ព្រះគម្ពីរលោកុប្បត្តិ ៣:១៨-១៩

**៣. ចំពោះមនុស្ស**

បណ្តាសាត្រូវដាក់ឱ្យមនុស្សប្រុស ត្រូវតែកាប់គាស់ដីដោយនឿយហត់ ដើម្បីឱ្យបានទទួលអាហារយកមកបរិភោគបាន ។

ព្រះគម្ពីរលោកុប្បត្តិ ៣:១៧

**៤. ចំពោះសាតាំង**

នៅពេលភ្លាមៗនោះឯង សាតាំងបានចំណេញនូវជ័យជម្នះ ដ៏ធំបំផុតមកលើមនុស្សជាតិ ព្រះទ្រង់ក៏បានដាក់បណ្តាសាទៅលើវា ។

ព្រះគម្ពីរលោកុប្បត្តិ ៣:១៥ ព្រះទ្រង់មានបន្ទូលទៅសាតាំង ដែលមានសត្វពស់នៅខាងក្នុង ក៏មានបន្ទូលទៅកាន់វាថា ពូជរបស់ស្ត្រីនឹងជាន់ក្បាលវា ។

**៥. ចំពោះស្ត្រី**

មានបណ្តាសាពីរផ្នែកដែលដាក់ទៅឱ្យស្ត្រី ។ នាងនឹងត្រូវបង្កើតកូនដោយមានការឈឺចាប់ ហើយបុរសនឹងត្រូវគ្រប់គ្រងលើនាង ។

ព្រះគម្ពីរលោកុប្បត្តិ ៣:១៦

នៅពេលដែលស្ត្រីម្នាក់ បានទទួលព្រះយេស៊ូវមកធ្វើជាព្រះអង្គសង្គ្រោះផ្ទាល់ខ្លួនរបស់នាង នោះនាងនឹងបានចំណេញនូវមុខនាទី ដែលបានបង្កើតឡើងរបស់នាងនោះឯង ។ ព្រះយេស៊ូវទ្រង់បានត្រឡប់មកជាតួបណ្តាសាជំនួសនាង ។

ព្រះគម្ពីរលោកុប្បត្តិ ៣:១៣

### ខ.សេចក្តីសន្យានៃការប្រោសលោះ

បណ្តាសាគឺបានដាក់ទៅលើសាតាំង គឺជាសេចក្តីសន្យាទីមួយនៃការយាងមករបស់ព្រះមែស៊ីនោះឯង ។ "ពូជ" គឺជាទំនាយរបស់ព្រះយេស៊ូវ ដែលត្រូវមកយកកំណើតនឹងស្ត្រី ។ សាតាំងត្រូវតែនៅពីក្រោមព្រះបាទា របស់ព្រះយេស៊ូវហើយ ។

### គ. រូបមន្តពីអនាគត សត្វដែលត្រូវស្លាប់ជំនួស

ការបង្ហូរឈាមលើកទីមួយត្រូវបានធ្វើសម្រេចហើយ គឺដោយព្រះទ្រង់បានបិទបាំង ដល់លោកអ័ដាមនិងនាងអេវ៉ានោះឯង ។ នេះគឺជាទីសម្គាល់ ឬក៏ជាប្រភេទរបស់ព្រះយេស៊ូវ ដែលទ្រង់ត្រូវបានធ្វើជាយញ្ញបូជា ជាអ្នកលាងបាបសម្រាប់លោកិយទាំងមូល ។

### ឃ. ព្រះទ្រង់មានផែនការ

សូម្បីតែចំណុចនៃសេចក្តីងងឹត នៅក្នុងប្រវត្តិសាស្ត្រនៃការប្រណាំងរបស់មនុស្សជាតិ ព្រះទ្រង់មានផែនការសង្គ្រោះដល់មនុស្សជាតិ ។ ព្រះយេស៊ូវគ្រីស្ទ ជាព្រះរាជបុត្រារបស់

ព្រះ ចំពោះបំណងដ៏មានសេរីភាពផ្ទាល់របស់ព្រះអង្គ នោះនឹងប្រទានជីវិតរបស់ទ្រង់សម្រាប់យើង ។ ដោយនូវការសុគតរបស់ទ្រង់ នោះទ្រង់នឹងធ្វើឱ្យសាតាំងត្រូវបរាជ័យ ។ សាតាំងត្រូវតែប្រឆាំងទប់ទល់នឹងព្រះបាទរបស់ព្រះយេស៊ូវ ប៉ុន្តែ ព្រះយេស៊ូវទ្រង់បានជាន់ក្បាលរបស់សាតាំងហើយ ។ សិទ្ធិអំណាចរបស់សាតាំង នោះនឹងត្រូវជាន់ឈ្លី ហើយសិទ្ធិអំណាចនោះនឹងត្រូវបានកែជាថ្មីដល់មនុស្ស តាមរយៈផែនការដើមរបស់ព្រះនោះឯង ។

## V. ផែនការរបស់សាតាំង

### ក.ការបោកបំភាន់របស់សាតាំង

សាតាំងមិនដែលបានបញ្ឈប់នូវសេចក្តីកំហឹង និងការភ័យខ្លាច ដល់មនុស្សប្រុសស្រី ដែលត្រូវបានបង្កើតមក ឱ្យមានសកម្មភាពដូចជាព្រះនោះ ។ គម្រោងផែនការរបស់វាក្នុងការឆបោកនោះ ក៏មិនដែលបានបញ្ឈប់ដែរ ។ តាមរយៈការឆបោកដល់ពួកអ្នកដឹកនាំខាងវិញ្ញាណ គឺតាមរយៈអាយុកាលដែលត្រូវបានទទួលនូវការប្លន់កំហែង ដោយនូវអំណាចរបស់ពួកគេនោះ ។ ពួកគេក៏បានត្រឡប់មកជាដឹកនាំនៃសេចក្តីងងឹតវិញ ។

***ប៉ុន្តែ ព្រះទ្រង់មិនដែលបោះបង់ចោល នូវផែនការរបស់ទ្រង់សម្រាប់មនុស្សជាតិនោះឡើយ ។ ការបង្ហូរព្រះលោហិត គឺជាការបញ្ជាក់ភស្តុតាង ជាលើកទីមួយរបស់ព្រះ នូវរបៀបដែលទ្រង់ត្រូវធ្វើការ ប្រោសលោះដល់មនុស្សជាតិ ព្រមទាំងគោលបំណង របស់ទ្រង់ ដែលនឹងត្រូវបានសម្រេចនោះ ។ ព្រះទ្រង់នៅតែសព្វព្រះហឫទ័យដើរជាមួយនឹងមនុស្ស ។***

### ខ. កិច្ចការងាររបស់សាតាំង

សាតាំងរៀបចំនូវកងកម្លាំងរបស់វា ចូលទៅក្នុងផែនការធ្វើសង្គ្រាមដ៏ពេញលេញ ។ ការគ្រប់គ្រងលើសេចក្តីងងឹតគឺជាកិច្ចការងារធ្វើទៅដល់ជនជាតិនីមួយៗ មនុស្សប្រុសម្នាក់ៗ មនុស្សស្រីម្នាក់ៗ និងកូនៗ ដើម្បីដាក់ពួកគេឱ្យចូលទៅក្នុងចំណង ។ ព្រះទ្រង់បាននាំមកច្បាប់ក្នុងការបន្ទាបខ្លួន ដើម្បីឱ្យពួកគេអាចបានទទួលនូវការអត់ទោសនូវអំពើបាប និងបានដើរនៅក្នុងការទំនាក់ទំនងជាមួយនឹងព្រះវិញ ។

### គ. លទ្ធផលៈ

មនុស្សដែលបានបង្កើតមក ឱ្យគ្រប់គ្រងលើភពផែនដីនេះគឺៈ សេចក្តីងងឹត និងការសុំទាននៅតាមផ្លូវ ជាប់ចំណងដោយពួកវិញ្ញាណពិការភាព ជាប់ចំណងដោយកងកម្លាំងវិញ្ញាណអាក្រក់ ។ មុខមាត់និងខ្លួនប្រាណដែលត្រូវបានបង្កើតមក ឱ្យបានដូចជាព្រះនោះ គឺលែងបានទទួលដោយមានការកើតនូវជម្ងឺឃ្លង់ដែលគួរឱ្យភ័យខ្លាច ។ មនុស្សប្រុសស្រីដែលបានបង្កើតមកឱ្យបានសោយរាជ្យ និងគ្រប់គ្រងនោះ គឺត្រូវបានទទួលនូវការរស់នៅដោយបរាជ័យទៅវិញ!

## VI. លោកអ័ដាមទីមួយ និងលោកអ័ដាមចុងក្រោយ

### ក. ព្រះទ្រង់បានបញ្ជូនព្រះរាជបុត្រារបស់ទ្រង់

នៅពេលដែលលោកអ័ដាម និងនាងអេវ៉ាបានធ្វើបាបជាដំបូង នោះព្រះទ្រង់ក៏បានសន្យាសថានឹងបញ្ជូនព្រះរាជបុត្រារបស់ទ្រង់ឱ្យមកយកកំណើតនឹងស្ត្រី ដើម្បីជាន់ក្បាលសាតាំង (លោកុប្បត្តិ ៣:១៥) ។ លោកសាវ័កប៉ុលក៏បានប្រាប់យើងពីព្រឹត្តិការនេះ និងពីការទំនាក់ទំនងអំពីការនេះ និងមានសេចក្តី

សន្យាជាដំបូងថា នឹងប្រទានអ្នកប្រោសលោះមកដែរ ។ កាឡាទី ៤:៤-៥

ការប្រកបទាក់ទងរបស់មនុស្សជាមួយនឹងព្រះ និងសិទ្ធិអំណាចរបស់គេ គឺត្រូវតែបានកែជាថ្មីឡើងវិញ ដោយការធ្វើជាយញ្ញបូជាជំនួស ដែលព្រះយេស៊ូវទ្រង់បានសុខចិត្តសុគតនៅលើឈើឆ្កាងនោះឯង ។ ការប្រោសលោះនូវអំពើបាប គឺជាការជាប់ទោស និងទទួលរងនូវលទ្ធផលបណ្តាសាពីក្រឹត្យវិន័យ ដែលមនុស្សត្រូវតែបានកើតជាថ្មីនៅក្នុងក្រុមគ្រួសាររបស់ព្រះ ។ ទ្រង់ត្រូវតែបានទទួលនូវការកើតជាថ្មី ។ ទ្រង់ត្រូវតែកើតជាថ្មីម្តងទៀត ដើម្បីទទួលនូវព្រះវិញ្ញាណរបស់ព្រះនៅក្នុងអង្គទ្រង់នោះ ។

### ខ. លោកអ័ដាមបាននាំមកនូវអំពើបាប

អំពើបាបបានចូលមកក្នុងលោកិយនេះ តាមរយៈការមិនស្តាប់បង្គាប់របស់លោកអ័ដាម ។ ព្រះគម្ពីររ៉ូម ៥:១២ ។

### គ. ព្រះយេស៊ូវទ្រង់បាននាំមកនូវ

**១. សេចក្តីសុចរិត** - ព្រះគម្ពីររ៉ូម ៥:១៩

**២. ដំណឹងល្អ**

បន្ទាប់ពីលោកអ័ដាម និងនាងអេវ៉ាបានធ្វើបាប ពេលដែលពួកគេបានដឹងថា ព្រះទ្រង់កំពុងតែយាងមក នោះពួកគេបានលាក់ខ្លួននៅពីក្រោយគម្ពតព្រៃ ។ ឥឡូវនេះព្រះយេស៊ូវដ៏ជាព្រះរាជបុត្រានៃព្រះ ទ្រង់បានកំពុងតែយាងមក ហើយទេវតាក៏បាននិយាយថា "កុំខ្លាចអី! នេះគឺជាដំណឹងល្អដល់អ្នកហើយ" ។

ព្រះគម្ពីរលូកា ២:១០-១១

**៣. សេចក្តីសុខសាន្តដល់មនុស្ស**

ព្រះគម្ពីរលូកា ២:១៣-១៤

ឱសេចក្តីសន្យាដ៏អស្ចារ្យអ្វីម្ល៉េះហ្ន៎ ដែលត្រូវបានប្រទានឱ្យមកដល់មនុស្ស គឺដែលព្រះគ្រីស្ទទ្រង់បានប្រសូតមកនេះ ។ "សេចក្តីសុខសាន្តនៅផែនដីនៅកណ្តាលមនុស្ស!"

***នោះស្រាប់តែមានពួកពលបរិវារកកកុញពីស្ថានសួគ៌***
***មកនៅជាមួយនឹងទេវតានោះ***
***ក៏ពោលសរសើរដល់ព្រះថា***
***សួស្តីដល់ព្រះនៅស្ថានដ៏ខ្ពស់បំផុត***
***ហើយសេចក្តីសុខសាន្តនៅផែនដីនៅកណ្តាលមនុស្ស***
***ដែលជាទីគាប់ព្រះហឫទ័យដល់ទ្រង់!***

## VI. ព្រះយេស៊ូវទ្រង់បានអនុវត្តភាពជាមនុស្សនៅលើផែនដី

តើព្រះយេស៊ូវទ្រង់បានអនុវត្តដោយនូវសិទ្ធិអំណាច និងអំណាចចេស្តា ក្នុងពេលដែលទ្រង់គង់នៅលើផែនដីនេះក្នុងភាពជាព្រះ ឬក៏ក្នុងជាមនុស្ស ក្នុងការចែករំលែកអំណាចដោយនូវព្រះវិញ្ញាណបរិសុទ្ធនោះ?

### ក. ព្រះយេស៊ូវគឺជាលោកអ័ដាមចុងក្រោយ

លោកសាវ័កប៉ុលបានផ្តល់យោបល់ថា ព្រះយេស៊ូវគឺជាលោកអ័ដាមចុងក្រោយ ។

ព្រះគម្ពីរ ១កូរិនថូស ១៥:៤៥

ព្រះយេស៊ូវគឺជាលោកអ័ដាមចុងក្រោយ ទ្រង់បានដើរ និងបានបំពេញព្រះរាជកិច្ច ដោយនូវសិទ្ធិអំណាចនៅលើផែនដីនេះ សូម្បីតែទ្រង់បានកើតមកជាលោកអ័ដាមទីពីរដើម្បីធ្វើ

ការងារក៏ដោយ ។ វាគឺជារឿងដ៏សំខាន់បំផុតដើម្បីឱ្យបាន យល់នូវការនេះ ពីព្រោះវាត្រូវតែបានសម្រេច ទៅតាមក្រឹត្យវិន័យជាលោកអ័ដាមចុងក្រោយ ដែលទ្រង់អាចនាំមកយើងនូវសេរីភាពពីក្រឹត្យវិន័យនោះ ។ មានតែការមកកើតជាមនុស្សទេ ដែលទ្រង់អាចបានត្រឡប់មកជាព្រះអង្គសង្គ្រោះនោះ ។ វាគឺជាការចាំបាច់បំផុត ដែលទ្រង់បានធ្វើឱ្យសាតាំងត្រូវទទួលនូវការបរាជ័យ គឺទ្រង់មកក្នុងភាពជាមនុស្សឱ្យបានទទួលនូវជ័យជម្នះ និងទទួលយកនូវសិទ្ធិអំណាចត្រឡប់មកវិញ ដែលសាតាំងបានលួចយកពីលោកអ័ដាមមុនដំបូងនោះ ។ តាំងពីព្រះយេស៊ូវទ្រង់បានត្រឡប់មកជាមនុស្សពេញលេញ គឺជាលោកអ័ដាមដ៏ពិតនោះ ទ្រង់ក៏បានទទួលនូវសិទ្ធិអំណាចដែលបានប្រទានឱ្យដល់លោកអ័ដាមនោះ ។ នៅពេលដែលព្រះវិញ្ញាណបរិសុទ្ធបានយាងមកសន្ថិតលើទ្រង់ នោះទ្រង់ក៏បានទទួលនូវអំណាចចេស្តារបស់ព្រះ គង់នៅក្នុងព្រះអង្គ ។

## ខ. ការជ្រមុជទឹករបស់ព្រះយេស៊ូវ

### ១. ព្រះវិញ្ញាណបរិសុទ្ធបានយាងមកសន្ថិតលើព្រះអង្គ

លោកយ៉ូហានបាប់ទីស្ទ បានឃើញព្រះវិញ្ញាណរបស់ព្រះ យាងមកសន្ថិតលើព្រះយេស៊ូវ នោះគឺជាព្រឹត្តិការណ៍ដ៏សំខាន់បំផុត ដែលបានកត់ត្រាទុកនៅក្នុងដំណឹងល្អទាំងបួន( ម៉ាកុស ១:១០ លូកា ៣:២២ យ៉ូហាន ១:៣២) ។

ព្រះគម្ពីរម៉ាថាយ ៣:១៦

### ២. ការសម្តែងនូវការធ្វើការអស្ចារ្យ

ព្រះយេស៊ូវទ្រង់មិនបានធ្វើការអស្ចារ្យ តាមរយៈពេល ដែលទ្រង់មានព្រះជន្ម៣០ព្រះវស្សានោះទេ ប៉ុន្តែ នៅពេលដែលទ្រង់បានចាប់ផ្តើមបំពេញព្រះរាជកិច្ចជាសាធារណៈទេ គឺទ្រង់បានបំពេញ នៅពេលដែលព្រះវិញ្ញាណបរិសុទ្ធ បានយាងមកស្ថិតលើព្រះអង្គវិញ ។ បន្ទាប់មកទើបទ្រង់បានបំពេញព្រះរាជកិច្ច ដោយនូវអំណាចចេស្តានៃព្រះវិញ្ញាណបរិសុទ្ធវិញ ហើយព្រះយេស៊ូវទ្រង់ក៏បានចាប់ផ្តើមបំពេញព្រះរាជកិច្ច ក្នុងការធ្វើការអស្ចារ្យនោះ ។ សិទ្ធិអំណាចនៅក្នុងការអនុវត្តន៍ ក្នុងភាពជាមនុស្សពេញលក្ខណៈ ដោយនូវព្រះវិញ្ញាណរបស់ព្រះវិញ ហើយក៏មានអំណាចចេស្តា ទទួលនូវជ័យជម្នះផ្សេងៗគ្នាទៅ!

## គ. ព្រះយេស៊ូវទ្រង់បានបោះបង់សិទ្ធិជាព្រះ

ចំពោះព្រះអង្គទ្រង់គឺមានភាពទទេ ។

លោកសាវ័កប៉ុលបានផ្តល់ឱ្យយើង នូវការយល់ដឹងផ្នែកខាងក្នុងចិត្តរបស់ព្រះគ្រីស្ទ នៅពេលដែលទ្រង់បានយាងមកគង់នៅលើផែនដីនេះ ។ លោកបានសរសេរថែងទុកមកថា ព្រះយេស៊ូវទ្រង់បានលះបង់ក្នុងភាពជាព្រះទាំងអស់របស់ទ្រង់ ព្រះគម្ពីរអេភេសូរ ២:៥-៨ ។

### ១. ព្រះយេស៊ូវទ្រង់មានបំណង:

ព្រះយេស៊ូវទ្រង់មានធម្មជាតិជាព្រះ តែទ្រង់មិនបានទុកស្មើនឹងភាពជាព្រះនោះឡើយ គឺទ្រង់បានលះបង់នូវ សិទ្ធិជាព្រះដ៏ខ្ពស់បំផុត មកដាក់មុខងារនៅលើផែនដី ធ្វើជាមនុស្សមនុស្សវិញ ។ ទ្រង់បានសុខចិត្តមកធ្វើ ជាមនុស្សក្នុងភាពជាបាវបម្រើវិញ ។ ទ្រង់បានសុខចិត្តបន្ទាបអង្គទ្រង់ និងបានចុះចូលស្តាប់

បង្គាប់រហូតបានទទួលនូវមរណា ។ ទ្រង់បានយាងមកលើផែនដីជារបស់ផងព្រះអង្គ មកយកកំណើតជាមនុស្ស ហើយអំណាចចេស្តារបស់របស់ផងទ្រង់នៅលើផែនដីនេះ គឺតាមរយៈព្រះវិញ្ញាណបរិសុទ្ធតែប៉ុណ្ណោះ ។

ទ្រង់មិនបានបង្កើតនូវកិត្តិយស ដោយអង្គទ្រង់នោះទេ គឺទ្រង់បានចាប់យកភាពជាបាវបម្រើវិញ គឺទ្រង់បានមកដោយមានរូបភាពដូចជាមនុស្ស ក៏បានបន្ទាបអង្គទ្រង់ ត្រឡប់មកជាអ្នកស្តាប់បង្គាប់នឹងទទួលសុគតវិញ ។

## ២. ហេតុអ្វីបានជាការសំខាន់យ៉ាងដូច្នេះទៅវិញ?

លោកអ័ដាមគឺជាមនុស្សដំបូង ដែលមិនបានស្តាប់បង្គាប់ដល់ព្រះ ហើយក៏បានប្រគល់សិទ្ធិអំណាចរបស់គាត់ឱ្យទៅសាតាំងវិញ ។ ព្រះយេស៊ូវទ្រង់គឺជាលោកអ័ដាមចុងក្រោយ គឺទ្រង់ត្រូវបានធ្វើគ្រប់ការទាំងអស់នៅលើផែនដីនេះជាមនុស្ស ដែលបានត្រូវទទួលអំណាចចេស្តា ដោយព្រះវិញ្ញាណរបស់ព្រះ ។ ទ្រង់បានត្រឡប់មកជាមនុស្សពេញលក្ខណៈ ក៏បានអនុវត្តការងារនៅលើផែនដីនេះ ជាលោកអ័ដាមដែលត្រូវបានបង្កើតមកឱ្យធ្វើការងារនោះឯង ។

## ឃ. ទ្រង់គឺជាកូនមនុស្ស

នៅពេលដែលព្រះយេស៊ូវ ទ្រង់បានយាងមកផែនដីនេះសិទ្ធិអំណាចដែលទ្រង់បានអនុវត្តនោះ គឺក្នុងនាមជាកូនមនុស្សនៅក្នុងការសម្តែងព្រះបន្ទូលជាបន្តបន្ទាប់ គឺដែលលោកយ៉ូហានបានប្រើនៅក្នុងជម្រើសពាក្យនីមួយៗ យ៉ាងច្បាស់លាស់ថា "ព្រះរាជបុត្រារបស់ព្រះ" "កូនមនុស្ស" ។ ព្រះគម្ពីរយ៉ូហាន ៥:២៥-២៧ ។

មនុស្សស្លាប់នឹងឮសំឡេងព្រះរាជបុត្រានៃព្រះ ហើយអស់អ្នកណាដែលឮនឹងបានរស់វិញ ។ នៅខាងក្រៅផែនដីនេះ ព្រះយេស៊ូវទ្រង់បានអនុវត្ត ជាផ្នែកនៃព្រះត្រៃឯក ។ នៅលើផែនដីនេះវិញ ព្រះយេស៊ូវទ្រង់បានដើរដោយនូវសិទ្ធិអំណាចពីព្រោះទ្រង់គឺជាកូនមនុស្ស។ មនុស្សដែលត្រូវបានបង្កើតមកគឺត្រូវដើរដោយមានសិទ្ធិអំណាច និងមានអំណាចគ្រប់គ្រង ។ គឺជាមនុស្សជាតិរបស់ព្រះយេស៊ូវ ដែលមានសិទ្ធិអំណាចនោះឯង ។ ដោយព្រោះតែទ្រង់គឺជាកូនមនុស្ស គឺជាលោកអ័ដាមចុងក្រោយទ្រង់មិនមែនជាព្រះរាជបុត្រានៃព្រះឡើយ។ គ្រប់ការទាំងអស់ដែលព្រះយេស៊ូវទ្រង់បានធ្វើ គឺដោយនូវអំណាចគ្រប់គ្រង និងដោយនូវសិទ្ធិអំណាចរបស់លោកអ័ដាមចុងក្រោយ ដែលបន្ទាប់មកទ្រង់ត្រូវបានទទួលនូវការកែជាថ្មី គឺរូបកាយរបស់ព្រះអង្គ ត្រូវបានបង្កើតឡើងជាថ្មីនោះឯង ។

## ង. ប្រសិបើព្រះយេស៊ូវទ្រង់បានបំពេញការនោះ យើងក៏អាចធ្វើការនោះបានដែរ!

ព្រះយេស៊ូវទ្រង់បានធ្វើត្រឹមតែអ្វី ដែលមនុស្សដែលត្រូវបានបង្កើតមកធ្វើការនៅលើផែនដីនោះដែរ ។ ទ្រង់អាចធ្វើការបំផ្លាស់បំប្រែបាន ដោយសារតែអំណាចចេស្តានៃព្រះវិញ្ញាណបរិសុទ្ធប៉ុណ្ណោះ គឺមិនអាចធ្វើបានដោយនូវអំណាចនៃព្រះរាជបុត្រារបស់ព្រះបានឡើយ! នេះគឺជាការសំខាន់បំផុតចំពោះយើង! ប្រសិនបើព្រះយេស៊ូវទ្រង់បានអនុវត្តព្រះរាជកិច្ចជាមនុស្សនៅលើផែនដីនេះ បន្ទាប់មកយើងអាចធ្វើការដូចជាទ្រង់បានធ្វើដែរ ។ យើងក៏មានដោយនូវអំណាចចេស្តាសិទ្ធិអំណាច និងសិទ្ធិដូចគ្នាគ្រប់បែបយ៉ាង ដែលព្រះយេស៊ូវ

ទ្រង់បានធ្វើ នៅពេលដែលទ្រង់បានគង់នៅលើផែនដីជាមនុស្សផងដែរ ។ ព្រះយេស៊ូវទ្រង់បានធ្វើ នៅពេលដែលទ្រង់បានគង់ជាមនុស្សនៅលើផែនដីនេះ ។

## VII. ការប្រឈមមុខនឹងសេចក្ដីល្បួងក្នុងភាពជាមនុស្ស

### ក.ទ្រង់ត្រូវល្បួងដូចជាយើងត្រូវល្បួងដែរ

ព្រះទ្រង់បានប្រទានឱ្យលោកអ័ដាម និងនាងអេវ៉ានូវបំណង ការជ្រើសរើស ឆន្ទៈដោយសេរី ។ រីឯព្រះយេស៊ូវទ្រង់ក៏មានឆន្ទៈដូចគ្នានេះដែរ ។ ដើម្បីឱ្យបានជាលោកអ័ដាមចុងក្រោយពេញលក្ខណៈ នោះព្រះយេស៊ូវទ្រង់ត្រូវតែរងទុក្ខនឹងសេចក្ដីល្បួងយ៉ាងដូច្នោះ ។

### ខ. លោកអ័ដាមនិងនាងអេវ៉ា ត្រូវបានទទួលនូវសេចក្ដីល្បួងទាំងបីចំណុចនេះ

១. **ខាងផ្នែករូបកាយ** - នាងអេវ៉ាបានមើលឃើញថាផ្លែឈើនោះ គួរតែជាចំណីអាហារដែលគួរនឹងទទួលបរិភោគបាន ។

២. **ខាងផ្នែកព្រលឹង** - សាតាំងបានសន្យាថា នាងនឹងមានប្រាជ្ញា ចំណេះដឹងចេញពីអារក្សនោះមក ។

៣. **ខាងផ្នែកវិញ្ញាណ** នៅទីបំផុត សាតាំងក៏បានសន្យាជាមួយនឹងនាងថា នាងនឹងបានដូចជាព្រះដែរ ។

### គ. ព្រះយេស៊ូវទ្រង់បានត្រូវសេចក្ដីល្បួង នៅក្នុងចំណុចទាំងបីនេះផងដែរ ។

➢ សេចក្ដីល្បួងទីមួយ ខាងផ្នែករូបកាយ

ព្រះយេស៊ូវទ្រង់បានគង់នៅក្នុងទីរហោស្ថាន អស់រយៈពេល៤០ថ្ងៃ ។ សាតាំងក៏បានព្យាយាមក្នុងពេលដែលទ្រង់មានសេចក្ដីកម្សោយខាងឯរូបកាយ គឺវាមកល្បួងព្រះយេស៊ូវឱ្យទ្រង់ប្រើប្រាស់នូវសិទ្ធិអំណាចរបស់ទ្រង់ ជាព្រះរាជបុត្រារបស់ព្រះ ឱ្យទ្រង់បានចម្អែតតាមសេចក្ដីត្រូវការខាងឯរូបកាយរបស់មនុស្សជាតិនោះ ។ ប៉ុន្ដែ ព្រះយេស៊ូវទ្រង់មិនបានយកភាពជាព្រះមកប្រើទេ គឺទ្រង់បានទុកភាពជាព្រះ ឱ្យនៅដោយឡែកវិញ ក្នុងពេលដែលទ្រង់បានយាងមកគង់លើផែនដីនេះ ក្នុងភាពជាកូនមនុស្សនោះ ។

#### ១. សេចក្ដីត្រូវចម្អែតខាងឯរូបកាយមនុស្ស

ព្រះគម្ពីរម៉ាថាយ ៤:១-៣

នៅពេលដែលសេចក្ដីល្បួង បានចូលមកដល់ទ្រង់ នោះវាក៏និយាយថា "បើអ្នកជាព្រះរាជបុត្រានៃព្រះមែន ចូរធ្វើការបញ្ជាក់ពីខ្លួនអ្នកផ្ទាល់ ចូរយកសិទ្ធិជាព្រះរបស់អ្នកត្រឡប់ទៅវិញទៅ។ ប្រសិនបើអ្នកពិតជាព្រះរាជបុត្រារបស់ព្រះមែន ចូរបញ្ជាឱ្យថ្មនេះត្រឡប់ទៅជានំប៉័ងទៅ" ។

ប្រសិនបើព្រះយេស៊ូវទ្រង់បានធ្វើថ្ម ឱ្យក្លាយទៅជានំប៉័ង នោះទ្រង់នឹងមិនបានអនុវត្តក្នុងភាពជាមនុស្សនេះបានទេ ។ ទ្រង់នឹងបានប្រើប្រាស់ក្នុងភាពជាព្រះហើយ ។ ប្រសិនបើទ្រង់បានធ្វើយ៉ាងដូច្នោះ នោះសាតាំងនឹងធ្វើឱ្យទ្រង់ បានទទួលនូវការបរាជ័យទាំងលោកអ័ដាមទីមួយ និងលោកអ័ដាមចុងក្រោយនោះបានហើយ ។

#### ២. ចម្លើយរបស់ព្រះយេស៊ូវ:

ព្រះយេស៊ូវទ្រង់បានឆ្លើយទៅសាតាំង ដោយនូវការកំណត់ទុកមកនៃព្រះបន្ទូលរបស់ព្រះ ។

ព្រះគម្ពីរម៉ាថាយ ៤:៤

ចូរកត់ចំណាំថា ព្រះយេស៊ូវទ្រង់បានបញ្ជាក់នូវភាពអង្គទ្រង់ជាមនុស្ស ។

## ឃ. សេចក្តីល្បួងទីពីរខាងផ្នែកព្រលឹង

ព្រះគម្ពីរម៉ាថាយ ៤:៥

សេចក្តីល្បួងទីពីរគឺមានតាមរយៈព្រលឹង ។ សាតាំងបានល្បួងព្រះយេស៊ូវ ទៅតាមហេតុផលដែលនាំឱ្យប្រឆាំងទាស់នឹងបំណងព្រះហឫទ័យនៃព្រះ សម្រាប់ជីវិតរបស់ព្រះអង្គ និងសកម្មភាពរបស់ទ្រង់នៅក្នុងផ្នែកអារម្មណ៍របស់ទ្រង់ ។

### ១. ការបញ្ជាក់ពីអង្គទ្រង់

ព្រះគម្ពីរម៉ាថាយ ៤:៦

នេះគឺជាការបន្តនូវសេចក្តីល្បួង ដែលមានមូលដ្ឋានដូចគ្នាថា "ប្រសិនបើអ្នកជាព្រះរាជបុត្រារបស់ព្រះមែន..." សាតាំងបានដឹងថា ទ្រង់គឺជាព្រះរាជបុត្រារបស់ព្រះ ។ ជីវិតរបស់ព្រះយេស៊ូវនៅលើផែនដីនេះ គឺត្រូវបានរស់នៅក្នុងភាពជាកូនមនុស្ស គឺជាលោកអ័ដាមចុងក្រោយ ។

### ២. ចម្លើយរបស់ព្រះយេស៊ូវ

ព្រះយេស៊ូវ ទ្រង់បានធ្វើឱ្យសាតាំងចុះចាញ់ ដោយទ្រង់មានបន្ទូលដ៏ត្រឹមត្រូវ តាមព្រះបន្ទូលរបស់ព្រះ ។ ព្រះយេស៊ូវទ្រង់បានជ្រាបថា ទ្រង់ពិតជាព្រះអម្ចាស់មែនហើយ រីឯសាតាំងក៏បានដឹងយ៉ាងដូច្នោះដែរ ។

ព្រះគម្ពីរម៉ាថាយ ៤:៧

## ង. សេចក្តីល្បួងទីបី ខាងវិញ្ញាណ

នៅក្នុងសេចក្តីល្បួងទីបីនេះ សាតាំងបានឱ្យនគរនៅលើលោកិយនេះដល់ព្រះយេស៊ូវ ។ តើនោះគឺមិនមែនជាព្រះរាជបំណងដែលព្រះយេស៊ូវទ្រង់យាងមកផែនដីទេឬអី? តើព្រះយេស៊ូវទ្រង់មិនមែនយាងមកផែនដី ដើម្បីដណ្តើមយកជ័យជម្នះពីសាតាំងមកវិញទេឬអី?

### ១. បានមកជាព្រះនៃពិភពលោកនេះ

ព្រះគម្ពីរម៉ាថាយ ៤:៨-៩

សាតាំងមានសិទ្ធិនឹងឱ្យលោកិយនេះ ដល់ព្រះយេស៊ូវ ។ សាតាំងទទួលនិងប្លន់យកសិទ្ធិអំណាចនេះពីលោកអ័ដាមមក ដើម្បីឱ្យបានគ្រប់គ្រងលើផែនដីនេះ ។ ប៉ុន្តែ ព្រះយេស៊ូវទ្រង់មិនបានចាប់អារម្មណ៍ ដើម្បីយកផែនដីនេះ ចេញពីសាតាំងត្រឡប់ទៅវិញ ដោយការមិនស្តាប់បង្គាប់ តាមបំណងព្រះហឫទ័យនៃព្រះវរបិតានោះទេ ។

### ២. ចម្លើយរបស់ព្រះយេស៊ូវ

ព្រះយេស៊ូវទ្រង់មិនបានចូលមកពិភាក្សា ជាមួយនឹងសាតាំងនោះទេ ។ គឺទ្រង់មិនបានមកឈ្លោះប្រកែកជាមួយនឹងវា ដែលបានគ្រប់គ្រងលើពិភពលោកនេះនោះទេ ។ ព្រះយេស៊ូវទ្រង់បានមានបន្ទូលដេញវា ឱ្យចេញទៅតែប៉ុណ្ណោះ ។ គឺទ្រង់មានបន្ទូលតាមព្រះបន្ទូលរបស់ព្រះ ដែលបានចែងជាបន្តទៀតនៅក្នុង ម៉ាថាយ ៤:១០ ។

ព្រះយេស៊ូវទ្រង់បានឈ្នះ នៅក្នុងសមរភូមិ ដោយទ្រង់បានបញ្ចេញនូវព្រះបន្ទូល ។ វាគឺជាការរស់នៅ និងមានពេញដោយអំណាចចេស្តា ។ ចូរធ្វើការប្រឆាំងទាស់នឹងអារក្សចុះ នោះវានឹងចាកចេញពីអ្នករាល់គ្នាទៅ ។ វាបានចែងទុកមកដូច្នេះឯង

វាបានចែងទុកមកដូច្នេះហើយ វាគឺបានចែងទុកមកបែបនេះ ។ នោះគឺជាមធ្យោបាយតែមួយគត់ ដែលទ្រង់ឆ្លើយទៅកាន់សាតាំងវិញ ។ លោកអ្នកមិនដែលធ្លាប់បានទទួលនូវជ័យជម្នះ ក្នុងការធ្វើការទាក់ទងជាមួយនឹងសាតាំងនោះទេ ។ ព្រះយេស៊ូវទ្រង់មានជ័យជម្នះ នៅគ្រប់ទាំងសមរភូមិ ។ យើងត្រូវតែធ្វើតាមគំរូរបស់ព្រះយេស៊ូវ និងនិយាយតាមព្រះបន្ទូល ។

## ក្រុមពិភាក្សា

១. ហេតុអ្វីបានជាព្រះយេស៊ូវទ្រង់បានបញ្ជូនមក ឱ្យធ្វើជា "លោកអ័ដាមចុងក្រោយ"?
២. ចូរធ្វើការពិភាក្សាបន្ថែមទៀតទៅលើ "អំណាចចេស្តានៃជ័ជម្នះទាំងពីរ" ឱ្យបានជ្រៅជាងនេះទៀតៈ សិទ្ធិអំណាចក្នុងការអនុវត្តន៍ នូវភាពជាមនុស្សពេញលេញដោយនូវព្រះវិញ្ញាណរបស់ព្រះ ។ តើព័តិមាននេះនឹងមានការប៉ះទង្គិចដល់ជីវិត និងការបំពេញការងាររបស់លោកអ្នក ដល់អ្នកដទៃទៀតដោយរបៀបណា?
៣. ហេតុអ្វីបានជាសាតាំងមានសិទ្ធិនឹងឱ្យដល់ព្រះយេស៊ូវនូវនគរទាំងអស់ដែលមាននៅលើពិភពលោកនេះ?

## ការសិក្សាដោយខ្លួនឯង

១. ចាប់តាំងពីសាតាំងបានដឹងពីគ្រប់ការទាំងអស់ នូវការសម្រេចព្រះទ័យមុនដំបូង ដែលត្រូវបានប្រគល់ឱ្យទៅមនុស្ស គឺជាការរំពួករបស់លោកអ្នក ចំពោះសាតាំងដែលត្រូវតែមានការផ្លាស់ប្តូរ? ប្រសិនបើដូច្នោះមែន តើធ្វើដោយរបៀបណា?
២. ការស្គាល់នូវតាក់ទិចរបស់សាតាំង នោះគឺមិនមែនបានន័យថា មានការផ្លាស់ប្តូរតាំងពីវាបានទទួលពីលោកអ័ដាម និងនាងអេវ៉ានោះទេ តើបានទទួលអ្វីពីពួកគេនោះ?
៣. តើសាតាំងបាននៅក្រោមព្រះបាទព្រះយេស៊ូវ ដោយរបៀបណា?

# សិទ្ធិអំណាចរបស់អ្នកជឿ

## *មេរៀនទី ៣: ព្រះយេស៊ូវទ្រង់ជាគំរូរបស់យើង*

### I. ការទប់ទល់នឹងសេចក្ដីល្បួង

### ក. ព្រះរាជបុត្រារបស់ព្រះ កូនមនុស្ស

ប្រសិនបើព្រះយេស៊ូវទ្រង់បានបំពេញ សកម្មភាពជាព្រះរាជបុត្រារបស់ព្រះ នៅពេលដែលសាតាំងបានល្បួងដល់ទ្រង់ឱ្យធ្វើការនោះ ទ្រង់នឹងត្រូវបានទទួលនូវការបោះបង់ចោលសិទ្ធិរបស់ទ្រង់ជាកូនមនុស្សហើយ ។ ទ្រង់នឹងមិនបានទទួលនូវគុណសម្បត្តិ ធ្វើជាអ្នកជំនួសក្នុងការប្រទានមកធ្វើជាអ្នកប្រោសលោះរបស់មនុស្សជាតិនោះតទៅទៀតទេ ។ សូម្បីតែព្រះយេស៊ូវទ្រង់បានសុគតនៅលើឈើឆ្កាងក៏ដោយ សាតាំងវាធ្វើតាមរយៈមនុស្ស វាបានចំអកឱ្យព្រះយេស៊ូវដោយពាក្យសម្ដីដដែលៗ ។

ព្រះគម្ពីរម៉ាថាយ ២៧:៤០

ជានិច្ចកាល សាតាំងនឹងឱ្យយើងនូវវត្ថុគ្រប់យ៉ាងដែលព្រះទ្រង់បានសន្យាជាមួយនឹងយើង ។ គ្រប់ទាំងអស់ដែលយើងត្រូវតែធ្វើ នោះគឺជាការសម្រុះសម្រួល នៅក្នុងតំបន់ខ្លះៗ ។ រូបមន្តនៃជ័យជម្នះរបស់យើង ទៅលើយុទ្ធសាស្ត្ររបស់វា គឺយើងត្រូវតែយល់ដឹង ហើយនិយាយពីព្រះបន្ទូលរបស់ព្រះ ។

### ខ.ព្រះយេស៊ូវទ្រង់យល់ដឹងពីសេចក្ដីល្បួង

នៅពេលដែលសាច់រឿងនៃសេចក្ដីល្បួង ដល់ព្រះយេស៊ូវគឺត្រូវបានទទួលនូវការប្រកបនៅក្នុងព្រះគម្ពីរម៉ាថាយ នោះយើងត្រូវបានទទួលនូវការប្រទាននូវភព្វសំណាង ក្នុងការសិក្សាពីរបៀបដែលសាតាំងត្រូវទទួលនូវភាពបរាជ័យ នៅក្នុងចំណុចនេះ ។ យើងក៏មានជម្រើសដោយសេរីដែរ ។ យើងក៏នឹងត្រូវទទួលនូវសេចក្ដីល្បួងដែរ ប៉ុន្តែ នៅពេលដែលព្រះយេស៊ូវទ្រង់បានដើរដោយមានជ័យជម្នះ ដូច្នេះ យើងក៏មានជ័យជម្នះនោះដែរ! ដោយសារតែព្រះយេស៊ូវទ្រង់បានរងទុក្ខដោយការទទួលនូវសេចក្ដីល្បួង នោះទ្រង់ក៏មានលទ្ធភាពដើម្បីជួយដល់អស់អ្នក ដែលបានទទួលរងនូវសេចក្ដីល្បួងនោះដែរ ។

ព្រះគម្ពីរហេព្រើរ ២:១៨

### គ. ព្រះយេស៊ូវទ្រង់ត្រូវសេចក្ដីល្បួងដូចជាយើងដែរ

យើងអាចមានការពិសោធន៍ ក្នុងការបញ្ជាក់យ៉ាងអង់អាចដោយការដឹងថា ព្រះយេស៊ូវទ្រង់បានត្រូវទទួលនូវសេចក្ដីល្បួងពីគ្រប់យ៉ាងទាំងអស់ ដែលយើងអាចនឹងត្រូវបានទទួលនោះដែរ ។ ពេលដែលទ្រង់មិនបានទទួលផលក្នុងសេចក្ដីល្បួងនោះទេ យើងក៏មិនអាចទៅឯព្រះនិងបានទទួលនូវជំនួយជាអធិធម្មជាតិរបស់ទ្រង់ ដើម្បីឈរទប់ទល់នឹងសេចក្ដីល្បួងនោះបានដែរ ។

ព្រះគម្ពីរហេព្រើរ ៤:១៤-១៦

### ឃ. គ្រប់សេចក្ដីល្បួងទាំងអស់គឺមានជាធម្មតា

ព្រះគម្ពីរ ១កូរិនថូស ១០:១៣

យុទ្ធសាស្ត្រមួយ បណ្ដាយុទ្ធសាស្ត្រទាំងឡាយរបស់សាតាំង គឺត្រូវតែបង្កើតនូវអារម្មណ៍របស់យើង ដែលធ្វើឱ្យយើងមានការលំបាក សេចក្ដីល្បួងរបស់យើងនោះគឺមានតែមួយ ឬមានការលំបាកជាជាងអ្វីដែលជាការរងទុក្ខដទៃទៀត។ ប៉ុន្តែ គ្រប់សេចក្ដីល្បួងទាំងអស់នោះគឺជាការធម្មតា ហើយ

ព្រះទ្រង់ក៏បានប្រទានឱ្យយើងនូវមធ្យោបាយ សម្រាប់គេចចេញពី ឬឈរឱ្យបានមាំមួនបាន ។

**ង. ការដើរតាមគំរូរបស់ព្រះយេស៊ូវ**

ព្រះយេស៊ូវទ្រង់ជាគំរូរបស់យើង ។ គ្រាន់តែព្រះយេស៊ូវទ្រង់បានឆ្លើយទៅនឹងសាតាំងដោយការប្រើ នូវព្រះបន្ទូលនៃព្រះ នោះយើងក៏ត្រូវតែធ្វើយ៉ាងដូច្នោះដែរ ។ នៅពេលដែលសាតាំងបានចូលមកឯព្រះយេស៊ូវ នោះព្រះយេស៊ូវទ្រង់មិនបាន:

**១. ប្រកែកជាមួយសាតាំង ។**

**២. គ្មានហេតុផលជាមួយនឹងសាតាំង ។**

**៣. ទទួលការប្រឹក្សា ពីការធ្វើតាមមធ្យោបាយនៃសាតាំង**

ព្រះយេស៊ូវទ្រង់បានកំណត់ក្នុងការថែងមក នូវព្រះបន្ទូលរបស់ព្រះ ។ ព្រះគម្ពីរម៉ាថាយ ៤:៤ ។

នេះគឺជារបៀបដែលសាតាំងត្រូវទទួលនូវការបរាជ័យ ។ ព្រះបន្ទូលរបស់ព្រះត្រូវតែបង្ហូរចេញមក តាមរយៈមាត់របស់យើង ។

នៅពេលដែលជម្ងឺព្យាយាមនឹងចូលមក ក្នុងរូបកាយរបស់យើង នោះយើងអាចនិយាយថា "មានសេចក្តីចែងទុកមកថា ដោយនូវស្នាមជាំរបស់ទ្រង់ នោះខ្ញុំនឹងបានជា" (១ពេត្រុស ២:២៤) ។ នៅពេលដែលភាពទ័លក្រព្យាយាមចូលមកទាស់ទទឹងនឹងផ្នែកថវិកា នោះយើងអាចនិយាយថា "មានសេចក្តីចែងទុកមកថា ព្រះនៃខ្ញុំទ្រង់នឹងបំពេញគ្រប់អស់ដែលខ្ញុំត្រូវការតាមភោគសម្បត្តិនៃទ្រង់ដ៏ឧត្តម ក្នុងព្រះគ្រីស្ទយេស៊ូវ" (ភីលីព ៤:១៩) ។ នៅពេលដែលសាតាំងបានព្យាយាមនាំកូនចៅរបស់យើង ឱ្យដើរតាមផ្លូវខុស នោះយើងអាចនិយាយថា "មានសេចក្តីចែងទុកមកដូច្នេះ កូនចៅរបស់ខ្ញុំទាំងអស់ ត្រូវបានទទួលនូវការបង្រៀនមកពីព្រះអម្ចាស់..." (អេសាយ ៥៤:១៣) ។

***និយាយពីភាពរឹងមាំ មិននិយាយពីបញ្ហា ។***

***និយាយពីចម្លើយ មិននិយាយពីសេចក្តីត្រូវការ ។***

***និយាយនិងជឿលើព្រះបន្ទូលព្រះ នោះសាតាំងនឹងមិន អាចៈ មកបង្អាប់ មកបំពេញ មកបំពេញចិត្ត ទទួលនូវការបរាជ័យហើយ!***

***ហើយលោកអ្នកនឹងត្រូវបានទទួលនូវជ័យជម្នះ!***

**II. ផែនការរបស់ព្រះសម្រាប់ពួកអ្នកជឿ**

ព្រះយេស៊ូវទ្រង់ជាលោកអ័ដាមចុងក្រោយ

វាគឺជាការសំខាន់ក្នុងការយល់ដឹងនូវសិទ្ធិអំណាច នៅក្នុងកន្លែងដែលព្រះយេស៊ូវទ្រង់បានដើរ ។ នេះគឺជាសិទ្ធិអំណាចដែលព្រះទ្រង់បានប្រទានមកឱ្យលោកអ័ដាមដំបូង បន្ទាប់មកយើងក៏ត្រូវតែបានដើរនៅក្នុងសិទ្ធិអំណាចដដែលនោះ នៅពេលដែលទ្រង់បានប្រោសលោះ ដល់មនុស្សប្រុសស្រីនៅសម័យសព្វថ្ងៃនេះ ។

ព្រះគម្ពីរលូកា ១០:១៩

នៅពេលដែលយើងបានកើតជាថ្មី នៅក្នុងព្រះយេស៊ូវ នោះយើងបានត្រឡប់មកជាមនុស្សប្រុសស្រី ដែលយើងត្រូវបានបង្កើតមកនៅក្នុងផែនការរបស់ព្រះនោះ ។ មានតែយើងបានអាននូវដំណឹងល្អ នោះយើងនឹងមើលឃើញព្រះយេស៊ូវដែលកំពុងតែដើរជាមនុស្សពេញលក្ខណៈ តើយើងអាចយល់

បានពីគំរូរបស់ព្រះ សម្រាប់ការរស់នៅ និងការដើររបស់យើង ដោយនូវសិទ្ធិអំណាច និងអំណាចគ្រប់គ្រងដ៏រឹងមាំ ទៅលើអំណាចទាំងអស់របស់ខ្មាំងសត្រូវ ។ គ្មានអ្វីណាមួយ ដែលអាចធ្វើឱ្យលោកអ្នកមានការឈឺចាប់បានឡើយ ។ យើងអាចដើរដោយនូវសិទ្ធិអំណាចនោះជារៀងរាល់ថ្ងៃ ដោយគ្មានការភ័យខ្លាចចំពោះសាតាំងនោះបានឡើយ ។

## III. លោកលូកាប្រាប់យើងអំពីសិទ្ធិអំណាចរបស់ព្រះយេស៊ូវ

### ក. ព្រះរាជសារទីមួយ

១. ដោយនូវអំណាចចេស្តានៃព្រះវិញ្ញាណបរិសុទ្ធ

ព្រះយេស៊ូវទ្រង់បានអនុវត្តការងារ ក្នុងភាពជាមនុស្សនៅលើផែនដីនេះ ។ ទ្រង់មានបំណងយ៉ាងពេញលេញថា នឹងលះបង់សិទ្ធិជាព្រះរបស់ផងទ្រង់មក ធ្វើការដោយព្រះអង្គទ្រង់ក្នុងភាពទទេ ។ ទ្រង់បានរងទុក្ខក្នុងសេចក្តីល្បួងរបស់មនុស្ស ។ ទ្រង់ក៏មានជ័យជម្នះលើសាតាំង នៅក្នុងភាពជាមនុស្សនោះ ។ ទ្រង់គឺជាមនុស្សជាតិដ៏ពិត ។ ព្រះយេស៊ូវគឺជាមួយអង្គ ដែលមានសិទ្ធិអំណាចនៅលើផែនដីនេះ ។ សិទ្ធិអំណាចរបស់ទ្រង់ គឺដោយសារតែទ្រង់ជាកូនមនុស្ស ជាលោកអ័ដាមចុងក្រោយ គឺមិនមែនដោយសារទ្រង់ជាព្រះរាជបុត្រានៃព្រះនោះទេ ។ ព្រះយេស៊ូវ ទ្រង់បានយាងមកជាលោកអ័ដាមចុងក្រោយ ដើម្បីបំពេញគ្រប់ទាំងអស់ ដែលព្រះទ្រង់បានបង្កើតមក គឺជាលោកអ័ដាមទីមួយដែលមាននៅនោះ ។ ការបានសម្រេចនូវផែនការរបស់ព្រះសម្រាប់លោកអ័ដាមទីមួយនោះឯង ។ ព្រះយេស៊ូវទ្រង់បានដើរដោយនូវសិទ្ធិអំណាច និងអំណាចគ្រប់គ្រងដ៏រឹងមាំនៅលើផែនដីនេះ ។

នៅពេលដែលព្រះយេស៊ូវ ទ្រង់បានទទួលពិធីជ្រមុជទឹកនៅក្នុងទន្លេយ័រដាន នោះព្រះវិញ្ញាណបរិសុទ្ធបានយាងមកសន្ថិតលើទ្រង់ ប្រទានអំណាចឱ្យទ្រង់ សម្រាប់ព្រះរាជកិច្ចរបស់ទ្រង់ ។ ក្នុងមួយរំពេចនោះ ឯងបន្ទាប់ពីការនេះ ទ្រង់ត្រូវបាននាំទៅទីរហោស្ថានឱ្យត្រូវល្បួង គឺជាកន្លែងដែលទ្រង់មានជ័យជម្នះលើសាតាំង និងសេចក្តីល្បួងរបស់វា ដោយការនិយាយពីព្រះបន្ទូលរបស់ព្រះ ។ ដោយមានការផ្ទង់ចិត្តទៅលើសិទ្ធិអំណាចរបស់ទ្រង់ នៅលើផែនដីនេះ ដែលជាមនុស្សនោះ ព្រះវិញ្ញាណបរិសុទ្ធក៏បានប្រទាននូវអំណាច ទ្រង់ក៏បានត្រៀមអង្គទ្រង់ជាស្រេច សម្រាប់ព្រះរាជកិច្ចនៅលើផែនដីនេះ បានចាប់ផ្តើមឡើង ។ ទ្រង់បានចាប់ផ្តើមព្រះរាជកិច្ចនេះនៅស្រុកកាលីឡេ ទ្រង់បានទទួលការចាក់ប្រេងតាំងដោយនូវអំណាចចេស្តានៃព្រះវិញ្ញាណបរិសុទ្ធ ហើយនិយាយដោយនូវសិទ្ធិអំណាចនោះ ។

ព្រះគម្ពីរលូកា ៤:១៤,១៦,១៨-២១ (ព្រះយេស៊ូវទ្រង់កំពុងតែអាន ព្រះគម្ពីរអេសាយ ៦១:១-២) ។

### ខ. ព្រះរាជសារទីពីរ

បន្ទាប់ពីព្រះយេស៊ូវមានបន្ទូលនៅស្រុកណាសារ៉ែត នោះទ្រង់បានមានបន្ទូលនៅទីក្រុងកាពើណិម ។ បណ្តាមនុស្សក៏បានឆ្ងល់ពីសិទ្ធិអំណាចរបស់ទ្រង់ ។

**១. ទ្រង់មានសិទ្ធិអំណាច**

ព្រះគម្ពីរលូកា ៤:៣១-៣៥

**២. វិញ្ញាណអាក្រក់ត្រូវបានបណ្តេញចេញ**

ព្រះគម្ពីរលូកា ៤:៣៣-៣៥

ព្រះយេស៊ូវ ទ្រង់បានបញ្ជាទៅវិញ្ញាណអាក្រក់ឱ្យចេញទៅ ហើយដោយព្រោះតែវាបានដឹងនូវសិទ្ធិអំណាចរបស់ព្រះយេស៊ូវ នោះវាក៏ចេញទៅ ។

**៣. សិទ្ធិអំណាចនិងអំណាចចេស្តា**

ព្រះគម្ពីរលូកា ៤:៣៦

## IV. ការអនុវត្តន៍របស់ព្រះយេស៊ូវចោយនូវសិទ្ធិអំណាច

លោកម៉ាកុសក៏បានសរសេរចែងទុកមក អំពីព្រះរាជកិច្ចរបស់ព្រះយេស៊ូវនៅក្រុងកាពើណិមនោះ ហើយបណ្តាមនុស្សដែលមានចម្ងល់ទៅលើសិទ្ធិអំណាចនោះ គឺនៅក្នុងកន្លែងដែលទ្រង់បានបំពេញព្រះរាជកិច្ចនោះឯង ។ លោកម៉ាកុសបានធ្វើដំណើរទៅប្រាប់គេអំពីវិញ្ញាណអាក្រក់ដទៃទៀត ដែលបានកាន់កាប់ និងធ្វើឱ្យមនុស្សឈឺ នៅត្រូវបានទទួលនូវការប្រោសឱ្យជា ។

### ក. សិទ្ធិអំណាចលើពួកវិញ្ញាណអាក្រក់

ព្រះគម្ពីរលូកា ៤:៤០-៤១

ពិមែនហើយ ពួកគេបានស្គាល់ព្រះអង្គ ។ ពួកគេបានថ្វាយបង្គំព្រះអង្គតាំងពីអស់រៀងមកហើយ ។ ហើយឥឡូវនេះ ទ្រង់បានយាងមកបំផ្លាញដល់ពួកគេ ។

### ខ. សិទ្ធិអំណាចលើជម្ងឺរោគា

ព្រះគម្ពីរម៉ាកុស ៣:១-៣

### គ.សិទ្ធិអំណាចលើខ្លួនមនុស្ស

ព្រះគម្ពីរម៉ាកុស ៣:១-៣

ព្រះយេស៊ូវទ្រង់បានជ្រាបនូវការដែលមនុស្ស ដែលមានបំណងចង់ទទួលនូវការប្រោសឱ្យជា ។ ដោយនូវសិទ្ធិអំណាចនោះទ្រង់មានបន្ទូលថា "ចូរឈានដើរទៅ" ។

ព្រះគម្ពីរម៉ាកុស ៣:៤-៥

ដោយនូវសិទ្ធិអំណាច គឺនៅពេលដែលកូនមនុស្ស គឺជាព្រះយេស៊ូវដែលទ្រង់មានបន្ទូលនូវពាក្យមួយម៉ាត់ ហើយមនុស្សនោះក៏បានលាតដៃគាត់ ហើយដៃគាត់ក៏ត្រូវបានទទួលនូវការប្រោសឱ្យជា ។ ព្រះយេស៊ូវទ្រង់មានបន្ទូលដោយនូវសិទ្ធិអំណាច និងអំណាចគ្រប់គ្រងនោះឯង ។ ទ្រង់មិនបានអាងលើព្រះទេ ។

### ឃ. សិទ្ធិអំណាចលើស្នាព្រះហស្ត

បណ្តាសាទៅកាន់ដើមល្វា

ព្រះយេស៊ូវទ្រង់មានសិទ្ធិ អំណាចលើដើមល្វានោះ ។ ព្រះគម្ពីរម៉ាថាយ ២១:១៩ ។

### ង. សិទ្ធិអំណាចលើកម្លាំងធម្មជាតិ

ទ្រង់បានបញ្ឈប់ព្យុះ

ព្រះយេស៊ូវទ្រង់មានបន្ទូលទៅខ្យល់ និងសមុទ្រដោយនូវសិទ្ធិអំណាច ហើយពួកគេក៏ស្តាប់បង្គាប់ព្រះអង្គ ។ ព្រះគម្ពីរម៉ាកុស ៤:៣៥-៣៨ ។

ព្រះយេស៊ូវទ្រង់បានស្តីបន្ទោសទៅខ្យល់ ហើយមានបន្ទូលទៅកាន់សមុទ្រ ។ ព្រះគម្ពីរម៉ាកុស ៥:៤០ ។

ការជាប់ទាក់ទងរបស់ព្រះយេស៊ូវគឺ "ហេតុអ្វីបានជាអ្នករាល់គ្នាមានការភ័យខ្លាចយ៉ាងដូច្នេះ? អ្នករាល់គ្នាអាចបញ្ជា

ទៅព្យុះឱ្យឈប់បាន ។ តើសេចក្តីជំនឿរបស់អ្នករាល់គ្នានៅឯណា?" ព្រះគម្ពីរម៉ាកុស ៥:៤១ ។

## V. ព្រះយេស៊ូវគឺជាគំរូរបស់យើង

ព្រះយេស៊ូវទ្រង់គឺជាគំរូរបស់យើង ពីរបៀបដែលយើងត្រូវដើរ និងបំពេញការងារដោយនូវសិទ្ធិអំណាចនោះ ។ ព្រះរាជកិច្ចរបស់ទ្រង់នៅលើផែនដីនេះ គឺជាលោកអ័ដាមចុងក្រោយ គឺជាគំរូពីរបៀបដែលយើងត្រូវបានទទួលនូវការប្រោសលោះ និងទទួលនូវការកែជាថ្មីដល់មនុស្សជាតិនោះឯង គឺត្រូវតែធ្វើការងាររបស់ផងព្រះយេស៊ូវ នៅលើផែនដីសម័យសព្វថ្ងៃនេះនោះឯង ។ យើងត្រូវតែរស់នៅ និងបំពេញការងារ ដោយនូវសិទ្ធិអំណាចដ៏រឹងមាំដដែល ដែលព្រះយេស៊ូវទ្រង់បានធ្វើ ដូចជាយើងក៏បានធ្វើការព្រះអង្គដែរ ។

ព្រះគម្ពីរយ៉ូហាន ១៤:១២

### ក.ព្រះយេស៊ូវទ្រង់បានស្តីបន្ទោសដល់ជម្ងឺគ្រុន

ព្រះយេស៊ូវទ្រង់មានបន្ទូលដោយនូវសិទ្ធិអំណាច គឺនៅពេលដែលទ្រង់បានស្តីបន្ទោសដល់ជម្ងឺគ្រុន ដែលមាននៅក្នុងម្តាយក្មេករបស់លោកពេត្រុស ។

ព្រះគម្ពីរលូកា ៤:៣៨-៣៩

### ខ. ការប្រោសលោកឡាសារឱ្យរស់ឡើងវិញ

ព្រះយេស៊ូវទ្រង់បានមានបន្ទូលដោយអង់អាច និងដោយការបង្ខំដោយការបញ្ចេញសម្លេងខ្លាំងៗ ទៅកាន់ផ្នូររបស់លោកឡាសារនោះ ។

ព្រះគម្ពីរយ៉ូហាន ១១:៤៣

### គ. ការធ្វើការងាររបស់ព្រះយេស៊ូវ

គ្រប់ទីកន្លែងដែលព្រះយេស៊ូវទ្រង់ទៅ គឺទ្រង់បានបំពេញព្រះរាជកិច្ចដោយមានភាពក្លាហាន ដែលបានចូលមកជាលទ្ធផលនៃការស្គាល់នូវសិទ្ធិអំណាចរបស់ទ្រង់ ជាកូនមនុស្សនោះ ។ នៅពេលដែលទ្រង់បានបញ្ចេញ នូវសិទ្ធិអំណាចដោយនូវអំណាចចេស្តានៃព្រះវិញ្ញាណបរិសុទ្ធ នោះទ្រង់បានប្រោសអ្នកជម្ងឺឱ្យជា ដេញវិញ្ញាណអាក្រក់ និងប្រោសអ្នកស្លាប់ឱ្យបានរស់ឡើងវិញ ។ ទ្រង់បានធ្វើការនេះ គឺទុកជាគំរូដល់ពួកអ្នកជឿទាំងនៅថ្ងៃនោះ និងទាំងប្រចាំថ្ងៃរបស់យើង ។

ព្រះយេស៊ូវទ្រង់មានបន្ទូលប្រាប់ពួកសិស្ស ឱ្យបំពេញការងារដោយនូវសិទ្ធិអំណាចដដែលនោះ ព្រមទាំងឱ្យធ្វើការងារដដែលនោះ ដោយច្បាស់លាស់ដែលទ្រង់បានធ្វើទុករួចមកហើយនោះ ។

ព្រះគម្ពីរម៉ាថាយ ១០:៨ ។

ពួកសិស្សអាចធ្វើការងាររបស់ព្រះយេស៊ូវ ពីព្រោះទ្រង់បានប្រទានឱ្យពួកគេនូវសិទ្ធិអំណាចដដែល ដែលទ្រង់បានរស់នៅ និងបានបំពេញព្រះរាជកិច្ចនោះ ។

ព្រះគម្ពីរលូកា ១០:១៩ ។

### ឃ. សិទ្ធិអំណាចដ៏ខ្លាំងក្លា

ព្រះរាជកិច្ចរបស់ព្រះយេស៊ូវ គឺបានប្រទានមកទុកជាគំរូដ៏ខ្លាំងក្លា និងមានអំណាចចេស្តា មិនមែនសម្រាប់ឱ្យមានការភ័យខ្លាច និងមានការអៀនខ្មាសនោះទេ ។

ព្រះគម្ពីរ ២ធីម៉ូថេ ១:៧

ព្រះយេស៊ូវទ្រង់បានផ្សាយដំណឹងល្អ ប្រកបដោយសេចក្តីក្លាហាន បណ្តេញអារក្ស និងអធិស្ឋានដាក់ដៃឱ្យអ្នកជម្ងឺ និង

មើលឃើញពួកគេបានគ្របបាំង នៅពេលដែលទ្រង់បំពេញព្រះរាជកិច្ចដោយនូវសិទ្ធិអំណាចនោះ ។ ព្រះយេស៊ូវដ៏ជាគំរូរបស់យើង ទ្រង់បានទុកយើងជាមួយនឹងចំណែកពាក្យសម្តីទាំងនេះ ។

ព្រះគម្ពីរម៉ាកុស ១៦:១៥-១៨

នៅពេលដែលយើងដើរតាមគំរូរបស់ព្រះយេស៊ូវ ធ្វើជាលោកអ័ដាមចុងក្រោយ ដែលយើងនឹងរកឃើញដោយខ្លួនឯងនូវការស្តាប់បង្គាប់ព្រះបន្ទូលរបស់ព្រះយេស៊ូវ ដ៏ជាអ្នកបង្កើតលោកអ័ដាមទីមួយនោះ ។ យើងនឹងរកឃើញដោយខ្លួនឯងនូវការគ្រប់គ្រង និងការចាប់យកនូវអំណាចគ្រប់គ្រងលើផែនដីនេះ ព្រមទាំងរបស់ទាំងអស់នៅលើផែនដីនេះ គឺរួមទាំងជម្ងឺការជាប់ចំណង ភាពទ័លក្រ និងសេចក្តីស្លាប់ ។ ម្យ៉ាងទៀត យើងនឹងធ្វើការអ្វីដែលយើងត្រូវបានបង្កើតមកឱ្យធ្វើនោះ ។

**ង. សេចក្តីវន្ធត់របស់សាតាំង**

នៅពេលដែលព្រះយេស៊ូវទ្រង់បានបំពេញព្រះរាជកិច្ចនៅលើផែនដីនេះ នោះសាតាំងត្រូវតែមានការឃ្លាំមើល ដោយមានភាពវន្ធត់ ។ នេះហើយ ដែលព្រះយេស៊ូវទ្រង់បានបំពេញព្រះរាជកិច្ចជាមនុស្ស គឺទ្រង់បានចាប់យកនូវអំណាចគ្រប់គ្រងដោយការនិយាយ និងការបំពេញព្រះរាជកិច្ចដោយនូវសិទ្ធិអំណាច ដោយការធ្វើយ៉ាងដូច្នោះ នោះគឺកំពុងតែបានបំផ្លាញការងាររបស់សាតាំងហើយ ។

ព្រះគម្ពីរ ១យ៉ូហាន ៣:៨ខ

ពេលដែលយើងដើរតាមគំរូរបស់ព្រះយេស៊ូវ នៅសម័យសព្វថ្ងៃនេះ នោះយើងនឹងរស់នៅ ព្រមទាំងបំពេញការងារដោយនូវសិទ្ធិអំណាច ដែលបានប្រទានមកពីព្រះរបស់យើងនោះដែរ ។ យើងក៏នឹងបំផ្លាញការងាររបស់សាតាំងផងដែរ ។

**VI. ការសុគតរបស់ព្រះយេស៊ូវ**

**ក. ព្រះយេស៊ូវទ្រង់បានត្រូវចោទប្រកាន់ ត្រូវទទួលការល្បើងជូរចត់ ទទួលការជាប់ឆ្កាង ។**

នគររបស់សាតាំង គឺត្រូវបានទទួលនូវការបំផ្លាញហើយៗ សាតាំងក៏បានដឹងថា ព្រះយេស៊ូវទ្រង់ត្រូវតែបានទទួលនូវការធ្វើគុត ។ ការឆបោកគឺបានធ្វើការជាមួយនឹងពួកទេវតា ។ វាបានធ្វើការទាស់ទទឹងជាមួយនឹងលោកអ័ដាម និងនាងអេវ៉ា ប៉ុន្តែ វាមិនបានធ្វើការប្រឆាំងនឹងព្រះយេស៊ូវនោះទេ! ទោះជាយ៉ាងណាក៏ដោយ ម្យ៉ាងទៀត សាតាំងបានប្រើប្រាស់នូវការឆបោកនេះ ។ វាបានបញ្ឆោតពួកអ្នកដឹកនាំសាសនា ឱ្យបានធ្វើការទាមទារ ឱ្យព្រះយេស៊ូវទ្រង់ត្រូវសុគតវិញ ។ វាបានធ្វើការកាន់កាប់ដល់រូបកាយរបស់ពួកសាសន៍យូដា ឱ្យទទួលស្គាល់នូវការចោទប្រកាន់នោះ សូម្បីតែនៅពេលដែលវាបានចូលទៅក្នុងរូបកាយរបស់សត្វពស់ ក៏ឱ្យបានទទួលស្គាល់នូវការបោកប្រាស់ដល់លោកអ័ដាម និងនាងអេវ៉ាដែរ ។

សាតាំងបានស្អប់ដល់ព្រះយេស៊ូវយ៉ាងខ្លាំងបំផុត ដែលមិនមែនត្រឹមតែបានធ្វើឱ្យវាចង់ឱ្យទ្រង់ទទួលនូវការសុគត គឺសាតាំងចង់ឱ្យទ្រង់ទទួលនូវការរងទុក្ខ ។ គោលការណ៍ទាំងអស់ អំណាចទាំងអស់ ការគ្រប់គ្រងនៃសេចក្តីងងឹតទាំងអស់ព្រមទាំងវិញ្ញាណដ៏កំណាចទាំងអស់របស់សាតាំង បានចូលមកដោយសេចក្តីពេញចិត្ត ។ ពួកគេត្រូវតែបានប្រុងប្រៀបរៀបចំសម្រាប់ជ័យជម្នះដ៏ធំ ក្នុងមួយរំពេចរបស់ពួកគេនោះព្រមទាំងការរៀបចំធ្វើពិធីបុណ្យ នៅពេលដែលការបំផ្លាញរបស់ពួកគេផ្ទាល់បានមកដល់ ។

**ខ. អ្នកឆបោកដ៏ធំបានធ្វើការឆបោក**

សាតាំងគឺជាអ្នកឆបោក វាខ្លួនឯងនោះឯងដែលបានធ្វើ

ការឆបោកនោះ ។ នៅក្នុងសេចក្ដីសម្អប់ដ៏ងងឹតរបស់វា នោះវាមិនពិតប្រាកដថា វាគ្រាន់តែបានបណ្ដាលឱ្យសេចក្ដីស្លាប់របស់តួអង្គដែលនឹងត្រូវសុគតជំនួស ហើយនឹងបានរស់ពីសុគតឡើងវិញនោះទេ គឺទ្រង់ថែមទាំងបានធ្វើឱ្យវាត្រូវបរាជ័យ និងបានជួយរំដោះមនុស្សជាតិ ឱ្យរួចចាកផុតពីលទ្ធផលនៃអំពើបាបរបស់ពួកគេនោះថែមទៀតផង ។

### គ. ព្រះយេស៊ូវ ទ្រង់បានបង់ថ្លៃជំនួសអំពើបាបរបស់យើងដោយការសុគតនៅលើឈើឆ្កាង ។

ទ្រង់បានជួយរំដោះអំពើបាបរបស់យើងទាំងអស់ គឺជម្ងឺ និងជម្ងឺរោគា ព្រមទាំងពិការភាព ក៏ត្រូវទទួលរងទុក្ខទោសជំនួសយើងរាល់គ្នាវិញ ។ នៅពេលដែលអំពើបាបទាំងអស់នៃពិភពលោកយើងនេះ ក៏ត្រូវបានរើចេញមកពីព្រះយេស៊ូវ មកពីអំណាចចេស្ដារបស់ព្រះ បានចូលមកឯព្រះអង្គនោះឯង ។ លោកិយទាំងមូល គឺត្រូវញ័រកំឡុងពេលសង្គ្រាមខាងឯវិញ្ញាណដ៏ធំនោះ ។ ព្រះយេស៊ូវទ្រង់បានបំពុលដល់សាតាំងនិងពពួកវិញ្ញាណអាក្រក់របស់វា ។ សាតាំង ដែលពីពេលមុនមកវាបានធ្វើឱ្យលោកអ័ដាម នៅពីក្រោមសិទ្ធិអំណាចរបស់វា ។ ព្រះយេស៊ូវទ្រង់បានចាប់យកកូនសោរនៃសិទ្ធិអំណាច ចេញពីវិញ្ញាណអាក្រក់វិញហើយ ។

## VII. តើមានអ្វីកើតឡើងនៅលើផែនដី?

### ក. មានកើតសង្គ្រាមចំនួនបីថ្ងៃ

ព្រះយេស៊ូវទ្រង់បានមានបន្ទូលថា ពេលដែលលោកយ៉ូណាសបាននៅក្នុងមាត់ត្រីចំនួនបីថ្ងៃបីយប់ នោះទ្រង់ក៏នឹងត្រូវនៅក្នុងផ្ទៃនៃផែនដីចំនួនបីថ្ងៃបីយប់ដែរ ។

ព្រះគម្ពីរម៉ាថាយ ១២:៤០

### ខ. ភស្តុតាង

***វាំងននក៏រហែកជាពីរ ផែនដីករញ្ជើក ថ្មក៏ត្រូវបែកចេញ ផ្នូរក៏ត្រូវរបើកឡើងដែរ ។***

មនុស្សមិនត្រូវដាច់ចេញពីព្រះតទៅទៀតឡើយ ។ រីឯវាំងននៅក្នុងព្រះវិហារ ដែលត្រូវចូលទៅក្នុងទីបរិសុទ្ធបំផុតនោះគឺត្រូវរហែកជាពីរ ។ ផែនដីក៏ត្រូវរញ្ជួយឡើង នៅពេលដែលព្រះយេស៊ូវទ្រង់បានបំបាក់បំបែក រនាំងនៃសេចក្ដីស្លាប់ដែលនៅក្នុងចិត្តរបស់ផែនដីនេះ ។

ព្រះគម្ពីរម៉ាថាយ ២៧:៥០-៥៣

## VIII. តើវិញ្ញាណលោកិយមានអ្វីកើតឡើង?

សមរភូមិដែលត្រូវតភ្ជាប់រវាងព្រះយេស៊ូវ ដ៏ជាអ្នកជំនួសរបស់យើងនិងសាតាំងរួមទាំងពពួកវិញ្ញាណអាក្រក់ដ៏ជាអ្នកថែសេះរបស់វា ក៏ត្រូវបានកើតឡើង ។

នៅពេលដែលព្រះយេស៊ូវទ្រង់បានត្រូវគេបោះភ្ជាប់ នៅលើឈើឆ្កាង នោះសាតាំងត្រូវតែបានទទួលនូវការកោះហៅព្រមទាំងពពួកវិញ្ញាណរបស់វា ឱ្យបានធ្វើជាទីបន្ទាល់ពីព្រឹត្តិ-ការណ៍ឆ្កាងដល់ទ្រង់នេះ ។ រឿងនេះគឺជាការដ៏សំខាន់បំផុតសម្រាប់ពួកគេដែលមានការបាត់បង់នេះ! នៅពេលដែលព្រះយេស៊ូវទ្រង់បានទទួលនូវការសុគតនៅលើឈើឆ្កាង នោះសាតាំងនិងពពួកវិញ្ញាណអាក្រក់របស់វា ត្រូវតែបានទទួលនូវការរៀបចំនូវការសប្បាយរីករាយដ៏កំណាច សម្រាប់អ្វីដែលពួកវាបានគិតថា ជាជ័យជម្នះដ៏ធំក្នុងមួយរំពេចភ្លាមៗនោះ ។

វាមិនគ្រប់គ្រាន់ទេចំពោះសាតាំង ក្នុងការឃើញភាពមានជីវិតនៃរូបកាយរបស់ព្រះយេស៊ូវដែលគេបានព្យួរនៅលើឈើឆ្កាងនោះ ។ ដោយមានចិត្តដ៏ខ្មៅងងឹត សាតាំងត្រូវតែបាន

ស្រែកនូវសម្រែកដ៏សប្បាយរីករាយថា "វាត្រូវតែបានធ្លាក់ទៅក្នុងជង្ហុកដ៏ធំនោះ!" ។ សាតាំងនិងពពួកវិញ្ញាណអាក្រក់របស់វា ដោយនូវការល្ងង់ខ្លៅរបស់ពួកវាយ៉ាងលីលា នោះត្រូវតែបានចាប់ផ្តើមសប្បាយរីករាយហើយ ប៉ុន្តែ ជីវិតនៃការជប់លៀងដ៏ខ្លីនៅទ្វារនៃស្ថានឃុំព្រលឹង គឺត្រូវបិទភ្ជាប់ឱ្យទៅនៅពីខាងក្រោយព្រះយេស៊ូវទៅវិញ ។

ព្រះយេស៊ូវទ្រង់បានត្រងយក ជាមួយនឹងអំពើបាបដ៏រន្ធត់របស់មនុស្សជាតិ ដោយការរងទុក្ខពីគ្រប់ទាំងអំពើដែលត្រូវរងទុក្ខទាំងអស់នៅក្នុងជង្ហុក គឺដែលទ្រង់បានដោះកូនចៅដែលគ្មានអ្នកជំនួយ ចេញពីទីជម្រៅនៃជង្ហុកដ៏ជ្រៅនោះ ។

នៅទីនោះហើយដែលទ្រង់បានបញ្ឈប់ និងរំដោះនូវអំពើបាបដ៏ធំ ដែលត្រូវតែបានកន្លងបង់ផុត ចេញពីពួកគេទៅតាមរយៈសេចក្តីជំនឿរបស់ពួកគេនោះ ។ ទ្រង់បានត្រូវបញ្ចុះគ្រប់ទាំងអំពើបាបទាំងអស់របស់យើងរាល់គ្នា ដើម្បីឱ្យយើងរាល់គ្នា បានត្រូវទទួលនូវការប្រោសលោះដែលគ្មានទោសតទៅទៀតឡើយ ។

ព្រះគម្ពីរទំនុកដំកើង ១០៣:១២

## ក. សេចក្តីទំនាយដោយស្តេចដាវីឌ

### ១. ទ្រង់បានដកយកនូវទោសនៃអំពើបាប និងការជំនុំជម្រះនៃអំពើបាបចេញ ។

ស្តេចដាវីឌ បានពណ៌នាពីអ្វីដែលបានកើតឡើងដល់ព្រះយេស៊ូវបន្ទាប់ពីការសុគតរបស់ផងព្រះអង្គ ។ ទ្រង់បានផ្ទុកនូវអំពើបាបរបស់យើង ទ្រង់គឺជាអ្នកជួយដល់យើង នៅពេលដែលសាតាំងបានមានផែនការនោះ គឺជាការបំផ្លាញចុងក្រោយរបស់ព្រះអង្គ ។ កូនចៅជំនាន់ក្រោយរបស់វា ត្រូវបានបោះទៅក្នុងផ្នែកនៃជង្ហុកដ៏ជ្រៅបំផុត ។ នេះគឺជាអស់អ្នកដែលបានស្លាប់ដោយការមិនជឿ គឺនឹងត្រូវបានទទួលនូវការរងទុក្ខ និងត្រូវជាប់ជំនុំជម្រះ ។

ព្រះយេស៊ូវ ទ្រង់បានយាងទៅដល់ជង្ហុកនោះ ដោយការផ្ទុកនូវទោសកំហុស និងការជំនុំជម្រះចំពោះអំពើបាបរបស់យើង ។

ព្រះគម្ពីរទំនុកដំកើង ៨៨:៣-៧

### ២. ស្តេចដាវីឌក៏បានថ្លែងទំនាយ អំពីការរស់ពីសុគតឡើងវិញរបស់ព្រះយេស៊ូវ ។

ព្រះគម្ពីរទំនុកដំកើង ១៦:១០

## ខ. ការថ្លែងទំនាយដោយហោរាអេសាយ

ព្រះគម្ពីរអេសាយ ៥៣:៨-១១

## គ. កូនចៀមនៃព្រះ

### ១. ទ្រង់បានផ្ទុកអំពើបាបរបស់មនុស្សជាច្រើន

### ២. ទ្រង់បានជួយអង្វរជំនួសដល់អ្នកដែលប្រព្រឹត្តកន្លង

ព្រះគម្ពីរអេសាយ ៥៣:១២

នៅលើឈើឆ្កាង ព្រះយេស៊ូវទ្រង់បានបំពេញនូវមុខងារជាកូនចៀមដ៏ជាយញ្ញបូជា នៅគ្រាសញ្ញាចាស់ ។

ព្រះគម្ពីរយ៉ូហាន ១:២៩

## ឃ. អ្នករងកំហុសជំនួសអ្នកឯទៀត

នៅពេលដែលព្រះយេស៊ូវ ទ្រង់បានផ្ទុកនូវអំពើបាបរបស់យើង ដើម្បីឱ្យបានចូលទៅដល់ជម្រៅនៃដែនដី នោះទ្រង់

ក៏បានបំពេញ នូវមុខងារជារូបភាពក្នុងការធ្វើជាអ្នករងកំហុសជំនួសអ្នកដទៃទៀត គឺដែលទ្រង់បានផ្ទុកនូវអំពើបាបរបស់សាសន៍អ៊ីស្រាអែលនោះឯង ។

ព្រះគម្ពីរលេវីវិន័យ ១៦:១០,២១-២២

ដោយសារតែព្រះយេស៊ូវទ្រង់បានផ្ទុក នូវអំពើបាបរបស់យើង ទ្រង់បានត្រូវកប់ទៅនូវអំពើបាបទាំងនោះ ទ្រង់ក៏បានធ្វើការរើចេញ នូវអំពើបាបទាំងនោះ ដែលព្រះទ្រង់មិនទាំងដែលស្គាល់តាល់តែសោះនោះ ។ អំពើបាបទាំងនោះគឺត្រូវបានកន្លងបង់ទៅហើយជារៀងរហូត ក៏គ្មាននៅចាំពួកវាតទៅទៀតដែរ ។

## IX. ព្រះយេស៊ូវទ្រង់មិនបានតាំទ្រនូវអំពើបាបនោះទេ!

នៅពេលដែលព្រះយេស៊ូវទ្រង់បានរំដោះ នូវអំពើបាបរបស់យើង ចេញពីជង្ហុកដ៏ជ្រៅនោះមក អំណាចេស្តារបស់ព្រះក៏បានយាងចូលមកក្នុងព្រះអង្គ ។

ព្រះគម្ពីរកិច្ចការ ២:២៧

ទ្វារនៃស្ថាននរក (ស្ថានឃុំព្រលឹងមនុស្ស) មិនអាចទាស់ទទឹងនឹងព្រះយេស៊ូវបានឡើយ ។ ព្រះវិញ្ញាណបរិសុទ្ធ ទ្រង់បានយាងមកសណ្ឋិតនៅលើព្រះយេស៊ូវ ហើយទ្រង់ក៏បានបំបាក់បំបែកទ្វារនៃស្ថាននរកនោះ ដែលទ្រង់ឆក់ទាញយកកូនសោរនៃសេចក្តីស្លាប់ ស្ថាននរក និងសេចក្តីស្លាប់ចេញពីសាតាំងនោះមកបានហើយ ។

## ក.អារក្សនិងពពួកវិញ្ញាណអាក្រក់ត្រូវបរាជ័យ

ប្រវត្តិរឿងសមរភូមិពីជំនាន់ដើម និងការធ្វើឱ្យខ្មាំងសត្រូវបានទទួលនូវការបរាជ័យ គឺបានផ្តល់នូវការយល់ដឹងដ៏ពិសេសៗ ចូលទៅក្នុងសេចក្តីសំខាន់នៃខគម្ពីរជាបន្តបន្ទាប់ ។ ព្រះគម្ពីរកូល៉ុស ២:១៥ ។

អំណាចចេស្តា និងសិទ្ធិអំណាច ដែលយើងបានសិក្សាពីមុនមក គឺសំដៅទៅលើអង្គការវិញ្ញាណអាក្រក់របស់សាតាំងនោះឯង ។ នៅក្នុងពេលវេលាដ៏យូរលង់មកហើយ គឺនៅពេលដែលកងទ័ពបានទទួលនូវការបរាជ័យ នោះខ្មាំងសត្រូវរបស់ពួកគេគឺត្រូវទទួលនូវការដាក់អាវុធចុះ ត្រូវបានដោះសម្លៀកបំពាក់របស់ពួកគេចេញ ត្រូវចាប់ចងដោយច្រវាក់ពីម្នាក់ទៅម្នាក់ទៀត ហើយត្រូវបង្អាប់ពួកគេចុះ ធ្វើពួកគេឱ្យទៅជាខ្ញុំកញ្ជះ ឱ្យទៅជាជនជាតិដែលត្រូវជាប់ជារបឹប ។

ព្រះយេស៊ូវទ្រង់បានដកអាវុធជាលក្ខណៈបុគ្គល ចេញពីសាតាំងនិងចេញពួកវិញ្ញាណអាក្រក់របស់វា ។ ទ្រង់បានដកយកគ្រឿងសាស្ត្រាវុធរបស់ពួកវា ចេញពីពួកវា ។ ទ្រង់ក៏បានដោះសម្លៀកបំពាក់របស់ពួកវាចេញ ។ ទ្រង់ក៏បានធ្វើឱ្យពួកវាត្រូវបានបង្ហាញជាសាធារណៈ ។ ចំពោះអស់អ្នកដែលបានកំពុងតែធ្វើពិធីជប់លៀង ក្នុងពេលដែលព្រះយេស៊ូវទ្រង់ត្រូវគេបោះភ្ជាប់នៅលើឈើឆ្កាង នោះជំនាន់កូនចៅរបស់ពួកវាក៏ត្រូវបានបោះចុះទៅក្នុងជង្ហុកជ្រៅនោះ ដែលឥឡូវនេះពួកវាត្រូវបានទទួលនូវការអាម៉ាសមុខជ្រុបតែម្តងទៅ ។

១. សាតាំងបានធ្វើឱ្យលោកអ័ដាម និងនាងអេវ៉ាទទួលនូវការចុះចាញ់ ។ ហើយក៏បានធ្វើឱ្យពួកគេទៅជាអាក្រាត ក៏បានដោះសិទ្ធិអំណាចចេញពីពួកគេដែរ ។

២. សាតាំងបានគិតថា វាបានធ្វើឱ្យព្រះយេស៊ូវចុះចាញ់ហើយ ។ ហើយវាក៏បានធ្វើឱ្យព្រះយេស៊ូវនៅជាអាក្រាត វាបានព្យួរព្រះយេស៊ូវនៅលើឈើឆ្កាងដែរ។

៣. ទោះជាយ៉ាងណាក៏ដោយ ក៏ព្រះយេស៊ូវទ្រង់បានធ្វើឱ្យសាតាំង និងពពួកវិញ្ញាណរបស់វាត្រូវបរាជ័យ ។

ក៏បានធ្វើផឱ្យពួកវានៅជាអាក្រាត ព្រមទាំងបានដោះនូវ សិទ្ធិអំណាចដ៏កល្បនោះ ចេញពីពួកវាផងដែរ!

## ខ. ការរស់ពីសុគតឡើងវិញ

ដោយមានការបង់ថ្លៃនូវទោសនៃអំពើបាប ដោយនូវការសុគតរបស់ផងព្រះអង្គ នៅលើឈើឆ្កាង ព្រមទាំងបានរំដោះបាបរបស់យើងចេញពីជង្ហុកដ៏ជ្រៅ គឺព្រះយេស៊ូវទ្រង់បានចាប់យកនូវកូនសោរនៃសេចក្តីស្លាប់ ចេញពីស្ថាននរក និងចេញពីផ្ទររបស់សាតាំង នោះបានហើយ ។

ដោយការធ្វើឱ្យសាតាំងទទួលបរាជ័យ ព្រមទាំងបានធ្វើការបំបាក់បំបែក នូវអំណាចលើសេចក្តីស្លាប់របស់វា ការរងទុក្ខរបស់វា នោះមិនអាចឃុំរូបកាយរបស់ព្រះយេស៊ូវបានឡើយ ។ នៅក្នុងការផុសចេញឡើងនៃជ័យជម្នះដ៏ពេញដោយអំណាចចេស្តា នោះព្រះយេស៊ូវទ្រង់បានរស់ពីសុគតឡើងវិញហើយ ។ នោះសាតាំង និងរាល់តាំងវិញ្ញាណអាក្រក់ក៏បានត្រូវទទួលនូវការបរាជ័យផងដែរ!

ព្រះគម្ពីរអេភេសូរ ១:១៩-២១

## X. ព្រះយេស៊ូវទ្រង់បានចម្រើនឡើង

### ក. នៅក្នុងជ័យជម្នះ

ព្រះយេស៊ូវទ្រង់បានចម្រើនឡើង ដោយនូវជ័យជម្នះត្រឡប់មកឯស្ថានសួគ៌វិញ ហើយទ្រង់ក៏បានអនុញ្ញាតឱ្យពួកឈ្លើយស្ថិតនៅក្នុងការហ៊ឹកហ៊ឺនរបស់ព្រះអង្គ ។ ព្រះគម្ពីរអេភេសូរ ៤:៨-១០ ។

ពេលដែលព្រះយេស៊ូវទ្រង់បានអនុញ្ញាត ឱ្យឈ្លើយសឹកដែលជាប់ឃុំ នោះយើងបានមានរូបភាពរបស់ព្រះយេស៊ូវ គឺនៅពេលដែលសញ្ញ័យនៃការដឹកនាំជាទូទៅ ឱ្យខ្មាំងសត្រូវដែលត្រូវបរាជ័យក្នុងការធ្វើជាដំណើរក្បួននោះ ក្នុងការដកហូតយកអាវុធ ក្នុងការធ្វើឱ្យអាក្រាត ក្នុងការចាប់ចងនឹងច្រវាក់ ក្នុងការធ្វើឱ្យអាម៉ាសមុខជ្រុប ក្នុងការធ្វើឱ្យចុកចាប់គឺជាការរព្វកនៅមុខពួកទេវតាទាំងអស់ ដែលនៅស្ថានសួគ៌ ។ សាតាំងនិងរាល់វិញ្ញាណអាក្រក់ ត្រូវបានទទួលនូវការបរាជ័យទាំងស្រុងហើយក៏នៅក្នុងការអាម៉ាសមុខជ្រុប ដែលត្រូវបានបញ្ចេញ ជាសាធារណៈនោះ ។

នៅពេលដែលព្រះយេស៊ូវទ្រង់បានឆក់យកកូនសោរ នៃសិទ្ធិអំណាចចេញពីសាតាំង នោះទ្រង់ក៏បានចាប់យកកូនសោរនៃសិទ្ធិអំណាច ដែលលោកអ័ដាមស្ថិតនៅក្នុងការមិនស្តាប់បង្គាប់ ហើយបានប្រគល់ឱ្យទៅសាតាំងនោះមកវិញផងដែរ ។ នៅពេលដែលព្រះយេស៊ូវ ទ្រង់បានកញ្ឆក់យកកូនសោរទាំងអស់នោះចេញពីដៃរបស់សាតាំងមក នោះទ្រង់ក៏បានដកហូតយកសិទ្ធិអំណាចរបស់សាតាំង ដែលវាបានគ្រប់គ្រងលើមនុស្សជាតិ និងនៅលើផែនដីនោះផងដែរ ។ ព្រះយេស៊ូវទ្រង់បានធ្វើឱ្យសាតាំងទទួលនូវការបរាជ៏យដោយផ្ទាល់ខ្លួន និងរបស់គ្រប់យ៉ាងរួមទាំងពពួកវិញ្ញាណអាក្រក់របស់វា នោះផងដែរ ។

### ខ. ការទទួលបានដោយសេចក្តីអំណរ

ពិតប្រាកដណាស់ គ្មានពាក្យនឹងថ្លែងពីសេចក្តីអំណរនៅឯនគរស្ថានសួគ៌ក្នុងពេលដែលព្រះរាជបុត្រារបស់ព្រះ ដែលទ្រង់

បានគង់នៅខាងស្តាំរបស់ព្រះអង្គ នៅនគរស្ថានសួគ៌នោះ ទ្រង់បានយាងត្រឡប់មកវិញ ។ តើឱ្យមនុស្សអាចពណ៌នាពីការយាងត្រឡប់មកវិញដោយមានជ័យជម្នះនោះ យ៉ាងដូចម្តេចបាន? ស្តេចដាវីឌបានផ្តល់ឱ្យ នូវការរំឭកដល់យើង ដែលបានពណ៌នានៅពេលវេលានេះ ។

ព្រះគម្ពីរទំនុកដំកើង ២៤:៧-១០

ព្រះវរបិតាទ្រង់បានទទួលព្រះយេស៊ូវ ដោយព្រះអង្គទ្រង់ផ្ទាល់ឱ្យចូលទៅក្នុងនគរស្ថានសួគ៌ គឺនៅពេលដែលទ្រង់មានជ័យជម្នះលើសាតាំង លើសេចក្តីស្លាប់ ស្ថាននរក និងផ្នូរនោះឯង ។

## គ. ការប្រកាសពីជ័យជម្នះ!

លោកសាវ័កយ៉ូហាន បានផ្តល់ឱ្យយើងនូវព្រះបន្ទូលរបស់ព្រះយេស៊ូវ នៅពេលដែលដែលទ្រង់បានប្រកាសពីជ័យជម្នះរបស់ព្រះអង្គនោះ! ព្រះគម្ពីរវិវរណៈ ១:១៨ ។

## XI. ព្រះយេស៊ូវទ្រង់មានកូនសោរ!

**ក. ព្រះយេស៊ូវ ទ្រង់បានយាងចូលក្នុងនគរស្ថានសួគ៌ទាំងស្រែកមួយព្រះឱស្ឋថា "ព្រះវរបិតាអើយ! ទូលបង្គំមានកូនសោរហើយ! សាតាំងត្រូវបរាជ័យ ហើយទូលបង្គំមានកូនសោរហើយ!"**

**ខ. ព្រះយេស៊ូវទ្រង់មានកូនសោរនៃសិទ្ធិអំណាច នៅក្នុងព្រះហស្តរបស់ទ្រង់ គឺដែលទ្រង់បានយកចេញពីដៃរបស់សាតាំងៈ** ដែលវាបានលួចយកពីក្នុងសួនច្បារអេដែន គឺនៅពេលដែលវាបានឆបោកដល់លោកអ័ដាម និងនាងអេវ៉ាមក ។

**ការសំខាន់នៃកូនសោរ -** ព្រះយេស៊ូវទ្រង់បានយកកូនសោរចេញពីសាតាំង ប៉ុន្តែ ទ្រង់មិនបានកាន់ពួកវាទេ គឺទ្រង់បានប្រទានឱ្យទៅមនុស្សជាតិវិញ ។ ក្នុងការបើកសម្តែងទីមួយរបស់ពួកជំនុំ នោះព្រះយេស៊ូវទ្រង់មានព្រះបន្ទូលទៅពួកសិស្សថា ទ្រង់នឹងប្រទានកូនសោរនេះ ទៅពួកគេនៅឯនគរស្ថានសួគ៌ ។

ព្រះគម្ពីរម៉ាថាយ ១៦:១៩

នៅក្នុងព្រះគម្ពីរអេសាយ ក៏មានការបញ្ជាក់ដទៃទៀតពីកូនសោរនេះដែរ ។

ព្រះគម្ពីរអេសាយ ២២:២២

ក្នុងពេលអតីតកាល កូនសោរនោះគឺធំណាស់ ធ្ងន់ ហើយមានលម្អថែមទៀត ។ បុរសអ្នកមានទាំងឡាយគឺតែងតែបាននាំយកពួកវាដាក់លើស្មាជានិច្ច ពីព្រោះដោយសារវាមានទម្ងន់ធ្ងន់ ប៉ុន្តែ ចំពោះករណីបន្ថែមទៀតនោះគឺវាមានសម្រស់ស្រស់ស្អាត ។ ជានិច្ចកាល អ្នកបម្រើពីរឬបីនាក់ត្រូវតែដើរតាមបុរសអ្នកមានទាំងនោះ ដើម្បីជួយកាន់កូនសោរទាំងនោះដោយស្ពាយពីលើស្មារបស់ពួកគេ ។ រឿងនេះគឺបង្ហាញអំពីទ្រព្យសម្បត្តិនោះឯង ។

នៅពេលដែលលោកហោរាអេសាយ បានថ្លែងទំនាយពីការយាងមករបស់ព្រះមែស៊ី នោះគាត់បានបញ្ជាក់ពីសេចក្តីសំខាន់របស់កូនសោរ ដែលគេបាននាំយកដោយលីលើស្មា ។

ព្រះគម្ពីរអេសាយ ៩:៦ក

កូនសោរ រដ្ឋបាល និងសិទ្ធិអំណាច គឺស្ថិតនៅក្នុងព្រះហស្តរបស់ព្រះយេស៊ូវ! ព្រះយេស៊ូវទ្រង់បានចាប់យកនូវកូនសោរទាំងនោះ ប្រទានទៅឱ្យពួកជំនុំរបស់ព្រះអង្គ ក្នុងការទូន្មាន ដែលមានពេញដោយកម្លាំងនៅលើនគរផែនដីនេះ ។ វាគឺជាពេលវេលាដែលមានការបាត់បង់ដ៏ពិត ហើយក៏ជាពេលវេលាដែលមានជ័យជម្នះ នៅគ្រប់សមរភូមិនៃជីវិតផងដែរ ។

***សិទ្ធិអំណាចនៅលើផែនដីគឺត្រូវបានកែមនុស្សជាតិសារជាថ្មីឡើងវិញហើយ!***

## ក្រុមពិភាក្សា

១. តើសាតាំងគឺជាអ្នកឆបោកដ៏អស្ចារ្យប៉ុណ្ណាទៅ ដែលវាបានឆបោកគេនោះ?

២. តើមានន័យយ៉ាងដូចម្តេច ដែលព្រះយេស៊ូវទ្រង់បាននាំទៅជា "ពួកអ្នកជាប់ទោស ដោយទ្រង់បានជាប់ទោស"?

៣. តើអ្វីទៅបន្ទាប់ពីព្រះយេស៊ូវទ្រង់បានធ្វើ សម្រាប់យើង តើព្រះទ្រង់ពិតជាបានបំភ្លេចនូវអំពើបាបរបស់យើង និងលែងចងចាំពួកវាតទៅទៀត? ចូរចែកចាយពីព្រះបន្ទូលតាមរយៈចម្លើយរបស់លោកអ្នកត្រឡប់ទៅវិញ ។

## ការសិក្សាដោយខ្លួនឯង

១. តើការសំខាន់អ្វីទៅ ដែលនិយាយអំពីគោលរឿងធម្មតាៗទាំងពីរយ៉ាង នៅពេលដែលអ្នកណាម្នាក់បានទទួលនូវការបរាជ័យៈ ពួកគេត្រូវនៅជាអាក្រាត ត្រូវបានដោះចេញនូវសិទ្ធិអំណាចនោះឬ?

២. ហេតុអ្វីបានជាលោកអ្នកគិតថា ព្រះយេស៊ូវទ្រង់បានប្រទានកូនសោរនៃសិទ្ធិអំណាច ត្រឡប់ទៅឱ្យដល់មនុស្សជាតិវិញ ជំនួសឱ្យការរក្សាទុកពួកវាទាំងនោះ?

៣. ព្រះយេស៊ូវទ្រង់គឺជាអ្នករងជំនួសរបស់យើង ។ ចូរអានព្រះគម្ពីរលេវីវិន័យ ១៦:១០,២១-២២ ម្តងទៀត ។ តើការផ្លាស់ប្រែនូវការរំពឹងរបស់លោកអ្នកនេះ ជាគំនិតរបស់ទ្រង់ឬទេ? បើមែន តើដោយរបៀបណា?

# សិទ្ធិអំណាចរបស់អ្នកជឿ

## *មេរៀនទី ៤: ពួកជំនុំ និងសិទ្ធិអំណាចរបស់វា*

### I. ព្រះរាជកិច្ចរបស់ព្រះយេស៊ូវគឺពេញ លក្ខណៈ!

ព្រះរាជកិច្ចរបស់ព្រះយេស៊ូវ គឺពិតជាមានពេញលក្ខណៈ! ព្រះគម្ពីរ ២កូរិនថូស ៥:១៧ ។

នៅសម័យសព្វថ្ងៃនេះ គឺនៅពេលដែលយើងបានកើតជាថ្មី នោះគឺយើងមានផ្លូវនៃជីវិតថ្មីទាំងស្រុង ។ សិទ្ធិអំណាច និងអំណាចគ្រប់គ្រងរបស់យើង បានទទួលនូវការកែជាថ្មីឡើងវិញហើយ ។ ម្យ៉ាងទៀតដង្ហើមរបស់ព្រះត្រូវបានដកចូលមកក្នុងយើងវិញហើយដែរ ។ តាមរយៈការជ្រមុជដោយព្រះវិញ្ញាណបរិសុទ្ធ នោះមានអំណាចចេស្ដានៃព្រះវិញ្ញាណបរិសុទ្ធនោះឯង ។ គ្រប់យ៉ាងដែលព្រះយេស៊ូវទ្រង់អាចធ្វើបាន គឺជាលោកអ័ដាមចុងក្រោយ លោកអ្នកនិងខ្ញុំគឺមានសិទ្ធិអំណាចដូចៗគ្នា ដើម្បីធ្វើការដូចៗគ្នាដែរ ។ ពេលដែលព្រះយេស៊ូវទ្រង់បានលើកកូនចៅកាន់តែខ្ពស់ឡើង នោះព្រះវរបិតាទ្រង់ក៏បានទទួលទ្រង់ និងព្រះលោហិតរបស់ទ្រង់ ក៏បានបង្ហូរមកស្រោចលើទីសន្ដោសប្រោស ហើយព្រះរាជកិច្ចរបស់ទ្រង់ក៏ត្រូវបានបង្គ្រប់ដែរ ។ ចំពោះសិទ្ធិអំណាច ដែលបានទទួលនូវការកែជាថ្មី ព្រមទាំងបានជ្រមុជដោយព្រះវិញ្ញាណបរិសុទ្ធ នោះយើងអាចដើរដោយនូវសិទ្ធិអំណាច និងអំណាចចេស្ដាដែលព្រះយេស៊ូវទ្រង់បានដើរនោះដែរ ។

### ក. ព្រះយេស៊ូវគង់នៅក្នុងនគរស្ថានសួគ៌

អ្នកនិពន្ធព្រះគម្ពីរហេព្រើរ ផ្ដល់ឱ្យយើងនូវតួនាទីរបស់ព្រះយេស៊ូវនៅសម័យសព្វថ្ងៃនេះ ។

ព្រះគម្ពីរហេព្រើរ ១០:១២-១៣

ព្រះយេស៊ូវទ្រង់បានគង់នៅខាងស្ដាំ នៃព្រះវរបិតា ។

ស្ដេចដាវីឌក៏បានថ្លែងទំនាយ ពីវត្តមាននៃតួនាទីរបស់ព្រះយេស៊ូវនៅថ្ងៃនេះ ។

ព្រះគម្ពីរទំនុកដំកើង ១១០:១

ស្ដេចដាវីឌបានថ្លែងទំនាយថា ព្រះយេស៊ូវទ្រង់នឹងបានគង់នៅខាងស្ដាំព្រះវរបិតា ។ ព្រះរាជកិច្ចរបស់ទ្រង់គឺបានសម្រេចហើយ ។ រីឯការងាររបស់យើងក៏បានចាប់ផ្ដើមឡើងដែរ ។

### ខ. ព្រះយេស៊ូវទ្រង់កំពុងតែរង់ចាំ

ទាំងស្ដេចដាវីឌ ទាំងអ្នកនិពន្ធព្រះគម្ពីរហេព្រើរបានប្រាប់យើងថា ព្រះយេស៊ូវទ្រង់កំពុងតែធ្វើការបន្ថែមទៀត ជាជាងការដែលទ្រង់កំពុងតែអង្គុយនៅខាងស្ដាំ នៃព្រះវរបិតានោះទៅទៀត ។ ព្រះយេស៊ូវទ្រង់កំពុងតែរង់ចាំឱ្យខ្មាំងសត្រូវរបស់ផងទ្រង់ដែលត្រូវនៅក្រោមព្រះបាទទ្រង់ ។

តើអ្នកណាមានបំណង នឹងធ្វើឱ្យខ្មាំងសត្រូវរបស់ព្រះអង្គឱ្យនៅពីក្រោមព្រះបាទារបស់ផងទ្រង់នោះ? ព្រះយេស៊ូវទ្រង់កំពុងតែរង់ចាំសម្រាប់ប្រោសលោះរបស់ព្រះអម្ចាស់ នៅក្នុងការរុកឱ្យឃើញ នូវសិទ្ធិអំណាចដែលបានកែជាថ្មីឡើងវិញ ដើម្បីធ្វើការសម្ដែងថា សាតាំងដែលជាខ្មាំងសត្រូវគឺត្រូវបានទទួលនូវការបរាជ័យហើយ ។ ព្រះរាជកិច្ចរបស់ព្រះយេស៊ូវគឺបានពេញលេញហើយ! ទ្រង់កំពុងតែរង់ចាំដល់អស់ទាំងខ្មាំងសត្រូវរបស់ទ្រង់ ឱ្យបាននៅពីក្រោមព្រះបាទារបស់ទ្រង់នោះឯង ។ វាគឺជាការងាររបស់ពួកអ្នកជឿឱ្យបានដាក់សាតាំងឱ្យនៅក្នុងកន្លែងរបស់វានោះ ។ ពួកអ្នកជឿទាំងឡាយ គឺត្រូវ

តែដាក់សាតាំង និងពួកវិញ្ញាណអាក្រក់របស់វាឱ្យនៅពីក្រោមព្រះបាទារបស់ព្រះយេស៊ូវ ។ ព្រះយេស៊ូវទ្រង់បានធ្វើសម្រេចគ្រប់យ៉ាង ដែលទ្រង់បានកំណត់ធ្វើនោះ ។ ឥឡូវនេះភារកិច្ចទទួលខុសត្រូវគឺជារបស់យើងហើយ ។ យើងគឺជារូបកាយរបស់ព្រះអង្គនៅលើផែនដីនេះ ។ យើងគឺជាដៃ ជាជើង ជាប្រអប់ជើងរបស់ព្រះអង្គ ។ យើងគឺជាម្នាក់ដែលត្រូវតែគ្រប់គ្រងលើពិភពលោករបស់យើងនៅសម័យសព្វថ្ងៃនេះ ។ ទ្រង់បានប្រទានឱ្យមកយើងនូវសិទ្ធិអំណាច ដើម្បីដើរក្នុងផ្លូវដែលទ្រង់បានដើរនោះ ។ ទ្រង់បានប្រទានឱ្យមកយើងនូវកូនសោរដើម្បីផ្ទេរអំណាចចេស្តានោះឱ្យមកយើងធ្វើការងារ ។

ព្រះគម្ពីរយ៉ូហាន១៤:១២

ព្រះគម្ពីរម៉ាថាយ ១០:៨

ទ្រង់បានចាត់ព្រះវិញ្ញាណបរិសុទ្ធ ឱ្យមកបំពេញដល់យើងឱ្យបានធ្វើកិច្ចការងារទាំងនេះ ។ ព្រះយេស៊ូវទ្រង់បានប្រទានឱ្យយើងនូវសិទ្ធិអំណាចនោះឯង ។ ព្រះយេស៊ូវទ្រង់ធ្វើការងារដ៏ពេញលេញ ។ ទ្រង់កំពុងតែរង់ចាំរហូតដល់ខ្មាំងសត្រូវរបស់ទ្រង់ត្រូវបានដាក់នៅពីក្រោមព្រះបាទារបស់ទ្រង់ ។ នោះគឺជាការទទួលខុសត្រូវរបស់យើងហើយ ។ យើគឺជាអ្នកដែលបានកើតជាថ្មី ។ យើងមានកូនសោរនៃសិទ្ធិអំណាចនោះហើយ ។ យើងគឺជាអ្នកស្រាយចំណងហើយ ។ ដែលយើងបានទូលសូមដល់ព្រះយេស៊ូវឱ្យទ្រង់បានយាងមក ព្រមទាំងបានជួសជុលនូវបញ្ហាទាំងឡាយរបស់យើង ដែលយើងបានទូលសូមឱ្យព្រះយេស៊ូវទ្រង់មិនស្តាប់បង្គាប់ដល់ព្រះវរបិតា របស់ទ្រង់នោះ ។ វាគឺជាពេលវេលាសម្រាប់យើង ក្នុងការចាប់ផ្តើមធ្វើការងារដែលយើងបានទទួលនូវការប្រទានពរមកនោះ ។ វាគឺជាការទទួលខុសត្រូវរបស់យើងហើយ ។ វាគឺជាពេលវេលាសម្រាប់យើងធ្វើការងាររបស់ព្រះយេស៊ូវ ។

## II. សេចក្តីអធិស្ឋានរបស់លោកប៉ុល

លោកសាវ័កប៉ុលគឺបានអធិស្ឋានពីការដ៏សំខាន់មួយ គឺជាសេចក្តីអធិស្ឋានដ៏ពេញដោយអំណាចចេស្តា សម្រាប់ពួកបរិសុទ្ធទាំងតអស់ ។ សេចក្តីអធិស្ឋានរបស់គាត់គឺបានគ្របបាំងនូវតួនាទីរបស់ព្រះយេស៊ូវ ដែលគង់នៅខាងស្តាំព្រះវរបិតា គឺជាតួនាទីរបស់យើង អំណាចចេស្តារបស់យើង និងការទទួលខុសត្រូវរបស់យើងនោះឯង ។

ព្រះគម្ពីរអេភេសូរ ១:១៨-២៣

### ក. តួនាទីរបស់ព្រះយេស៊ូវ

តាមរយៈលោកសាវ័កប៉ុល នោះព្រះយេស៊ូវទ្រង់បានរស់ពីសុគតឡើងវិញ ទ្រង់បានគង់នៅខាងស្តាំនៃព្រះនៅឯនគរស្ថានសួគ៌ គឺជានគរដែលខ្ពស់លើសជាងទាំងអស់ ទាំងគោលការណ៍ ទាំងអំណាច ឫទ្ធិតេជៈ និងអំណាចគ្រប់គ្រង គឺខ្ពស់លើសជាងទាំងអស់ ដែលអាចត្រូវបានប្រទានពរមកនោះ ព្រមទាំងគ្រប់របស់ទាំងអស់ ដែលនៅពីក្រោមព្រះបាទាទ្រង់ផង ។ ព្រះយេស៊ូវទ្រង់មានអំណាចលើអស់ទាំងអំណាចរបស់ពួកវិញ្ញាណអាក្រក់ ។ ព្រះយេស៊ូវទ្រង់មានគ្រប់ទាំងតួនាទីដែលអាចប្រទាន ឬនឹងអាចប្រទានជាបន្តទៅទៀតបាន ។ គ្រប់ទាំងអស់គឺត្រូវនៅពីក្រោមព្រះបាទារបស់ព្រះយេស៊ូវ ។

### ខ. មាត្រដ្ឋាននៃអំណាចចេស្តា

មានមាត្រដ្ឋាននៃអំណាចចេស្តាពីរយ៉ាង មួយគឺនៅក្នុងគ្រាសញ្ញាចាស់ មួយទៀតគឺនៅក្នុងគ្រាសញ្ញាថ្មី ។

នៅក្នុងគ្រាសញ្ញាចាស់ មាត្រដ្ឋាននៃអំណាចចេស្តា គឺជាចំណែកនៃសមុទ្រក្រហម ។ នៅក្នុងគ្រាសញ្ញាថ្មី មាត្រដ្ឋាននៃអំណាចចេស្តា គឺនៅតែពឹងអាងទៅលើអំណាចនៃការរស់ពីសុគតឡើងវិញរបស់ព្រះយេស៊ូវគ្រីស្ទនោះឯង ។

ព្រះគម្ពីរអេភេសូរ ១:១៩ខ-២០ក

### គ. តួនាទីរបស់ពួកអ្នកជឿ

លោកសាវ័កប៉ុលបានអធិស្ឋានថាពួកអ្នកជឿ គឺត្រូវតែបញ្ចេញនូវពន្លឺ ដែលពួកគេអាចដឹងបាន:

សង្ឃឹមទៅលើការត្រាស់ហៅរបស់ព្រះអង្គ គឺជាភោគសម្បត្តិនៃទ្រង់ដ៏ឧត្តម គឺជាអំណាចចេស្តាដ៏ធំឧត្តមរបស់ទ្រង់នោះឯង ។ យើងរាល់គ្នាគឺជារូបកាយរបស់ព្រះអង្គ ។ យើងមានភាពដ៏ពេញលេញរបស់ព្រះអង្គ ដែលទ្រង់បានបំពេញគ្រប់ទាំងអស់ ។

យើងត្រូវតែមានចំណេះដឹងចំពោះភោគសម្បត្តិនៃទ្រង់ដ៏ឧត្តម ព្រមទាំងអំណាចចេស្តាដ៏ធំឧត្តមរបស់ទ្រង់ សម្រាប់យើងរាល់គ្នាដែលជាអ្នកជឿនោះឯង ។ យើងត្រូវតែអនុវត្តដោយនូវអំណាចចេស្តាដូចគ្នា នឹងអំណាចចេស្តា ដែលព្រះយេស៊ូវទ្រង់បានរស់ពីសុគតឡើងវិញនោះដែរ!

## III. ភាពពេញលេញរបស់ទ្រង់

ប្រសិនបើយើងជាពួកជំនុំរបស់ព្រះអង្គ គឺយើងត្រូវតែបំពេញនូវចន្លោះ ឬក៏មានភាពខ្វះខាតនៅក្នុងព្រះរាជបុត្រារបស់ព្រះ តើភាពខ្វះខាតនោះកើតឡើងនៅពេលណា? ប្រហែលជាភាពខ្វះខាតនេះ ត្រូវត្រឡប់ទៅឯពេលវេលារបស់លូស៊ីហ្វើរទេដឹង ដែលវាបានទទួលការចាក់ប្រេងតាំងធ្វើជាចេរូប៊ីន ដែលជាអ្នកគ្របបាំង ហើយដែលត្រូវបានបណ្តេញចេញពីស្ថានសួគ៌ ជាមួយនឹងពួកទេវតារបស់វា ដែលជាអ្នកដើរតាមវាក្នុងការបះបោររបស់វានោះ ។

ព្រះគម្ពីរអេសេគាល ២៨:១៤

### ក.អ្នកដឹកនាំទេវតា

ភាពជាព្រះត្រៃឯករបស់ព្រះ គឺមានការលេចឡើងជាបីផ្នែកដែលមាននៅក្នុងភាពជាអ្នកដឹកនាំ របស់ពួកទេវតា ។ គឺមានទេវតាមីកែល លូស៊ីហ្វើរ និងកាព្រីយ៉ែល ។

#### ១. មួយភាគបី

នៅពេលដែលលូស៊ីហ្វើរបានបះបោរ ក៏មានការនិយាយថា "ពួកទេវតារបស់វា" គឺត្រូវបានបណ្តេញចេញជា មួយនឹងវាដែរ ។

ព្រះគម្ពីរអេសេគាល ២៨:១៤-១៥

ព្រះគម្ពីរវិវរណៈ ១២:៧-៩

ព្រះគម្ពីរវិវរណៈ១២:៤ក

ពួកទេវតាទាំងនេះបានត្រូវបង្កើតមក សម្រាប់ជាគោលបំណងរបស់ព្រះ ប៉ុន្តែ ឥឡូវនេះ គឺបានដើរតាមសាតាំងទៅវិញ ។

#### ២. ទេវតាមីកែល

មីកែលគឺជាទេវតាតែមួយគត់ ដែលត្រូវធ្វើជាអ្នកបញ្ជូនសារ គាត់គឺជាមហាទេវតាមួយរូប ។

ព្រះគម្ពីរយូដាស ១:៩ក

នោះគឺជាទេវតាមីកែល និង "ពួកទេវតារបស់គាត់" ដែលត្រូវបានធ្វើជាពួកទេវតាចម្បាំង គឺដែល

បានច្បាំងទាស់សាតាំងនោះឯង "គឺជានាគ និងពួកទេវតារបស់វា" ។

ព្រះគម្ពីរវិវរណៈ ១២:៧

ប្រហែលជាមហាទេវតាមីកែល និងទេវតាមួយភាគបីទៀត ដែលនៅក្រោមការបញ្ជារបស់គាត់ ក្នុងការបំពេញព្រះរាជកិច្ចថ្វាយដល់ព្រះវរបិតានោះឯង ។

## ៣. ទេវតាកាព្រីយ៉ែល

ប្រហែលជាកាព្រីយ៉ែលនេះឯង ដែលតែងតែលេចឡើងជាទេវតាអ្នកបញ្ជូនសារ ព្រមទាំងជាទេវតាក្រុមទីបី ក៏មានពួកទេវតាមួយភាគបី ដែលនៅក្រោមការបញ្ជារបស់គាត់ ក្នុងការបំពេញព្រះរាជកិច្ចថ្វាយដល់ព្រះវិញ្ញាណបរិសុទ្ធ ។ គាត់បានលេចឡើងទៅឯលោកសាការី ដែលបានបញ្ជូនសារទៅឱ្យគាត់ ដែលប្រពន្ធគាត់ គឺនាងអេលីសាបិត នឹងត្រូវបង្កើតកូនប្រុសមួយឱ្យគាត់ គឺដែលគាត់នឹងបាន "ពេញដោយព្រះវិញ្ញាណបរិសុទ្ធ ដោយកំណើតកូននោះ" ។

ព្រះគម្ពីរលូកា ១:១៩ ។

ទេវតាកាព្រីយ៉ែលក៏បានលេចឡើង ទៅកាន់ស្រីព្រហ្មចារី ឈ្មោះនាងម៉ារា ។

ព្រះគម្ពីរលូកា ១:៣០-៣១,៣៥ ។

នាងម៉ារាបានសួរថា "តើការនេះអាចនឹងកើតបានដោយរបៀបណា... ខ្ញុំមិនដែលស្គាល់ប្រុសណាផង?"

ទេវតាកាព្រីយ៉ែលបានបើកសម្តែងឱ្យនាងដឹងថាការនោះនឹងកើតពីព្រះវិញ្ញាណបរិសុទ្ធ ។

## ៤. លូស៊ីហ្វើរ

តើអាចនឹងកើតបានឬទេ អញ្ចឹងដែលលូស៊ីហ្វើរ និងពួកទេវតារបស់វា ក្នុងការបំពេញព្រះរាជកិច្ចនៃព្រះរាជបុត្រារបស់ព្រះឬទេ?

លូស៊ីហ្វើរបានបំពេញកិច្ចការងារ ជាអ្នកគ្របបាំង ជាចេរូប៊ីន និងជាចេរូប៊ីនដែលគ្របបាំង គឺជាអ្នកដែលនៅឯទីសន្តោសប្រោស គឺជាការពិពណ៌នាពីវានោះ ។ វាមានសិទ្ធិនៅក្បែរបល្ល័ង្ករបស់ព្រះ ។ ដូចជាយើងបានឃើញនូវការគ្របបាំង គឺជាការបំពេញការងារសរសើរតម្កើង និងការងារថ្វាយបង្គំនោះឯង ។

នៅពេលដែលវាបានបះបោរភ្លាម នោះលូស៊ីហ្វើរ និងពួកទេវតាទាំងអស់របស់វា បានត្រូវបណ្តេញចេញពីស្ថានសួគ៌ចុះមក តើការនេះនឹងត្រូវបានបំពេញដោយរបៀបណា?

តើព្រះវរបិតាទ្រង់បានសុំឱ្យទេវតាមីកែល និងទេវតាកាព្រីយ៉ែល ដាក់ឱ្យធ្វើការងារខ្លះនៃពួកទេវតារបស់វាដែរឬទេ ដើម្បីបំពេញនូវការខ្វះចន្លោះនេះ នៅក្នុងព្រះរាជកិច្ចរបស់ព្រះរាជបុត្រានោះ? យើងមិនមានការកត់ត្រានូវការកើតឡើងនោះទេ ។ តើវាអាចនឹងបានជាដូច្នោះឬទេ ដែលព្រះទ្រង់បានធ្វើឱ្យផែនការរបស់ព្រះអង្គ ឱ្យបានរឹតតែល្អប្រសើរឡើងជាងនេះទៅទៀតនោះ នៅពេលដែលទ្រង់បានបង្កើតមនុស្សជាតិមក ឱ្យមានរូបភាពរបស់ព្រះអង្គនោះ ឱ្យបានជាអ្នកថ្វាយបង្គំដល់ព្រះអង្គ ដើម្បីអង្គុយជាមួយនឹងទ្រង់នៅឯនគរស្ថានសួគ៌ គឺ

ឱ្យនៅខាងព្រះអង្គ និងគ្រប់គ្រងលើ ព្រមទាំងសោយរាជ្យជាមួយនឹងទ្រង់ ដ៏នៅអស់កល្បជានិច្ច នោះឯងឬអី?

## ខ. កន្លែងចន្លោះត្រូវបានបំពេញហើយ

មនុស្សប្រុសស្រី ដែលបានបង្កើតមកនៅក្នុងរូបភាពរបស់ព្រះ គឺអាចត្រឹមតែត្រូវបំពេញបន្ថែម និងត្រូវបំពេញឱ្យបានពេញលេញ ដូចជាទ្រង់ដ៏ជាអ្នកបង្កើតម្តងមកហើយនោះ ពេលដែលទ្រង់បង្កើតម្តងទៀត គឺត្រូវតែផ្លុំខ្យល់ដង្ហើមដោយអង្គទ្រង់បញ្ចូលទៅឱ្យពួកគេ នៅក្នុងពេលភ្លាម១ ដែលពួកគេបានទទួលនូវសេចក្តីសង្គ្រោះនោះ ។ ទ្រង់បំពេញនូវភាពទទេនៅក្នុងជីវិតជាមួយនឹងអង្គទ្រង់ ។ ឥឡូវនេះ រូបកាយរបស់ព្រះអង្គ គឺត្រូវតែបានបំពេញនូវភាពទទេនៅក្នុងទ្រង់ ដោយនូវព្រះរាជកិច្ចនៃការសរសើរ និងការថ្វាយបង្គំ ។

ព្រះគម្ពីរកិច្ចការ ១៣:១-៣

កាលដើមដំបូងឡើយ មានតែការងារមួយនេះទេ គឺជាការងារសរសើរ និងការងារថ្វាយបង្គំ ។ នៅពេលដែលមានការងារជាច្រើន ដែលត្រូវបានបញ្ញប់ គឺដោយសារការចាំបាច់ ដូចជាការងារប្រោសឱ្យជាការងាររំដោះ ការងារផ្សះផ្សា ការងារកែជាថ្មីឡើងវិញ និងការងារដទៃទៀត ។

តើវាបានជាយ៉ាងដូច្នោះឬទេ ដែលការងារសរសើរ និងការងារថ្វាយបង្គំត្រូវបានកែជាថ្មីឡើងវិញ ដល់ពួកជំនុំនោះ រីឯការងារដទៃទៀតនេះ នឹងមិនមែនជាការចាំបាច់ដ៏យូរលង់ ដែលនៅក្នុងរូបកាយរបស់ព្រះគ្រីស្ទ ដូចជាពួកគេមាននៅសព្វថ្ងៃនេះឬទេ?

នៅពេលដែលយើងចំណាយពេលបំពេញការងារ បន្ថែមហើយបន្ថែមទៀត នៅក្នុងការសរសើរ និងការថ្វាយបង្គំដល់ព្រះ នោះយើងនឹងរុករកឱ្យឃើញថា មានសេចក្តីត្រូវការសម្រាប់ការប្រោសឱ្យជា ឬការរំដោះ ឬការបំពេញកិច្ចការងារដទៃទៀតនៅក្នុងជីវិតរបស់យើង ដែលមិនទាន់មានការលូតលាស់ ។

យើងគឺជាមនុស្សសំខាន់របស់ព្រះ! យើងត្រូវតែបានពេញលេញនៅក្នុងទ្រង់ ។ យើងត្រូវតែបំពេញការងារដល់ទ្រង់ក្នុងការសរសើរ និងការថ្វាយបង្គំនេះ ។ ដោយការធ្វើយ៉ាងដូច្នោះ នោះយើងជារូបកាយរបស់ព្រះអង្គ គឺត្រូវត្រឡប់មកជា "ភាពពេញលេញរបស់ព្រះអង្គ ដែលជាអ្នកបំពេញគ្រប់ទាំងអស់លើទាំងអស់" ។ ព្រះគម្ពីរអេភេសូរ ១:២២-២៣ ។

យើងជាអ្នកសរសើរ និងជាអ្នកថ្វាយបង្គំព្រះ នោះយើងមិនត្រូវបំពេញតែទៅតាមទម្រង់មុខងាររបស់លូស៊ីហ្វើរ និងពួកទេវតារបស់វានោះទេ គឺយើងត្រូវតែសម្តែងពីសេចក្តីពិតដែលពួកគេត្រូវទទួលនូវការបរាជ័យ ហើយគេគ្មានកន្លែងនៅឯនគរស្ថានសួគ៌នោះទៀតឡើយ ។ យើងត្រូវធ្វើឱ្យពួកវាទាបចុះទៅ ព្រមទាំងដាក់ពួកវាឱ្យនៅពីក្រោមជើងរបស់យើង ។ នៅពេលដែលយើងរាំនៅចំពោះព្រះអម្ចាស់នោះយើងត្រូវតែជាន់សាតាំងឱ្យវាបរាជ័យ ដោយប្រើជើងរបស់យើង ។ សាតាំងបានត្រូវបរាជ័យហើយ ។

កំណត់ចំណាំៈ ចំពោះការសិក្សាឱ្យបានកាន់តែជ្រៅជាងនេះទៅទៀតពីសៀវភៅ **ការសរសើរ និងការថ្វាយបង្គំ** ដោយលោក អេ.អែល និង ចយ ហ្គីល ។

## IV. តើការនេះមានន័យដូចម្តេចដល់យើង

តាមរយៈការងាររបស់ព្រះយេស៊ូវនៅលើឈើឆ្កាង និងតាមរយៈព្រឹត្តិការណ៍ ជាបន្តបន្ទាប់ នោះសាតាំងបានត្រូវ

ទទួលនូវការបរាជ័យហើយ! រាល់ទាំងវិញ្ញាណអាក្រក់ក៏បានទទួលនូវការបរាជ័យដែរ! ព្រះយេស៊ូវទ្រង់ធ្វើឱ្យពួកវា ត្រូវបានទទួលនូវការបរាជ័យ និងបានធ្វើឱ្យពួកវាគ្មានអ្វីទាំងអស់! ទ្រង់បានធ្វើឱ្យពួកវាបានទៅជា "លេខសូន្យ" ដ៏ធំ ។ ហេតុអ្វីបានជាយើងនៅតែអនុញ្ញាត ឱ្យពួកវាចាប់យកនូវផ្ទះរបស់យើងចេញពីយើងទៅវិញបាន ទាំងទីក្រុងរបស់យើង និងជាតិសាសន៍របស់យើងនោះ? ហេតុអ្វីបានជាយើងនៅតែអនុញ្ញាតឱ្យវាដាក់ជម្ងឺមកលើយើងបាន? ហេតុអ្វីបានជាយើងទទួលនូវភាពទ័លក្រ?

ចម្លើយនោះគឺ យើងត្រូវតែសិក្សាឱ្យបានយល់ដឹងពីអ្នកដែលយើងបាននៅក្នុងព្រះយេស៊ូវ ហើយអ្វីដែលយើងបានត្រូវទទួលនូវការប្រទានពរមកឱ្យបាននៅក្នុងព្រះយេស៊ូវគ្រីស្ទ ។ យើងត្រូវតែរុករកឱ្យឃើញ នូវសិទ្ធិអំណាចដែលបានកែជាថ្មីឡើងវិញរបស់យើងនោះ ។

## ក. យើងត្រូវបានរំដោះហើយ!

នៅពេលដែលលោកសាវ័កប៉ុល បានសរសេរចែងទុកមកនៅក្នុងព្រះគម្ពីរកូល៉ុស នោះគាត់បានមានប្រសាសន៍ថា យើងបានទទួលនូវៈ ការរំដោះ ការបកប្រែ ការប្រោសលោះ ការអត់ទោស ( ព្រះគម្ពីរកូល៉ុស ១:១៣-១៤ ) ។

## ខ. នគរ គឺនៅទីនេះហើយ

តើនគររបស់ព្រះរាជបុត្រា គឺជាអ្វី? យើងបានទទួលនូវការបកប្រែមកហើយ នៅក្នុងការតឹងតែងពីអតីតកាល ។ នៅពេលដែលព្រះយេស៊ូវ ទ្រង់បានបង្រៀនដល់ពួកសិស្សឱ្យអធិស្ឋាន នោះទ្រង់បានអធិស្ឋាននូវពាក្យទាំងនេះ:

ព្រះគម្ពីរម៉ាថាយ ៦:១០

នគររបស់ព្រះ គឺមិនមែនជាការបញ្ចេញបញ្ចូលទៅក្នុងពេលអនាគតនោះទេ ។ គឺអធិស្ឋាននៅពេលឥឡូវនេះ ។ យើងបានទទួលនូវការរំដោះ ចេញពីអំណាចគ្រប់គ្រងរបស់សេចក្តីងងឹត ហើយបាននាំចូលទៅក្នុងនគររបស់ព្រះរាជបុត្រានៃព្រះ តាមរយៈការប្រោសលោះ និងការអត់ទោសនូវអំពើបាបរបស់យើង ។

ចំពោះចំណេះដឹងនៃសិទ្ធិអំណាច ដែលបានកែជាថ្មីឡើងវិញ នោះយើងអាចបានត្រឡប់មកជាការពេញដោយកងកម្លាំងប្រុសស្រី ដែលនឹងមានជាផ្នែកសំខាន់ៗក្នុងការឱ្យដំបូន្មានដ៏មានកម្លាំងខ្លាំងក្លានៅនគរស្ថានសួគ៌ ក៏ដូចជានៅលើផែនដីនេះដែរ ។

ព្រះគម្ពីរម៉ាថាយ ១១:១២

លោកសាវ័កប៉ុលបានបន្ត ជាមួយនឹងការពណ៌នាពីព្រះយេស៊ូវដ៏អស្ចារ្យ ។

ព្រះគម្ពីរកូល៉ុស ១:១៥-១៨

## គ. ព្រះយេស៊ូវគឺជាប្រមុខរបស់យើង

ព្រះយេស៊ូវៈ គឺជារូបភាពរបស់ព្រះ ជាអ្នកបង្កើតគ្រប់របស់ទាំងអស់ ទ្រង់គង់នៅមុនរបស់ទាំងអស់ ទ្រង់បានទ្រទ្រង់គ្រប់របស់ទាំងអស់ ទ្រង់គឺជាប្រមុខនៃរូបកាយពួកជំនុំ ទ្រង់គឺជាដើម ទ្រង់គឺជាអ្នកដែលបានរស់ឡើងវិញជាមុនដំបូងក្នុងចំណោមពួកអ្នកស្លាប់ទាំងអស់ ។ ព្រះយេស៊ូវគឺជាប្រមុខរបស់យើង ។ យើងគឺជារូបកាយរបស់ព្រះអង្គនៅលើផែនដីនេះ ។ រូបកាយរបស់ព្រះអង្គគឺត្រូវតែបានបង្កើតពួកអ្នកជឿទាំងអស់ ។ យើងជារូបកាយរបស់ព្រះអង្គ គឺយើងត្រូវតែបានទទួលនូវការពណ៌នា ជាអ្នកដែលត្រូវបានទទួលនូវការ

ជួយឱ្យរួចពីគ្រោះថ្នាក់ ពីអំណាចគ្រប់គ្រងរបស់សាតាំង និងពីការកែប្រែឱ្យបានចូលទៅក្នុងនគរថ្មី ដែលយើងបានសោយរាជ្យដោយអំណាចគ្រប់គ្រង ជាមួយនឹងព្រះយេស៊ូវដ៏ជាព្រះរាជបុត្រារបស់ព្រះរួចទៅហើយ ។ យើងគឺត្រូវបានទទួលនូវការពណ៌នា ជាអ្នកបានទទួលនូវការប្រោសលោះ ជាអ្នកបានទទួលនូវការអត់ទោសដ៏ពេញលេញ ពីគ្រប់អាទាំងអំពើបាបហើយ ។

ព្រះយេស៊ូវ ទ្រង់ជាប្រមុខនៃរូបកាយ នៅក្នុងនគរស្ថានសួគ៌ ។ រូបកាយរបស់ទ្រង់ដែលសល់នៅ គឺរួមបញ្ចូលទាំងព្រះបាទារបស់ទ្រង់ គឺកំពុងតែនៅលើផែនដីនេះ ។ វាកំពុងតែនៅលើផែនដីនេះ គឺដែលមនុស្សត្រូវតែបំពេញ តាមមុខងារនៃអំណាចគ្រប់គ្រងរបស់គេឱ្យបានរឹងមាំនោះឯង ។ វាគឺនៅទីនេះហើយ ដែលយើងត្រូវតែឱ្យដំបូន្មានយ៉ាងរឹងប៉ឹង ពីនគររបស់ព្រះ ដោយការខិតខំធ្វើសង្គ្រាមខាងឯវិញ្ញាណនោះឯង ។

## V. តួនាទីរបស់សាតាំង

### ក. នៅពីក្រោមព្រះបាទារបស់ព្រះយេស៊ូវ

ព្រះទ្រង់បានដាក់សាតាំង ឱ្យនៅពីក្រោមព្រះបាទារបស់ព្រះយេស៊ូវ ព្រមទាំងបានដៅព្រះយេស៊ូវឱ្យបានធ្វើជាប្រមុខលើការទទួលខុសត្រូវគ្រប់យ៉ាង នៅក្នុងពួកជំនុំ ។

ព្រះគម្ពីរអេភេសូរ ១:២២

### ខ.នៅពីក្រោមជើងរបស់យើង

ព្រះគម្ពីររ៉ូម ១៦:២០ក

ដើម្បីធ្វើឱ្យបាននៅពីក្រោមជើងរបស់អ្នកណាម្នាក់ នោះគឺជារូបភាពមួយនៃការដណ្តើមយកជ័យទាំងស្រុង ធ្វើឱ្យគេទទួលនូវការបរាជ័យ និងបានទទួលនូវជ័យជម្នះទាំងស្រុង ។ វាគឺជារូបភាពនៃសិទ្ធិអំណាច និងអំណាចគ្រប់គ្រងដ៏រឹងមាំនោះឯង ។

ព្រះគម្ពីរលោកុប្បត្តិ ៣:១៥

### គ. នៅក្រោមសិទ្ធិអំណាចរបស់យើង

សាតាំងគឺបាននៅក្រោមព្រះបាទារបស់ព្រះយេស៊ូវ ពីព្រោះព្រះយេស៊ូវទ្រង់បានធ្វើឱ្យវាទទួលបរាជ័យដ៏ពេញលេញ ព្រមទាំងពពួកវិញ្ញាណអាក្រក់ទាំងអស់ របស់វានោះឯង ។ សាតាំងនិងពួកវិញ្ញាណអាក្រក់របស់វា នៅពេលឥឡូវនេះ គឺត្រូវតែបានដាក់ឱ្យនៅពីក្រោមជើងរបស់យើង គឺនៅពេលដែលយើងបានរុករកឃើញ នូវសិទ្ធិអំណាចដែលបានកែជាថ្មីរបស់យើង និងបានចាប់ផ្តើមប្រើប្រាស់សិទ្ធិអំណាចនោះនៅលើផែនដីនេះ ។

### ឃ.ការជាន់ឈ្លីពីលើ

លោកលូកាបានផ្តល់ឱ្យយើង នូវរូបភាពយ៉ាងច្បាស់លាស់ពីតួនាទីរបស់សាតាំង ។ វាត្រូវតែបានទទួលនូវការជាន់ឈ្លីនៅពីក្រោមជើងរបស់យើង ។ យើងក៏ត្រូវតែបានទទួលនូវសេចក្តីសន្យាថា គ្មានអ្វីណាមួយនឹងធ្វើឱ្យយើងមានការចុកចាប់បានឡើយ ។ ព្រះគម្ពីរលូកា ១០:១៩ ។

មនុស្សជាតិបានត្រូវទទួលនូវការជួយ ឱ្យរួចពីគ្រោះថ្នាក់ គឺបានត្រូវនាំចូលមកទទួលការប្រោសលោះ ការអត់ទោស និងការកែជាថ្មីដ៏ពេញលេញឡើងវិញ ឱ្យបានជារូបភាពរបស់ព្រះនៅលើផែនដីនេះ ។ ការងាររបស់យើងឥឡូវនេះគឺត្រូវតែជាន់សាតាំងឱ្យនៅពីក្រោមព្រះបាទារបស់ទ្រង់ ព្រមទាំងធ្វើការសម្តែងថា វាគឺជាខ្មាំងសត្រូវដែលបានទទួបរាជ័យហើយ ។

ពេលដែលហោរាអេសាយបានពណ៌នា ពីចុងបំផុតរបស់សាតាំង នោះគាត់បាននិយាយយោងទៅលើលក្ខណៈរបស់វាគឺត្រូវតែបាននៅពីក្រោមជើងរបស់យើង ។

ព្រះគម្ពីរអេសាយ ១៤:១៨-២០

## VI. ច្រវាក់នៃការបញ្ជា

**ក. ពេលដែលព្រះយេស៊ូវទ្រង់បានលើកឡើង ទៅឯព្រះវរបិតារបស់ទ្រង់** នោះទ្រង់បានគង់នៅខាងស្តាំរបស់ព្រះអង្គជាកូនមនុស្ស ហើយក៏បានចាប់យកមកវិញ នូវសិទ្ធិជាព្រះរាជបុត្រារបស់ព្រះ ដោយព្រះអង្គទ្រង់ផ្ទាល់ ។

**ខ. សិទ្ធិនៅលើផែនដីរបស់មនុស្ស**

ព្រះយេស៊ូវទ្រង់គឺជាព្រះ ទ្រង់មិនចាំបាច់ហាត់សមប្រើនូវអំណាចគ្រប់គ្រងនៅលើផែនដីនេះទេ ពីព្រោះការនេះទ្រង់ប្រទានអំណាចគ្រប់គ្រងលើមនុស្សហើយ ។

វាគឺជាមនុស្សដែលត្រូវតែដាក់សាតាំង ឱ្យនៅពីក្រោមជើងរបស់គេនៅលើផែនដី គឺនៅពេលដែលត្រូវបានបង្កើតមកឱ្យធ្វើការនោះហើយ ។

ហោរាអេសាយបានផ្តល់ឱ្យយើងនូវការដ៏អស្ចារ្យ គឺជាហោរាដែលមានការលើទឹកចិត្ត ។ នៅក្នុងភាពសុចរិត លោកអ្នកត្រូវតែបានទទួលនូវការសម្រេច ។ ការកៀបសង្កត់នឹងត្រូវតែបាននៅឆ្ងាយពីលោកអ្នក ។ លោកអ្នកនឹងគ្មានការភ័យខ្លាចអ្វីឡើយ ។ ភាពភ័យខ្លាំងនឹងមិនជ្រៀតចូលមកដល់មកជិតលោកអ្នកឡើយ ។ ប្រសិនបើមានអ្នកណាម្នាក់ចូលមកប្រយុទ្ធជាមួយ នោះពួកគេនឹងត្រូវបានចុះចូលវិញ ។ គ្មានទម្រង់នៃយុទ្ធភ័ណ្ឌណា មកប្រឆាំងទាស់នឹងលោកអ្នកបានឡើយ ។ លោកអ្នកនឹងអាចបដិសេធពីគ្រប់ទាំងអណ្តាតដែលចូលមកទាស់ទទឹងនឹងលោកអ្នក ។

ព្រះគម្ពីរអេសាយ ៥៤:១៤-១៧

កេរ្តិ៍មតិករបស់យើងគឺជាកម្មសិទ្ធិដល់យើង ដោយសិទ្ធិពីកំណើតនោះឯង ។ ពេលដែលយើងបានកើតជាថ្មី នោះយើងបានកើតម្តងទៀតហើយ ។ នេះជាមតិករបស់យើងនៅក្នុងព្រះគ្រីស្ទ ។

ហោរាអេសាយបានទាយទុកមកថា :

**នេះគឺជាមតិករបស់អ្នកបម្រើនៃព្រះអម្ចាស់!**

## VII. តើមានការអ្វីកើតឡើង?

**ជាងពីរពាន់ឆ្នាំក្រោយមក**
**សាតាំងបានក្លែងសិទ្ធិអំណាចនោះ ។**

***ជាងពីរពាន់ឆ្នាំក្រោយមកយើងបានឃើញៈ***
***មនុស្សមិនអាចរស់នៅ***
***ដោយគ្មានព្រះនាមព្រះយេស៊ូវបានឡើយ ។***
***មនុស្សរស់នៅក្នុងភាពក្រីក្រ***
***មនុស្សរស់នៅក្នុងអំពើបាប***
***មនុស្សរស់នៅក្នុងភាពបរាជ័យ***
***មនុស្សតែងទទួលបាននូវការលែងលះគ្នា***
***មនុស្សមានកូនចៅដែលលង់ក្នុងគ្រឿងញៀន***
***មនុស្សថ្វាយបង្គំនៅក្នុងសេចក្តីងងឹត ។***

***ហេតុអ្វីបានជាសាតាំងនៅតែបញ្ចេញសកម្មភាព***
***ដូចជាវាគឺជាព្រះរបស់លោកិយនេះអញ្ចឹង?***

***វាត្រូវបានទទួលនូវការបរាជ័យដោយព្រះយេស៊ូវ ហើយទ្រង់បានធ្វើឱ្យវាគ្មានអំណាចទៀតឡើយ ។ ព្រះយេស៊ូវទ្រង់បានធ្វើសម្រេចនូវចំណែករបស់ទ្រង់ ក្នុងការរំដោះយើងយកមកវិញហើយ!***

***តើយើងបានធ្វើនូវចំណែករបស់យើង ដោយនូវអំណាចរបស់យើង អំណាចគ្រប់គ្រងរបស់យើង សិទ្ធិអំណាចរបស់យើងហើយឬនៅ?***

## VIII. យុទ្ធសាស្ត្ររបស់សាតាំង

### ក.លួច សម្លាប់ ហើយបំផ្លាញ

តាមរយៈគ្រប់ទាំងអាយុកាល បំណងរបស់សាតាំងគឺមិនដែលមានការផ្លាស់ប្តូរឡើយ ។ ព្រះគម្ពីរយ៉ូហាន ១០:១០ក

អារក្សស្អប់យើងរាល់គ្នាជាខ្លាំងដល់ម្ល៉េះ ដែលវាបានផ្តល់ឱ្យជាលំដាប់លំដោយតាមរយៈបុណ្យស័ក្តិ នៃកងកម្លាំងផ្នែកវិញ្ញាណអាក្រក់របស់វា ដើម្បីលួច សម្លាប់ និងបំផ្លាញនោះឯង! ឧបករណ៍ដែលនាំឱ្យមានជាបញ្ហាដើម្បីប្លន់យកពីយើងនូវភាពចាំបាច់ក្នុងការរស់នៅ និងការបំពេញការងាររបស់យើងនោះឯង ។ ការជាលំដាប់លំដោយដែលនាំឱ្យមានបញ្ហានោះគឺក្នុងការសម្លាប់យើង តាមរយៈវិញ្ញាណពិការភាព វិញ្ញាណឃាតករ និងវិញ្ញាណអត្តឃាត ។ គ្រោះថ្នាក់ដែលប្រកបដោយទុក្ខភ័យគឺវាត្រូវតែខឹតខំប្រឹងប្រែងធ្វើ មកលើជីវិតរបស់យើង ។ អារក្សធ្វើឱ្យមានបញ្ហាតាមកម្រិតរបស់វា "ទោះជាធ្វើអ្វីក៏ដោយ ពួកវាត្រូវបានទទួលនូវការវិនាស!"

ប្រសិនបើពពួកវិញ្ញាណអាក្រក់ គ្មានលទ្ធភាពនឹងសម្លាប់យើងបាន នោះប្រហែលជាពួកវាអាចធ្វើការាយការណ៍ថាពួកវាបានពន្យឺតយើង បញ្ឈប់យើងពីការធ្វើបានសម្រេច នូវការងារដែលបានប្រទានមកពីព្រះរបស់យើងនោះដែរ ។

### ខ. ការដាក់វិញ្ញាណពិការភាព

សាតាំងបានខឹតខំប្រឹងប្រែង ដើម្បីលួចសុខភាពរបស់យើង ដោយការប្រើពួកវិញ្ញាណពិការភាពដ៏អាក្រក់នោះឯង ។

ព្រះគម្ពីរលូកា ១៣:១១-១៣

ព្រះគម្ពីរយ៉ូហាន ៥:៥

សាតាំងនឹងធ្វើការគ្រប់យ៉ាង ដែលវាអាចបំផ្លាញដល់យើងបាន ។

### គ. ដើម្បីក្បៀបសង្កត់ ធ្វើឱ្យវល់គំនិត បៀតបៀន

លោកសាវ័កប៉ុលបានពណ៌នា ពីការប្រយុទ្ធរបស់សាតាំងទៅលើជីវិត និងការបំពេញការងាររបស់យើង ។ វាគឺជាការលើកទឹកចិត្ត ដើម្បីឱ្យយល់ឃើញថា សាតាំងបានខឹតខំប្រឹងប្រែងគ្រប់ការទាំងអស់ ដើម្បីឱ្យបានទម្លាក់ចុះ និងបញ្ឈប់នូវការងារបម្រើដល់ព្រះអម្ចាស់របស់លោកសាវ័កប៉ុលនោះឯង ។

ព្រះគម្ពីរ ២កូរិនថូស ៤:៨-៩

សាតាំងខឹតខំប្រយុទ្ធពីគ្រប់ការទាំងអស់ ដែលល្អនិងមានវិជ្ជមាននៅក្នុងជីវិតរបស់យើង អាពាហ៍ពិពាហ៍ កូនចៅ ក្រុមគ្រួសារ មិត្តភក្តិ ការងារ សុខភាព សេចក្តីអំណរ និងសេចក្តីសុខសាន្តរបស់យើង ។

## IX. ការការពាររបស់យើង

### ក. ស្គាល់យុទ្ធសាស្ត្ររបស់ខ្មាំងសត្រូវ

មនុស្សប្រុសស្រីមានការវិនាស និងខ្វះខាតនូវចំណេះដឹង ។ ប្រសិនបើពួកគេមានបំណងនឹងបញ្ឈប់សាតាំង ពី

គោលដៅនៃការលួច សម្លាប់ និងបំផ្លាញរបស់វា នោះពួកគេត្រូវតែដឹង ស្គាល់នូវខ្មាំងសត្រូវ និងយុទ្ធសាស្ត្ររបស់វានោះឯង ។

**១. សាតាំងនាំមកនូវសេចក្តីស្លាប់ ។**

**២. ព្រះទ្រង់បាននាំមកនូវជីវិត ។**

**៣. សាតាំងនាំមកនូវសេចក្តីសម្អប់ ។**

**៤. ព្រះទ្រង់នាំមកនូវសេចក្តីស្រឡាញ់ ។**

**ខ. ព្រះយេស៊ូវ**

**១. ទ្រង់បំផ្លាញសេចក្តីស្លាប់**

ព្រះយេស៊ូវទ្រង់បានបំផ្លាសេចក្តីស្លាប់ ហើយនាំមកនូវជីវិត និងភាពអមតៈ ។

ព្រះគម្ពីរ ២ធីម៉ូថេ ១:១០

**២. បំផ្លាញអំណាចអារក្ស**

ព្រះយេស៊ូវទ្រង់បានបំផ្លាញអារក្ស និងដោះយើងឱ្យមានសេរីពីការភ័យខ្លាចនឹងសេចក្តីស្លាប់ ។

ព្រះគម្ពីរហេព្រើរ ២:១៤-១៥

## ក្រុមពិភាក្សា

១. មានមាត្រដ្ឋាននៃអំណាចពីរយ៉ាង ទីមួយគឺមាននៅក្នុងគ្រាសញ្ញាចាស់ មួយទៀតគឺមាននៅក្នុងគ្រាសញ្ញាថ្មី ។ ហេតុអ្វីបានជាមាត្រដ្ឋាននៃអំណាច នៅគ្រាសញ្ញាចាស់មាន ចំណែកនៅក្នុងសមុទ្រក្រហម?

២. ក្នុងការបំពេញព្រះរាជកិច្ចនៃការសរសើរ និងការថ្វាយបង្គំ គឺត្រូវបានកែជាថ្មីឡើងវិញដល់ពួកជំនុំ ហេតុអ្វីបានជាការបំពេញការងារដទៃទៀត មិនមែនជាការចាំបាច់ដ៏យូរលង់តទៅ?

៣. តើអ្វីទៅដែលត្រូវបានទទួលស្គាល់ នៅពេលដែលពួកអ្នកជឿសរសើរ ថ្វាយបង្គំ និងរាំនៅចំពោះព្រះអម្ចាស់?

## ការសិក្សាដោយខ្លួនឯង

១. ចំណេះដឹងពីសិទ្ធិអំណាច ដែលបានកែជាថ្មីរបស់លោកអ្នក គឺត្រូវតែជួយបង្កើតលោកអ្នកឱ្យបានចាមនុស្សពេញកម្លាំង ដែលនឹងបានជាផ្នែកមួយក្នុងការឱ្យដំបូន្មាន នៅនគរស្ថានសួគ៌ ។ តើមធ្យោបាយអ្វីខ្លះដែលលោកអ្នកអាចដើរនៅក្នុងសិទ្ធិអំណាច ដែលបានកែជាថ្មីរបស់លោកអ្នក ពីមួយថ្ងៃទៅមួយថ្ងៃនោះ?

២. តើតំបន់អ្វីខ្លះនៅក្នុងជីវិតរបស់លោកអ្នក ដែលលោកអ្នកមានអារម្មណ៍ថា សាតាំងបានធ្វើការប្រកួតនឹងលោកអ្នក?

   ក. តើមានការបើកសម្តែងអ្វីទៅ អ្វីខ្លះ ប្រសិនបើមានតើលោកអ្នកបានទទួលពីតំបន់ណា បន្ទាប់ពីបានស្តាប់នូវមេរៀននេះ?

   ខ. តើលោកអ្នកត្រូវមានគាក់ទិចអ្វីខ្លះ ដើម្បីរៀបចំគម្រោងប្រយុទ្ធប្រឆាំងជាមួយនឹងសាតាំងពេលនេះ?

៣. តើលោកអ្នកអាចបំពេញ នូវមុខងារនៃអំណាចគ្រប់គ្រងដ៏រឹងមាំរបស់លោកអ្នក នៅលើផែនដីនេះ?

# សិទ្ធិអំណាចរបស់អ្នកជឿ

## *មេរៀនទី ៥: យុទ្ធសាស្ត្ររបស់សាតាំងសម័យសព្វថ្ងៃនេះ*

### I. ការការពាររបស់យើង

#### ក. ការស្គាល់ពីយុទ្ធសាស្ត្ររបស់ខ្មាំងសត្រូវ

ព្រះគម្ពីរ ១ពេត្រុស ៥:៨

មនុស្សប្រុសស្រីតែងមានការវិនាស និងការខ្វះខាតនូវចំណេះដឹង ។ ប្រសិនបើពួកគេមានបំណងនឹងបញ្ឈប់សាតាំងពីគោលបំណងនៃការលួច សម្លាប់ និងបំផ្លាញរបស់វា នោះពួកគេត្រូវតែដឹងស្គាល់នូវខ្មាំងសត្រូវ និងយុទ្ធសាស្ត្ររបស់វា ។ សាតាំងមិនដែលបានទទួលនូវការសម្រេចឡើយ ។ រីឯព្រះយេស៊ូវទ្រង់បានយាងមក ដើម្បីប្រទាននូវជីវិតដ៏បរិបូរដល់គ្រប់គ្នាដែលស្គាល់នូវព្រះបន្ទូលរបស់ព្រះនោះឯង ។

#### ខ. ព្រះយេស៊ូវ

##### ១. ទ្រង់បំផ្លាញសេចក្តីស្លាប់

ព្រះយេស៊ូវទ្រង់បានបំផ្លាសេចក្តីស្លាប់ ហើយនាំមកនូវជីវិត និងភាពអមតៈ ។ ដំណឹងល្អ គឺដែលព្រះយេស៊ូវទ្រង់បានលុបចោល នូវសេចក្តីស្លាប់នោះឯង ។

ព្រះគម្ពីរ ២ធីម៉ូថេ ១:១០

##### ២. បំផ្លាញអំណាចអារក្ស

ព្រះយេស៊ូវទ្រង់បានបំផ្លាញអារក្ស និងដោះយើងឱ្យមានសេរីពីការភ័យខ្លាចនឹងសេចក្តីស្លាប់ ។ យើងមានចម្លើយនៅក្នុងព្រះបន្ទូលរបស់ព្រះ ។

ព្រះគម្ពីរហេព្រើរ ២:១៤-១៥

##### ៣. ការរំដោះចេញពីភាពជាទាសករ

សាតាំងគ្មានសិទ្ធិនឹងទុកយើង ឱ្យនៅជាទាសករបានឡើយ ។ តាមរយៈសេចក្តីជំនឿលើព្រះយេស៊ូវគ្រីស្ទ នោះយើងបានរំដោះចេញពីចំណងជាទាសភាពពីនគររបស់សាតាំងនោះហើយ ។ នៅពេលដែលសាតាំង ឬពួកវិញ្ញាណអាក្រក់របស់វាបានចូលមកលួច សម្លាប់ និងបំផ្លាញ នោះពួកវាមិនត្រូវរកយើងឃើញ ដើម្បីធ្វើឱ្យយើងមានការឈឺចាប់ គ្មានការការពារ ឬក៏គ្មានភាពការពារនោះឡើយ ។ ជំនួសឱ្យនូវការនេះ គឺតាមរយៈចំណេះដឹងពីព្រះបន្ទូលរបស់ព្រះ នោះយើងត្រូវតែរកឱ្យឃើញ នូវការគ្របបាំងដោយព្រះលោហិតរបស់ព្រះយេស៊ូវ ។ យើងត្រូវតែឈរឱ្យរឹងមាំ ដោយមានខែលនៃសេចក្តីជំនឿរបស់យើង ។ ព្រះបន្ទូលរបស់ព្រះតាមរយៈលោកហោរាអេសាយ ៥៤:១៧ក ។

ព្រះគម្ពីរអេភេសូរ ៦:១១ និង ៦:១៦

យើងត្រូវការស្គាល់នូវព្រះបន្ទូលរបស់ព្រះ ។

### II. ការប្លន់ដ៏ធំចម្បងរបស់សាតាំងមកលើព្រះបន្ទូលព្រះ

#### ក. ចូរសម្លៀងដាវរបស់អ្នកនៅចង្កេះ

ប្រសិនបើយើងមិនមានព្រះបន្ទូលរបស់ព្រះ នៅក្នុងគំនិតនិងវិញ្ញាណរបស់យើងទេ នោះយើងមិនអាចធ្វើឱ្យសាតាំងនិងអ្នកដើរតាមវានៅក្នុងលោកិយនេះ ត្រូវចុះចាញ់ឡើយ ។ ព្រះយេស៊ូវទ្រង់សព្វព្រះហឫទ័យចង់ឱ្យយើង មានជីវិតពេញបរិបូរក្នុងការដើរគ្រប់ទាំងអស់ នៅក្នុងជីវិតរបស់យើង ។ ប្រសិនបើយើងមិនមានរបស់ទាំងនេះទេ នោះយើងនឹងត្រូវ

សាតាំងប្លន់យកទៅបានហើយ ។ យើងត្រូវតែស្គាល់អ្នកដែលយើងហៅមកឱ្យនៅក្នុងព្រះគ្រីស្ទ ដើម្បីបញ្ជាក់ថា យើងបានទទួលនូវជ័យជម្នះក្នុងសង្គ្រាមនេះហើយ!

***ការប្រៀបធៀបពីកសិករៈ គឺជាការបើកសម្តែងពីជ័យជម្នះ ។***

***ការប្រៀបធៀបៈ ព្រះគម្ពីម៉ាកុស ៤:៣-៨***

***"ចូរស្តាប់ចុះ មើល មានអ្នកព្រោះពូជម្នាក់ចេញទៅព្រោះ***
***កំពុងដែលព្រោះ មានខ្លះធ្លាក់ចុះតាមផ្លូវ***
***ហើយសត្វហើរលើអាកាសក៏មកចឹកស៊ី***
***ខ្លះទៀតធ្លាក់ទៅក្នុងកន្លែងថ្ម ដែលមិនសូវមានដីប៉ុន្មាន***
***ហើយក៏ដុះឡើងភ្លាម ពីព្រោះគ្មានដីជ្រៅ តែកាលថ្ងៃរះឡើង***
***នោះក្រៀមខ្លោចទៅវិញ ពីព្រោះគ្មានឫស***
***ខ្លះទៀតធ្លាក់ទៅក្នុងបន្លា បន្លាក៏ដុះឡើងខ្ទប់***
***ហើយគ្រាប់នោះមិនកើតផលសោះ***
***តែខ្លះទៀតធ្លាក់ទៅក្នុងដីល្អ ក៏កើតលចំរើនកាន់តែច្រើនឡើង គ្រាប់១បង្កើតបាន៣០ មួយបាន៦០ ហើយមួយបាន១រយ"***

***ព្រះយេស៊ូវទ្រង់ក៏បានពន្យល់ពីពាក្យប្រៀបប្រដូចនោះៈ***
***នៅក្នុងព្រះគម្ពីរម៉ាកុស ៤:១៤-៤០ ចែងថាៈ***
***"ឯអ្នកព្រោះពូជ គឺព្រោះព្រះបន្ទូល ឯពួកអ្នកតាមផ្លូវ***
***គឺជាកន្លែងដែលបានព្រោះព្រះបន្ទូលចុះ កាលគេឮ***
***នោះអារក្សសាតាំងក៏មកលួចឆក់យកព្រះបន្ទូល***
***ដែលព្រោះក្នុងចិត្តគេទៅភ្លាម***
***ឯពួកអ្នកដែលទទួលពូជក្នុងកន្លែងថ្មក៏ដូចគ្នាដែរ***
***កាលណាគេឮព្រះបន្ទូល នោះគេទទួលភ្លាមដោយអំណរ***
***តែគ្មានចាក់ឫសនៅក្នុងខ្លួនសោះ ហើយក៏នៅជាប់តែបន្តិចទេ***
***បើកាលណាកើតមានសេចក្តីទុក្ខលំបាក***
***ឬសេចក្តីបៀតបៀនដោយព្រោះព្រះបន្ទូល***
***នោះគេរវាតចិត្តចេញភ្លាម ឯពួកអ្នកដែលទទួលពូជក្នុងបន្លា***
***គឺអស់អ្នកដែលបានឮព្រះបន្ទូលហើយ***
***តែសេចក្តីខ្វល់ខ្វាយនៅជីវិតនេះ***
***សេចក្តីឆបោករបស់ទ្រព្យសម្បត្តិ***
***និងសេចក្តីប៉ងប្រាថ្នាខាងឯសេចក្តីផ្សេងៗឯទៀត***
***ក៏ចូលមកខ្ទប់ព្រះបន្ទូលជិត***
***រួចព្រះបន្ទូលមិនអាចនឹងបង្កើតផលបាន***
***ឯពួកអ្នកដែលទទួលពូជក្នុងដីល្អ***
***គឺអស់អ្នកដែលបានឮព្រះបន្ទូលហើយទទួល***
***រួចបង្កើតផល ម្នាក់បាន៣០ ម្នាក់បាន៦០***
***ម្នាក់ទៀតបាន១រយ" ។***

មានមនុស្សជាច្រើន បានយល់ពីការប្រៀបធៀបនេះ ចំពោះគ្រាប់ពូជនៃសេចក្តីសង្គ្រោះ ដែលបានព្រោះចុះ និងមានលទ្ធផលផ្សេពីគ្នាពីការផ្សាយដំណឹងល្អ និងពីសេចក្តីពិតនេះ ។

ទោះជាយ៉ាងណាក៏ដោយ ក៏ព្រះយេស៊ូវទ្រង់មានបន្ទូលថា ទ្រង់កំពុងតែជជែកពីព្រះបន្ទូលរបស់ព្រះ ។ ព្រះយេស៊ូវបានបង្រៀនថា នៅពេលដែលយើងបានទទួលនូវការយល់ដឹងថ្មីៗពីព្រះបន្ទូលរបស់ព្រះ ដែលចំនួនជាអាទិភាពរបស់សាតាំង គឺជាការលួចវាយ៉ាងប្រញាប់ប្រញាល់ ចេញពីយើងមកទៅវិញ។ ការនេះគឺអាចបានជាព្រះបន្ទូលរបស់ព្រះ ដែលវាគឺជាការអនុវត្តន៏ចំពោះតំបន់ណាមួយនៃជីវិតរបស់យើង ។

តើប៉ុន្មានដងមកហើយ ដែលលោកអ្នកបានឮមនុស្សនិយាយថា បន្ទាប់ពីពេលវេលាដ៏ជិតដឹតជាមួយនឹងព្រះអម្ចាស់

ដែលតែងតែចូលមក ដោយមានការសាកល្បងយ៉ាងណាទៅ? បន្ទាប់ពីសន្និសីទ ឬសិក្ខាសាលាដ៏អស្ចារ្យ នោះគ្រប់យ៉ាងក៏ហាក់ដូចជាផ្ទៃកមួយដែលមានការធ្លាក់ចុះហើយ ។ ព្រះយេស៊ូវទ្រង់មានបន្ទូលថា នេះគឺជាសាតាំងដែលបានមកដើម្បីលួចនូវព្រះបន្ទូលនោះឯង ។

## ខ. រឿងរ៉ាវមួយនៅក្នុងរឿងរ៉ាវទាំងបីបានកើតឡើង ។

នៅពេលដែលព្រះបន្ទូលត្រូវបានរកឃើញថា មានរឿងរ៉ាវបីយ៉ាងដែលអាចកើតឡើងបាន:

១. សាតាំងអាចលួចព្រះបន្ទូលជាប្រញាប់ប្រញាល់ គឺប្រសិនបើយើងបានត្រឡប់មកជាមានការរវាទចិត្ត គឺនៅពេលដែលសាតាំងនាំមកនូវការទុក្ខព្រួយ និងការបៀតបៀនចូលមកដល់នោះឯង ។

២. ការខ្វល់ខ្វាយក្នុងជីវិតនេះ សេចក្តីឆបោកខាងទ្រព្យសម្បត្តិ ឬសេចក្តីប៉ងប្រាថ្នាខាងលោកិយនេះ ។

៣. ព្រះបន្ទូលអាចបានជាការលើកទឹកចិត្ត ដើម្បីឱ្យបានចាប់យកឫសគល់ និងមានការលូតលាស់ឡើង ។

## គ. ការទុក្ខព្រួយ/ការបៀតបៀន

ព្រះយេស៊ូវទ្រង់បានទូន្មានដល់ពួកគេថា ការទុក្ខព្រួយនិងការបៀតបៀន នឹងកើតមានឡើងចំពោះការដែលយើងផ្សាយព្រះបន្ទូល ។ ព្រះគម្ពីរម៉ាកុស ៤:១៧ ។

## ឃ. សាតាំងបានមកយ៉ាងឆាប់រហ័ស

សាតាំងបានដឹងថា ប្រសិនបើការបើកសម្តែងពីព្រះបន្ទូលរបស់ព្រះ បានបើកឱកាសឱ្យមាននៅក្នុងដួងចិត្តរបស់យើង តាមរយៈព្រះបន្ទូលដដែលនោះឯងដែលវា(សាតាំង) អាចបានទទួលនូវការបរាជ័យ ។ នៅពេលដែលវាមានផែនការជាច្រើន និងយុទ្ធសាស្ត្រទាំងអស់ ដើម្បីនាំការបរាជ័យចូលមកក្នុងជីវិតរបស់យើង រីឯគោលបំណងជាចម្បងរបស់វា ក៏តែងតែមានការប្លន់ដល់យើងនូវការបើកសម្តែងពីព្រះបន្ទូលរបស់ព្រះ ។ ព្រះយេស៊ូវទ្រង់មានបន្ទូលថា សាតាំងតែងតែចូលមក នៅពេលដែលព្រះបន្ទូល កំពុងតែហូរចូលមកក្នុងចិត្តរបស់យើង ។

ព្រះគម្ពីរម៉ាកុស ៤:១៥

## ង. គ្រាប់ពូជខ្លះផលិតឡើងជាលទ្ធផលល្អ

ប៉ុន្តែមានគ្រាប់ពូជខ្លះបានដុះមកក្នុងដីល្អ ហើយក៏លូតលាស់ឡើងបានផលផ្លែដ៏ច្រើន ខ្លះបានជា៣០ ខ្លះបានជា៦០ ខ្លះបានជា១០០ ។ នោះគឺជាការផលិតដ៏ធំអស្ចារ្យ ។ គ្រាប់ពូជនៃព្រះបន្ទូលរបស់ព្រះ គឺមានជីវិតនៅ ហើយមានអំណាចផងដែរ ។ ព្រះគម្ពីរម៉ាកុស ៤:២០ ។

## III. ព្រះយេស៊ូវទ្រង់បានបញ្ជាទៅសមុទ្រឱ្យស្ងប់

នៅពេលដែលព្រះយេស៊ូវបង្ហើយការបង្រៀន នោះទ្រង់និងពួកសិស្ស ក៏ចេញទៅឯទូក ។ ក្នុងមួយរំពេចនោះឯង ព្រះយេស៊ូវទ្រង់បានផ្ទំលក់នៅខាងក្រោយទូក ។ បន្ទាប់មកសាតាំងក៏បានចូលមក ដោយនាំយកសេចក្តីទុក្ខព្រួយក្នុងជីវិតនេះមកដែរ ។

ព្រះគម្ពីរម៉ាកុស ៤:៣៥-៤១

ព្យុះដែលបានចូលមកគឺជាការទុក្ខព្រួយ ឬក៏ជាសេចក្តីល្បួង ព្រះយេស៊ូវទ្រង់មានបន្ទូលថា សាតាំងនឹងនាំមកនូវអ្វីដែលវាអាចនាំមកបាន ដូចជាយើងបានមើលឃើញក្នុងព្រះបន្ទូលស្រាប់ ។ ចូរធ្វើការកត់ចំណាំពីប្រតិកម្មរបស់ពួកសិស្ស ។

ពួកគេមានការរវាទចិត្ត ។ "លោកគ្រូ ហេតុអ្វីបានជាលោកមិនខ្វល់ពីយើងរាល់គ្នា យើងជិតវិនាសហើយ?" ពួកគេមានការរវាទចិត្ត ពីព្រោះព្រះយេស៊ូវទ្រង់កំពុងតែផ្ទំលក់ និងមិនមានការភ័យខ្លាច ដូចជាពួកគេមាននោះ ហើយពួកគេក៏ស្តីបន្ទោសទៅទ្រង់ថា ទ្រង់មិនបានខ្វល់ទៅវិញ ។

## ក.យើងមានជម្រើស

នៅពេលដែលសាតាំងនាំមកនូវការទុក្ខព្រួយ និងការបៀតបៀនមកប្រឆាំងទាស់នឹងយើង ដោយមានការខឹតខំប្រឹងប្រែងក្នុងការប្លន់យកព្រះបន្ទូលព្រះចេញពីយើង នោះយើងក៏ត្រូវមានជម្រើសដែរ ។ យើងអាចអរព្រះគុណដល់ព្រះអម្ចាស់សម្រាប់ការទូន្មានដល់យើង ដើម្បីឱ្យយើងមិនត្រូវអើពើដឹងពីល្បិចរបស់សាតាំង ហើយបន្ទាប់មកត្រូវធ្វើការស្តីបន្ទោសដល់វា ។ ឬក៏យើងអាចបានត្រឡប់មកជាមានការរវាទចិត្ត ដោយបាត់បង់នូវសេចក្តីអំណរ ដោយធ្វើការបណ្តោយខ្លួនឱ្យសាតាំងលួចឆក់យកចេញពីយើង នូវការបើកសម្តែងពីព្រះបន្ទូលរបស់ព្រះ ដែលមាននៅក្នុងរបស់យើងរួចទៅហើយនោះ ។ តើមានការញឹកញាប់ប៉ុណ្ណាទៅដែលមានការទុក្ខព្រួយ និងការបៀតបៀនបានចូលមកឯយើងនោះ តើយើងបានចាប់ផ្តើមស្រែក និងធ្វើការបន្ទោសទៅព្រះឬអី?

***"លោកគ្រូ តើលោកមិនខ្វល់ទេអី
យើងនឹងលិចលង់ចុះហើយ?"
"ឱព្រះអើយ! តើទ្រង់មិនខ្វល់ពីកូនចៅរបស់ខ្ញុំ ទេឬអី
ពួកគេបានដើរផ្លូវខុសហើយ?
ឱព្រះអើយ! តើទ្រង់មិនខ្វល់ទេឬអី
ដែលជម្ងឺវាចេះតែមករំខានដល់ជីវិតរបស់ខ្ញុំនោះ?
ឱព្រះអើយ! តើទ្រង់មិនខ្វល់ទេឬអី
ដែលខ្ញុំមិនមានលុយបង់ថ្លៃផ្ទះនេះ?"***

នៅពេលដែលយើងបើកចិត្តរបស់ឱ្យទទួល នូវការរវាទចិត្ត ហើយក៏ធ្វើការស្តីបន្ទោសទៅព្រះ ចំពោះព្យុះដែលបានចូលមកក្នុងជីវិតរបស់យើង យើងក៏បើកឱ្យសាតាំងប្លន់យកនូវគ្រាប់ពូជដំបូងនៃព្រះបន្ទូលរបស់ព្រះទៅនោះ ។

## ខ. ការនិយាយដោយសេចក្តីជំនឿ

សកម្មភាពជាវិជ្ជមានចំពោះសេចក្តីជំនឿ គឺជាការចាំបាច់បំផុត ប្រសិនបើយើងមានបំណងនឹងថែរក្សាគ្រាប់ពូជនៃព្រះបន្ទូល នៅក្នុងចិត្តរបស់យើង ហើយមានសង្ឃឹមថានឹងបានទទួលផល មួយជា៣០ មួយជា៦០ ឬក៏មួយជា១០០នោះ ។ សេចក្តីបានមកដោយការឮព្រះបន្ទូលរបស់ព្រះ ។

ព្រះគម្ពីរម៉ាកុស ៤:៤០

## គ. ការនិយាយដោយមានសិទ្ធិអំណាច

ជំនួសឱ្យនូវការត្រឡប់មកជាមានការរវាទចិត្តនេះ គឺនៅពេលដែលព្យុះនៃជីវិតបានចូលមកទាស់ទទឹង នឹងទូករបស់យើង នោះយើងត្រូវតែឈរឱ្យមាំមួនប្រទាស់នឹងអារក្សដោយ ហើយនិយាយដោយអង់អាចនូវព្រះបន្ទូលរបស់ព្រះដោយនូវសេចក្តីជំនឿនោះឯង ។ តើអ្នកណាអាចធ្វើការនេះបាន? ព្រះយេស៊ូវទ្រង់ជាកូនមនុស្ស គឺជាលោកអ័ដាមចុងក្រោយ ហើយក៏ដើរដោយនូវសិទ្ធិអំណាច និងអំណាចគ្រប់គ្រងបាន ។ ព្រះគម្ពីរម៉ាកុស ៤:៣៩

## ឃ.ចូរធ្វើការប្រយ័ត្នប្រយែង

សូម្បីតែសាតាំងក៏ត្រូវទទួលបរាជ័យ នៅពីក្រោមជើងយើងដែរ វានឹងធ្វើគ្រប់យ៉ាងឱ្យយើងបានត្រូវចាកចេញពីសិទ្ធិ

អំណាចដែលព្រះទ្រង់បានប្រទានឱ្យមកយើងនោះ ។ យើងត្រូវតែមានការប្រយ័ត្នប្រយែង ត្រូវតែវាងល្បាត និងត្រៀមខ្លួនជាស្រេច ដើម្បីយកជ័យជម្នះពីគ្រប់ទាំងការប្រយុទ្ធប្រឆាំងទាស់នឹងជីវិតរបស់យើងនោះ ។ យើងត្រូវតែដឹងស្គាល់ថាអ្នកណា ដែលអ្នកបាននៅក្នុងព្រះគ្រីស្ទនោះ ។

ព្រះគម្ពីរ ១ពេត្រុស ៥:៨

## ង.គ្រឿងសឹករបស់ព្រះ

ដោយសេចក្តីជំនឿ យើងត្រូវតែពាក់នូវគ្រឿងសឹករបស់ព្រះ ដើម្បីឱ្យយើងអាចឈរឱ្យមាំមួនប្រឆាំងទាស់ឧបាយកលរបស់អារក្ស ។ ព្រះគម្ពីរអេភេសូរ៦:១០-១១ ។

នៅពេលដែលយើងធ្វើយ៉ាងដូច្នេះ នោះយើងនឹងរកឃើញនូវការឈរយ៉ាងមាំមួនដោយខ្លួនឯង ទាស់នឹងអារក្សនៅកណ្តាលព្យុះនោះបាន ។ ព្រះគម្ពីរអេភេសូរ ៦:១៣ ។

## ច. សិទ្ធិអំណាចរបស់យើង

ព្រះរាជកិច្ចរបស់ព្រះយេស៊ូវ គឺត្រូវតែពេញលេញ! ទ្រង់បានបង្ក្រាបអារក្សសាតាំង និងពពួកវិញ្ញាណអាក្រក់របស់វារួចជាស្រេចហើយ ។

ទ្រង់បានបង្កើតមនុស្សប្រុសស្រី ឱ្យមាននៅលើផែនដីនេះ គឺដើម្បីឱ្យបានដើរដោយនូវសិទ្ធិអំណាចនេះឯង ។ ទ្រង់ក៏បានកែជាថ្មីឡើងវិញ នូវសិទ្ធិអំណាចរបស់យើង ហើយឥឡូវនេះយើងត្រូវតែងើបឡើង ហើយសម្តែងថា អារក្សគឺត្រូវតែបរាជ័យនៅពីក្រោមជើងរបស់យើងហើយ ។ យើងត្រូវតែមានការឱ្យជាដំបូន្មានថា នគររបស់ព្រះគឺនៅលើផែនដីនេះ ។

ព្រះគម្ពីរអេសាយ ៥៤:១៧ខ

## IV. តើពួកជំនុំគឺជាអ្វី?

## ក.និទ្ទេសទីមួយ

តាមរយៈព្រះគម្ពីរសញ្ញាចាស់ ការថ្វាយបង្គំគឺតែងតែត្រូវបានដាក់ជាកណ្តាល នៅជុំវិញរោងឧបោសថ គឺជាព្រះវិហារ ឬក៏ជារោងប្រជុំ ។ អត់មានពួកជំនុំដូចជាយើងបានដឹង នៅសម័យសព្វថ្ងៃនេះនោះទេ ។

ពេលដែលព្រះយេស៊ូវទ្រង់សម្តែងនិទ្ទេសជាដំបូង ទៅដល់ពួកជំនុំ នោះទ្រង់ក៏បានបើកសម្តែងជាបីយ៉ាង ដែលត្រូវតែមានជាបុគ្គលិកលក្ខណៈ នៅពីលើមុខងារទាំងអស់របស់វា ។

***វាត្រូវតែបានសង់ឡើងដោយព្រះយេស៊ូវ ។***

***វាត្រូវតែបានទទួលនូវជ័យជម្នះ***

***លើកងកម្លាំងដែលមានជ័យជម្នះ លើទ្វារនៃស្ថាននរក ។***

***វាត្រូវតែមានអំណាចដើម្បីចង និងស្រាយ ។***

ព្រះគម្ពីរម៉ាថាយ ១៦:១៣-១៨

ពាក្យ "ពេត្រុស" មានន័យថា ថ្មដ៏តូចមួយដុំ គឺជាថ្មដែលដាំនៅពីលើព្រះយេស៊ូវ គឺដែលទ្រង់បានសង់ពួកជំនុំរបស់ទ្រង់ឱ្យទៅជាថ្មដ៏ធំបំផុត ដែលអាចទប់ក្បាលទឹកនៅទន្លេយ័រដានដែលកំពុងតែហូរបាន ។

## ខ. សេចក្តីពិតដែលជាគ្រឹះមាំ

លោកសាវ័កពេត្រុសបានដឹងដោយការបើកសម្តែង មកពីព្រះថា ព្រះយេស៊ូវទ្រង់ជាព្រះគ្រីស្ទ ជាព្រះរាជបុត្រានៃព្រះ ។ នេះគឺជាសេចក្តីពិត ដែលពួកជំនុំត្រូវបានសង់ឡើង ។

## គ. ការសង់ឡើងដោយព្រះយេស៊ូវ

បុគ្គលិកលក្ខណៈទីមួយរបស់ពួកជំនុំ គឺដែលព្រះយេស៊ូវ

ទ្រង់នឹងសង់វាឡើង ។ វាមិនត្រូវបានសង់ឡើងដោយមនុស្ស ដោយទំនៀមទម្លាប់របស់មនុស្ស ឬដោយមានកម្មវិធីនោះទេ។

### ឃ. ការឈ្នះលើទ្វារស្ថាននរក

ពួកជំនុំគឺមិនមែនជាប៉ម នៅកន្លែងដែលលាក់ខ្លួនពីការភ័យខ្លាចនោះទេ ។ បុគ្គលិកលក្ខណៈទីពីរនៃពួកជំនុំ គឺដែលទ្វារនៃស្ថាននរកនឹងមិនឈ្នះវាឡើយ ។ "ទ្វារ" គឺតំណាងឱ្យរដ្ឋបាល ។ ព្រះគម្ពីរម៉ាថាយ ១៦:១៨ ។

## V. ទ្វារស្ថាននរក

វាគឺជាការសំខាន់ក្នុងការយល់ពីអ្វី ដែលព្រះយេស៊ូវទ្រង់មានបន្ទូល គឺនៅពេលដែលទ្រង់មានបន្ទូលថា ទ្វារនៃស្ថានឃុំព្រលឹងមនុស្ស មិនអាចយកជ័យជម្នះលើពួកជំនុំបាន ។ នៅក្នុងពេលរបស់យើង នោះយើងគិតថា ទ្វារគឺជាការបើកចេញចូលតាមរបងដែលមានជញ្ជាំង ។

តើទ្វារនោះគឺជាអ្វី?

នៅក្នុងពេលនៃព្រះគម្ពីរ រដ្ឋបាល និងជំនួញនៃទីក្រុង គឺត្រូវបានទទួលនូវការណែនាំតាមរយៈទ្វាររបស់វានោះឯង ។ ដូច្នេះទ្វារនោះ គឺនៅពេលដែលមានការចែកចាយនូវសន្តិសុខទៅចំពោះជញ្ជាំងទីក្រុង ក៏បានត្រឡប់ទៅជាការសម្អាងទៅលើរដ្ឋាភិបាល នៃទីក្រុង ឬជនជាតិនីមួយៗនោះឯង ។ ស្តេចសាឡូម៉ូនបានសម្អាងទៅលើការនេះមួយៗ នៅក្នុងព្រះគម្ពីរសុភាសិតរបស់ទ្រង់នោះឯង ។

ព្រះគម្ពីរសុភាសិត ៣១:២៣ (រដ្ឋាភិបាលរបស់ទីក្រុង)

នៅពេលដែលព្រះទ្រង់បានប្រទានពរដល់លោកអ័ប្រាហាំ នោះគាត់ក៏បានសម្អាងទៅលើ ការកាន់កាប់ទ្វារនៃសត្រូវពាន របស់គាត់ ។ នោះគឺជាព្រះពរ ។

ព្រះគម្ពីរលោកុប្បត្តិ ២២:១៧

ព្រះគម្ពីរលោកុប្បត្តិ ២៤:៦០

ដើម្បីកាន់កាប់នូវទ្វារនៃសត្រូវពាហណៈ ក្នុងការចាប់យក និងគ្រប់គ្រងនូវរដ្ឋបាលរបស់វានោះឯង ។ សម័យសព្វថ្ងៃនេះ យើងត្រូវតែគ្រប់គ្រងកាន់កាប់ទ្វារ របស់ខ្មាំងសត្រូវទាំងបួន នៅក្នុងតំបន់ខាងឯវិញ្ញាណ ដោយនូវសិទ្ធិអំណាច អំណាចគ្រប់គ្រង និងដោយនូវការឈ្លានពាន ដោយសង្គ្រាមខាងឯវិញ្ញាណដ៏កំណាចឃោរឃៅ ទ្វារដែលត្រូវបានចាប់យកដោយកងកម្លាំងនោះឯង ។ ស្តេចសាឡូម៉ូនបាននិយាយយ៉ាងដូច្នេះ។

ព្រះគម្ពីរសុភាសិត ១៤:១៩

## VI. កូនសោរដែលបានកែជាថ្មីឡើងវិញ

**កូនសោររបស់នគរ** - ព្រះគម្ពីរម៉ាថាយ ១៦:១៩

ចំពោះកូនសោរទាំងនេះ យើងអាចសម្រេចតាមបំណងព្រះហឫទ័យរបស់ព្រះ និងនគររបស់ព្រះនៅលើផែនដីនេះ ។ យើងមានអំណាចដើម្បីចង និងមានអំណាចដើម្បីស្រាយ ។ នៅលើផែនដីនេះ អំណាចគ្រប់គ្រងគឺត្រូវបានកែជាថ្មីឡើងវិញ ដល់ពួកជំនុំរបស់ទ្រង់ ។ គ្រប់ពេលដែលយើងបង្ខំបកទៅលើកងកម្លាំងរបស់សាតាំងវិញ គឺយើងកំពុងតែឱ្យដំបូន្មានពីនគររបស់ព្រះហើយ ។

យើងបានធ្វើឱ្យមានឡើងគឺដែលកូនសោរ ដែលបញ្ជាក់ទៅលើសិទ្ធិអំណាចនៅលើផែនដីនេះ ។ កូសោរគឺអាចទាំងចាក់បិទ និងចាក់បើកទ្វារ ដែលយើងបានមើលឃើញ គឺជារដ្ឋបាលលើអង្គភាពនីមួយៗ ទៅលើបុគ្គលម្នាក់ ក្រុមគ្រួសារមួយអង្គការមួយ ទីក្រុងមួយ រដ្ឋមួយ ឬក៏ជនជាតិមួយ ។

### ខ. កូនសោរដើម្បីគ្រប់គ្រង

ទាំងនេះគឺជាកូនសោរនៃសិទ្ធិអំណាច ដែលព្រះទ្រង់បានប្រទានដល់មនុស្សមនុស្សជាតិ គឺនៅពេលដែលទ្រង់បានបង្កើតមនុស្សប្រុសស្រី នៅក្នុងរូបភាពព្រះអង្គទ្រង់ផ្ទាល់ ។ ទ្រង់បានប្រទាននូវសិទ្ធិអំណាចដល់មនុស្ស ឱ្យបានគ្រប់គ្រងលើគ្រប់របស់ទាំងអស់នៅលើផែនដីនេះ រួមទាំងអារក្សផងដែរ ។ ព្រះគម្ពីរលោកុប្បត្តិ ១:២៦ ។

### គ. ការកែមនុស្សជាថ្មីឡើងវិញ

កូនសោរទាំងរនេះគឺជាសិទ្ធិអំណាច ដែលព្រះយេស៊ូវទ្រង់បានកែមនុស្សជាតិជាថ្មីឡើងវិញ គឺជាការកើតជាថ្មី បន្ទាប់ពីការរស់ពីសុគតឡើងវិញរបស់ទ្រង់ និងការលើកឡើងទៅឯព្រះវរបិតា ។ ចាប់តាំងពីកូនសោរទាំងនេះ ត្រូវបានកែជាថ្មីឡើងវិញហើយ នោះភាពជាម្ចាស់ផ្ទាល់របស់ពួកគេសុទ្ធសាធនោះ ក៏ត្រូវបាននៅលើផែនដីនេះ ពួកគេនឹងមិនត្រូវបានបាត់បង់នូវការប្រើប្រាស់ ជាកូនសោរនៃសេចក្ដីស្លាប់ និងស្ថានឃុំព្រលឹងមនុស្សស្លាប់តទៅទៀតឡើយ។ ពួកគេនឹងបានត្រឡប់មកជាអ្នកស្គាល់ថា ជាកូនសោរនៃនគរស្ថានសួគ៌វិញ ។ យើងត្រូវតែសិក្សារៀនសូត្រក្នុងការទទួលស្គាល់ និងការដើរដោយនូវសិទ្ធិអំណាច និងអំណាចគ្រប់គ្រង ដែលព្រះយេស៊ូវទ្រង់បានកែយើងជាថ្មីឡើងវិញ ។ ព្រះយេស៊ូវទ្រង់បានប្រើវត្ថុជាគំរូនៃជីវិត ដើម្បីបង្រៀនដល់យើង ។

### ឃ. កូនសោរដើម្បីចង និងស្រាយ

ពួកជំនុំមានអំណាចនឹងចង ហើយនិងស្រាយ ។
ព្រះគម្ពីរម៉ាថាយ ១៦:១៩

មានរឿងរ៉ាវបីយ៉ាង ដែលយើងត្រូវការសិក្សារៀនសូត្រអំពីពួកជំនុំ ចាប់ពីពេលវេលាទីមួយដែលព្រះយេស៊ូវទ្រង់បានធ្វើនិទ្ទេសពីវានោះ ។

១. ពួកជំនុំត្រូវបានសង់ឡើងដោយព្រះយេស៊ូវ នៅលើការបើកសម្ដែងមកពីព្រះវរបិតា ដែលព្រះយេស៊ូវទ្រង់ដ៏ជាព្រះគ្រីស្ទ គឺជាព្រះរាជបុត្រានៃព្រះដ៏មានព្រះជន្មរស់ ។
២. ទ្វារស្ថានឃុំព្រលឹងមនុស្សស្លាប់ នឹងមិនអាចទាស់ទទឹងនឹងពួកជំនុំនេះបានឡើយ ។
៣. ពួកជំនុំនឹងត្រូវបានប្រទានឱ្យ នូវកូនសោរនៃនគរស្ថានសួគ៌ នៅលើផែនដីនេះ ហើយមានអំណាចអាចចង និងស្រាយបាន ។

## VII. គោលការណ៍នៃការចង និងការស្រាយ

### ក. ព្រះយេស៊ូវបានចងមនុស្សខ្លាំង

ព្រះយេស៊ូវទ្រង់បានជជែកអំពីការចង ដល់មនុស្សខ្លាំង ។ ព្រះគម្ពីរម៉ាថាយ ១២:២៨-២៩

### ខ. តើអ្នកណាជាមនុស្សខ្លាំង?

មនុស្សខ្លាំងគឺជាសាតាំង ឬក៏វិញ្ញាណអាក្រក់ដែលគ្រប់គ្រង គឺដែលវាបានចាត់ចែងលើរដ្ឋបាល អង្គការ ឬក៏លើជីវិតរបស់បុគ្គលម្នាក់ៗ ។ ព្រះយេស៊ូវទ្រង់បានយាងចូលមកឯផ្ទះរបស់មនុស្សខ្លាំង គឺជាសាតាំងនិងវិញ្ញាណដែលគ្រប់គ្រងរបស់វានោះឯង ។

យើងចងសាតាំង ហើយបន្ទាប់មកចងពួកវិញ្ញាណដែលគ្រប់គ្រងលើរបស់វា ដោយការនិយាយជាមួយនឹងសិទ្ធិ

អំណាចថា "នែ៎សាតាំង អញចងឯងដោយនូវព្រះនាមព្រះយេស៊ូវ!"

## គ.តើការចងគឺជាអ្វី?

ការចងមានន័យថា: កំណត់ឱ្យសាតាំង ឬវិញ្ញាណអាក្រក់ ដែលគ្រប់គ្រងលើស្ថានការណ៍ពិសេសៗ នៅកន្លែងដែលព្រះទ្រង់បានអនុញ្ញាតឱ្យយើង ចូលទៅក្នុងសង្គ្រាមខាងឯវិញ្ញាណនោះ ។ ព្រះទ្រង់បានប្រទានឱ្យយើងម្នាក់ៗនូវសិទ្ធិអំណាចក្នុងតំបន់របស់យើងហើយ ។

យើងជាគំរូគឺនៅពេលដែលយើងចងឆ្កែមួយក្បាល ជាមួយនឹងច្រវាក់ គឈបានចងវាជាប់ទៅនឹងបង្គោលស្ទឹង ឆ្កែនោះគឺវាអាចទៅបានចម្ងាយ ត្រឹមតែប្រវែងកំណត់ប៉ុណ្ណោះ។ គាត់បានកំណត់ពីចម្ងាយតាមបណ្តោយច្រវាក់ ចេញពីកន្លែងដែលបានចងវាប៉ុណ្ណោះ ។ យើងក៏មានការកំណត់នៅក្នុងតំបន់ ដែលមានអានភាពលើនោះដែរ ។ នេះគឺជាអ្វីដែលជាអត្ថន័យនៃការចងនោះឯង ។

## ឃ. តំបន់សិទ្ធិអំណាច

ព្រះទ្រង់បានប្រទានមកយើងម្នាក់ៗ គឺនៅត្រង់ចំណុចតំបន់នៃសិទ្ធិអំណាចនៅក្នុងជីវិត ក្រុមគ្រួសារ អ្នកជិតខាង កន្លែងធ្វើការ និងគ្រប់កន្លែងទាំងអស់របស់យើង ដែលទ្រង់បានបញ្ជូនយើងមកនោះ ។ ការស្គាល់អ្នកដែលនៅក្នុងព្រះគ្រីស្ទ ។ ចូរចងមនុស្សខ្លាំង ហើយចែករំលែកដល់តំបន់របស់លោកអ្នក ។

## ង. ចូរស៊ើបអង្កេតមើលផ្ទះរបស់វា

ជាបន្តបន្ទាប់ទៀត យើងត្រូវតែស៊ើបអង្កេតមើលផ្ទះរបស់វា ។ យើងធ្វើយ៉ាងដូច្នេះដោយការបញ្ជាពីវិញ្ញាណអាក្រក់ ដែលនៅក្រោមសិទ្ធិអំណាចរបស់មនុស្សខ្លាំងនោះថា "ចូរចេញទៅនៅក្នុងព្រះនាមព្រះយេស៊ូវ!" យើងអាចស្គាល់ និងបញ្ជាក់ពីវិញ្ញាណទាំងនេះ គឺដោយការអនុវត្តនីដោយនូវអំណោយទានខាងឯវិញ្ញាណខាងការសង្កេតនូវវិញ្ញាណ និងពាក្យសម្តីនៃចំណេះចេណស្មាត់ ។ យើងក៏អាចស្គាល់នូវភស្តុតាងរបស់ពួកគេ តាមមុខងារជាក់ស្តែង ។ មុខងារទាំងនេះគឺវិញ្ញាណអាថិកំបាំង វិញ្ញាណលាក់លៀម វិញ្ញាណមិនស្អាត វិញ្ញាណពេញដោយសេចក្តីប៉ងប្រាថ្នា វិញ្ញាណខូចអាក្រក់ វិញ្ញាណពិការភាព វិញ្ញាណនៃការរងទុក្ខ និងជាវិញ្ញាណអត្តឃាត ។

## ច. ការបណ្តេញដល់ពពួកវិញ្ញាណ

តាមការបណ្តេញដល់ពពួកវិញ្ញាណទាំងនេះ គឺយើងត្រូវយៃស៊ើបអង្កេតដល់ផ្ទះមនុស្សខ្លាំងនោះ ។ នៅពេលដែលផ្ទះរបសលវានេះ ត្រូវបានស៊ើបអង្កេតចប់សព្វគ្រប់ហើយ នោះវានឹងត្រឡប់មកជាគ្មានជំនួយ ហើយយើក៏អាចបញ្ជាវាឱ្យចាកចេញ ដោយនូវព្រះនាមព្រះយេស៊ូវ ។

ព្រះគម្ពីរលូកា ១១:២១-២២

ព្រះយេស៊ូវទ្រង់បានបន្ថយអាវុធ បន្ថយអំណាច និងសិទ្ធិអំណាច ព្រមទាំងធ្វើឱ្យពួកវាបង្ហាញរូបភាពជាសាធារណៈ ។ ទ្រង់បានបង្ហាញរូបភាពទាំងអស់របស់ពួកវា ព្រមទាំងបានគង់នៅខាងស្តាំនៃព្រះវរបិតា ។ បើយើងចងអ្វីនៅផែនដី នោះក៏នឹងត្រូវចងនៅស្ថានសួគ៌ដែរ ហើយបើយើងស្រាយអ្វីនៅផែនដី នោះក៏ត្រូវស្រាយនៅស្ថានសួគ៌ដែរ ។ នេះគឺជាការទទួលស្គាល់ដ៏ពិតនៅឯនគរស្ថានសួគ៌ ប៉ុន្តែ យើងត្រូវការធ្វើវានៅលើផែនដីផងដែរ ។

## VIII. តួនាទីរបស់សាតាំង

### ក.ការធ្វើមិនឱ្យមានប្រសិទ្ធិភាព

ដោយនូវការសុគត និងការរស់ឡើងវិញ នោះព្រះយេស៊ូវទ្រង់បានធ្វើឱ្យសាតាំងលែងមានប្រសិទ្ធិភាព ឱ្យទៅជាចំណុចសូន្យ ។ មានតែរឿងមួយទេដែលសាតាំងអាចធ្វើបាន គឺជាអ្វីដែលពួកជំនុំបានអនុញ្ញាតឱ្យវាធ្វើប៉ុណ្ណោះ ។

ព្រះគម្ពីរហេព្រើរ ២:១៥

### ខ. អ្នកចាប់ចងរបស់យើងគ្មានតទៀតឡើយ

យើងត្រូវបានដោះលែងឱ្យមានសេរីភាព ពីការភ័យខ្លាចចំពោះសេចក្តីស្លាប់ និងចំណងហើយ ។

ព្រះគម្ពីរហេព្រើរ ២:១៥

តាមរយៈការងាររបស់ព្រះយេស៊ូវ ដែលត្រូវបានទទួលស្គាល់ក្នុងការសុគត និងការរស់ពីសុគតឡើងវិញដ៏ជាញជ័យរបស់ព្រះអង្គ នោះមនុស្សប្រុសស្រីនឹងមិនត្រូវការគាំទ្រ នឹងឈ្លើយសឹកចំពោះការភ័យខ្លាចនឹងសេចក្តីស្លាប់ នោះតទៅទៀតឡើយ ។ នៅពេលដែលយើងរុករកឱ្យឃើញ នូវសេចក្តីពិតនេះ នោះយើងត្រូវបានដោះឱ្យមានសេរីភាព និងត្រូវបានរំដោះយ៉ាងពេញលេញ ចេញពីចំណងនិងសេចក្តីភ័យខ្លាចដល់អារក្សនោះ ។

### គ.ការងារត្រូវបានបំផ្លាញ

ហេតុអ្វីបានជាព្រះរាជបុត្រារបស់ព្រះ ត្រូវបានសម្តែងឱ្យឃើញ? គឺដើម្បីកំចាត់កំចាយនូវការងាររបស់សាតាំង! ចូរធ្វើការបង្ហាញរូបភាពរបស់ពួកវាជាសាធារណៈចុះ! យើងត្រូវការស្គាល់នូវសិទ្ធិអំណាច និងអំណាចគ្រប់គ្រងរបស់យើងក្នុងព្រះយេស៊ូវគ្រីស្ទ ។

ព្រះគម្ពីរ ១យ៉ូហាន ៣:៨

ព្រះគម្ពីរកូល៉ុស ២:១៥

## IX. ការបេកលក់របស់ពួកជំនុំគឺត្រូវបានដាស់ឱ្យងើបឡើង!

នៅពេលដែលព្រះយេស៊ូវ ទ្រង់បានយាងមកផែនដីនេះដើម្បីបំផ្លាញដល់ការងាររបស់អារក្ស នោះទ្រង់ក៏បានទុកសិទ្ធិអំណាចទ្រង់ជាព្រះនៅដោយឡែកសិន ។ នៅលើផែនដីនេះទ្រង់គឺជាលោកអ័ដាមចុងក្រោយ ទ្រង់បានដើរនិងបំពេញព្រះរាជកិច្ច ដោយនូវសិទ្ធិអំណាច និងអំណាចគ្រប់គ្រង ។ សាតាំងគឺត្រូវបានបរាជ័យដ៏ពេញលេញ ដោយព្រះយេស៊ូវ ។ វាត្រូវបានទទួលនូវការនាំមកដល់ចំណុចសូន្យ ហើយបានធ្វើឱ្យវាលែងមានប្រសិទ្ធិភាពទៀតហើយ ។ ព្រះយេស៊ូវទ្រង់បានធ្វើឱ្យអារក្សធ្លាក់ចុះដល់ចំណុច "លេខសូន្យ" ហើយ ។ វាត្រូវបានទទួលនូវការបរាជ័យហើយ ។

ឥឡូវនេះ សិទ្ធិអំណាចនិងអំណាចគ្រប់គ្រងនេះ គឺជាកូនសោរដែលបានត្រូវកែជាថ្មីឡើងវិញហើយ ដើម្បីប្រោសលោះដល់មនុស្សជាតិ ដែលតាមរយៈសេចក្តីជំនឿ នោះឥឡូវនេះពួកជំនុំរបស់ព្រះអង្គនិងរូបកាយរបស់ទ្រង់នៅលើផែនដីនេះ។ សាតាំងដែលត្រូវបានទទួលនូវការបរាជ័យហើយនោះ គឺត្រូវបាននៅពីក្រោមបាទជើងនោះ វាបានត្រឹមតែអាចធ្វើការនៅលើផែនដី គឺជាអ្វីដែលយើងអនុញ្ញាតឱ្យវាធ្វើដោយនូវភាពអវិជ្ជារបស់យើងប៉ុណ្ណោះ ។ ចំពោះការបើកសម្តែងនេះ គឺមកពីព្រះបន្ទូលរបស់ព្រះ ដែលយើងអាចងើបឡើង និងចងសាតាំង និងពពួកវិញ្ញាណគ្រប់គ្រងរបស់វានោះ ។ យើងអាចរុញច្រានវាចុះ នូវទីមាំមួនរបស់សាតាំង គឺនៅពេលដែលយើងបានចងមនុស្សខ្លាំង និងបានស៊ើបអង្កេតដឹងពីផ្ទះរបស់វា

ហើយ គឺយើងបានបញ្ចោញពួកវិញ្ញាណអាក្រក់ឱ្យវាចេញទៅ ក្នុងព្រះនាមព្រះយេស៊ូវនោះឯង ។

ព្រះគម្ពីរ ២កូរិនថូស ១០:៤

ពួកជំនុំដែលព្រះយេស៊ូវទ្រង់ មានបន្ទូលថាទ្រង់នឹងសង់ឡើង នោះបានត្រូវដេកលក់យន់ទៅហើយ ឥឡូវនេះគឺត្រូវបានដាស់ឱ្យងើបឡើង ដើម្បីអនុវត្តនូវសិទ្ធិអំណាច ដែលបានប្រទានមកពីព្រះ ហើយនឹងត្រូវរើចេញនូវទីមាំមួនរបស់សាតាំង ហើយធ្វើការឱ្យដំបូន្មានយ៉ាងខ្លាំងក្លាពីនគររបស់ព្រះវិញ!

## ក្រុមពិភាក្សា

១. ចូរពិភាក្សាពីរឿងរ៉ាវខ្លះៗ ដែលអាចត្រូវប្រឹក្សាបាន "ការខ្វល់ខ្វាយ/ការទុក្ខព្រួយរបស់លោកិយនេះ" ដែលធ្វើឱ្យថប់ចិត្តនឹងព្រះបន្ទូល ហើយដែលមិនបង្កើតផលផ្លែនោះ ។

២. ចូរចែកចាយពីគូស្វាមីភរិយា ដោយមានគំរូខ្លីៗពីតាក់ទិចដែលសាតាំងបានព្យាយាម នៅក្នុងជីវិតរបស់លោកអ្នកជាលំដាប់លំដោយ ដើម្បីទាញលោកអ្នកចេញពីការដើរដោយនូវសិទ្ធិអំណាច ដែលព្រះទ្រង់បានប្រទានមកអ្នករាល់គ្នាហើយនោះ ។

៣. តើការបើកសម្ដែងដូចម្ដេចខ្លះ ដែលលោកអ្នកបានទទួលមកពីព្រះគម្ពីរម៉ាថាយ ១៦:១៣-១៨ បន្ទាប់ពីបានសិក្សាអំពីប្រវត្តិអត្ថន័យនៃពាក្យ "ទ្វារ" នោះ?

## ការសិក្សាដោយខ្លួនឯង

១. យើងមានអំណាចដើម្បីចង ហើយនិងស្រាយ ។ តើនៅមានតំបន់ណាខ្លះក្នុងជីវិតរបស់លោកអ្នក ដែលលោកអ្នកត្រូវការបន្ថែមទៀត ជាមួយនឹងការចងនិងស្រាយនេះ? ប្រសិនបើមាន តើនៅក្នុងតំបន់ណា? ចូរសរសេរចុះហើយ ចាប់ផ្ដើមប្រើនូវសិទ្ធិអំណាច និងអំណាចគ្រប់គ្រងដែលព្រះទ្រង់បានប្រទានឱ្យមកលោកអ្នកនោះ ។

២. តើលោកអ្នកបានរៀនដូចម្ដេចខ្លះ អំពីការចង "មនុស្សខ្លាំង" (ម៉ាថាយ ១២:២៨-២៩) នោះ?

៣. សាតាំងត្រូវបានទទួលនូវការបរាជ័យ នៅក្រោមជើងរបស់យើងហើយ ។ វាអាចធ្វើបានត្រឹមតែអ្វីដែលពួកជំនុំបានអនុញ្ញាតឱ្យវាធ្វើប៉ុណ្ណោះ ។ តើលោកអ្នកអាចគិតទៅលើ តំបន់នៅក្នុងជីវិតរបស់លោកអ្នក គឺនៅកន្លែងដែលលោកអ្នក បានអនុញ្ញាតដល់ពួកវានូវច្រកចូល ឬក៏អំណាចនោះ? តើលោកអ្នកអាចធ្វើបានយ៉ាងដូចម្ដេចដើម្បីបំផ្លាស់បំប្រែនូវការនេះ?

# សិទ្ធិអំណាចរបស់អ្នកជឿ

## *មេរៀនទី ៦: កូនសោរសម្រាប់ចាក់នគរស្ថានសួគ៌*

### I. ព្រះយេស៊ូវគឺជាកូនសោរ

ព្រះយេស៊ូវទ្រង់បានធ្វើឱ្យសេចក្តីស្លាប់ត្រូវចុះចាញ់! ព្រះយេស៊ូវទ្រង់បានចាប់យកកូនសោរនៃស្ថាននរក និងសេចក្តីស្លាប់ចេញពីសាតាំងហើយ ។ ម្យ៉ាងទៀត ព្រះយេស៊ូវទ្រង់បានរំដោះយើងចេញពីអំពើបាប ដែលត្រូវតែធ្លាក់ទៅឯស្ថានឃុំព្រលឹងមនុស្សស្លាប់នោះ គឺវាមិនអាចធ្វើឱ្យទ្រង់គាំទ្រដល់ពួកវា ដែលជាអ្នកទោសតទៅទៀតឡើយ ។ ព្រះយេស៊ូវទ្រង់បានកែសិទ្ធិអំណាច អំណាចគ្រប់គ្រង និងភាពជាស្តេចដល់ពួកជំនុំរបស់ទ្រង់សារជាថ្មីឡើងវិញហើយ ។ ទ្រង់បានកែយើងពីគ្រប់ការ ដែលសាតាំងបានលួចឆក់យកទៅនោះហើយដែរ ។

យើងដឹងថា ព្រះទ្រង់បានសព្វព្រះហឫទ័យឱ្យយើងរស់នៅដោយមានអំណាចគ្រប់គ្រង និងសិទ្ធិអំណាចទាំងស្រុងលើសាតាំង ពីព្រោះទ្រង់បានធ្វើជាយញ្ញបូជា ដោយព្រះរាជបុត្រារបស់ទ្រង់ផ្ទាល់ ដើម្បីកែគ្រប់ទាំងអស់ ដែលទ្រង់បានបង្កើតមកឱ្យយើងមាននៅ និងធ្វើការនៅលើផែនដីនេះ ។

គ្រប់ទាំងអស់ដែលព្រះយេស៊ូវ ទ្រង់បានធ្វើនៅលើផែនដីនេះ ដោយជីវិតរបស់ទ្រង់ការសុគតរបស់ទ្រង់ និងការរស់ពីសុគតឡើងវិញរបស់ទ្រង់ គឺដើម្បីឱ្យយើងអាចដើរដោយនូវសិទ្ធិអំណាច និងជ័យជម្នះលើសាតាំង ពួកវិញ្ញាណអាក្រក់របស់វា និងគ្រប់យ៉ាងដែលនៅលើផែនដីនេះ ។

ព្រះគម្ពីរកិច្ចការ ២:២៤

### II. ព្រះលោហិតរបស់ព្រះយេស៊ូវ គឺជាកូនសោរជ័យជម្នះលើអស់ទាំងជ្យជម្នះ ។

ព្រះគម្ពីរវិវរណៈ ១២:១១

នៅពេលដែលព្រះទ្រង់បានបង្កើតលោកអ័ដាមមក នោះទ្រង់បានផ្លុំខ្យល់ដង្ហើមចូលទៅក្នុងលោកអ័ដាម ឱ្យគាត់មានជីវិតរបស់ទ្រង់ផ្ទាល់ ។ ជីវិតនេះគឺមិនមែនជាការកំណត់ទៅចំពោះម្នាក់ ឱ្យនៅដាច់ឆ្ងាយពីរូបកាយរបស់លោកអ័ដាមនោះទេ ។ ព្រះទ្រង់បានដាក់ជីវិតរបស់ទ្រង់ ឱ្យនៅក្នុងសួតរបស់គាត់ គឺជាកន្លែងដែលវាអាចបញ្ជូនចូលទៅក្នុងឈាមរបស់លោកអ័ដាមនោះឯង ។ វាបានផ្លុំជាបន្តៗទៅគ្រប់ផ្នែកទាំងអស់នៃរូបកាយរបស់លោកអ័ដាមនោះឯង ។

លោកម៉ូសេបានសរសេរចែងទុកមកថា ជីវិតដែលបានបង្កើតមកគឺស្ថិតនៅក្នុងឈាម ។

ព្រះគម្ពីរលេវីវិន័យ ១៧:១១ក

#### ក. អំពើបាបរបស់លោកអ័ដាម គឺជាសេចក្តីស្លាប់

តាមរយៈការធ្វើបាប លោកអ័ដាមបានបាត់បង់ជីវិតរបស់ព្រះ ដែលបាននៅក្នុងឈាមរបស់គាត់នោះ ។ ជីវិតនេះគឺអាចបានត្រឹមតែទទួលនូវការកែជាថ្មីឡើងវិញដល់ មនុស្សតាមរយៈផែនការនៃសេចក្តីប្រោសលោះរបស់ព្រះ ។ សម្រាប់មនុស្ស ដើម្បីឱ្យបានទទួលនូវការកែជាថ្មីឡើងវិញ ឱ្យមានរូបភាពរបស់ព្រះ នោះគេត្រូវតែមានជីវិតរបស់ព្រះជាថ្មីម្តងទៀត នៅក្នុងឈាមរបស់គេ ។ នៅក្នុងផែនការនៃសេចក្តីប្រោសលោះរបស់ព្រះ នោះព្រះរាជបុត្រារបស់ទ្រង់ ព្រះនាមព្រះយេស៊ូវ ត្រូវតែមកបង្ហូរព្រះលោហិតផ្ទាល់របស់ព្រះអង្គ ។

ព្រះគម្ពីរហេព្រើរ ៩:២២

ទោសសម្រាប់អំពើបាប ដែលត្រូវតែស្លាប់ គឺត្រូវបង់ថ្លៃ ដោយការជំនួសដ៏គ្រប់លក្ខណ៍ ដែលមិនមានការបាត់បង់នូវជីវិតរបស់ព្រះនៅក្នុងឈាមរបស់គាត់ ដែលមានអំពើបាបនោះ ។ គឺត្រូវតែមកចាប់កំណើតដោយព្រះវិញ្ញាណបរិសុទ្ធ និងកើតជាមួយនឹងស្រីព្រហ្មចារី គឺជាព្រះយេស៊ូវ ដែលទ្រង់មិនដែលមានជាប់ខ្សែស្រឡាយសាច់ឈាម របស់លោកអ័ដាមនោះ ។ ទ្រង់បានត្រឡប់មកជាអ្នកជំនួសដ៏គ្រប់លក្ខណ៍នោះ គឺដែលទ្រង់បានមានបំណងបោះបង់ នូវជីវិតរបស់ទ្រង់ ដោយការបង្ហូរព្រះលោហិត ដែលគ្មានទោសផ្ទាល់របស់ព្រះអង្គនោះ ។

## ខ. តាមរយៈព្រះលោហិតព្រះយេស៊ូវ នោះយើងមានៈ

### ១. ការអត់ទោសនូវអំពើបាប

ការប្រោសលោះរបស់យើង គឺមាននៅក្នុងព្រះលោហិត របស់ព្រះយេស៊ូវ ។

ព្រះគម្ពីរអេភេសូរ ១:១៧

ព្រះគម្ពីរ ១ពេត្រុស ១:១៨-១៩

### ២. ភាពយុត្តិធមិ និងសេចក្តីសង្គ្រោះ

យើងបានទទួលនូវភាពយុត្តិធមិ និងសេចក្តីសុចរិតរបស់ផងព្រះ គឺដោយសារការកែជាថ្មីឡើងវិញ ដល់ជីវិតរបស់យើង ដោយព្រះលោហិតរបស់ព្រះយេស៊ូវ ។

ព្រះគម្ពីររ៉ូម ៥:៨-៩

សេចក្តីយុត្តិធមិដ៏គ្រប់លក្ខណ៍របស់ព្រះ គឺត្រូវបានចម្អែត ហើយយើងក៏ត្រូវបានទទួលនូវសេចក្តីសង្គ្រោះ រួចពីសេចក្តីក្រោធរបស់ផងព្រះ ពីព្រោះព្រះយេស៊ូវ ទ្រង់បានត្រឡប់មកជាអ្នកជំនួសរបស់យើង ហើយក៏បានរងជំនួសនូវទោសនៃសេចក្តីស្លាប់របស់យើង ដោយការបង្ហូរព្រះលោហិតរបស់ទ្រង់នៅលើឈើឆ្កាងនោះឯង ។ មានតែការយកចំណែកនៃការបង្ហូរ ព្រះលោហិតរបស់ព្រះយេស៊ូវ ដែលជាជីវិតរបស់ផងព្រះទេ ដែលអាចធ្វើឱ្យយើងមានជីវិតរបស់ព្រះម្តងទៀត នៅក្នុងយើងនោះ ។

ព្រះគម្ពីរយ៉ូហាន ៦:៥៣

### ៣. ការប្រកបគ្នា

ព្រះលោហិតរបស់ព្រះយេស៊ូវ នឹងរេីគ្រប់ទាំងអស់ដែលជាផលរបស់អំពើបាប ដែលមាននៅក្នុងជីវិតរបស់យើងនោះ ដើម្បីឱ្យយើងបានកើតជាថ្មីម្តងទៀត ដែលមានជីវិតរបស់ផងព្រះ នោះយើងអាចទទួលនូវការកែជាថ្មីឡើងវិញបាន ។

ព្រះគម្ពីរ ១យ៉ូហាន ១:៧

### ៤. ការប្រោសលោះ

ការប្រោសលោះរបស់យើង និងការអត់ទោសបាបទាំងស្រុងរបស់យើង គឺតាមរយៈព្រះលោហិតរបស់ទ្រង់ ។

ព្រះគម្ពីរកូល៉ុស ១:១៣-១៤

បើគ្មានការទទួលនូវយញ្ញបូជា នៃការប្រោសលោះ និងអំណោយទាននៃសេចក្តីសង្គ្រោះរបស់ព្រះ តាមរយៈការបង្ហូរព្រះលោហិត របស់ព្រះយេស៊ូវទេ នោះគ្មានផ្លូវណាសម្រាប់មនុស្សលោក ឱ្យបានទទួលនូវការអត់ទោស និងការកែជាថ្មីឡើងវិញបាននោះឡើយ ។

ព្រះគម្ពីរ ហេព្រើរ ៩:២២

ព្រះគម្ពីរ ហេព្រើរ ៩:១២,១៤

ដូច្នេះ ព្រះទ្រង់បានលាងសម្អាតយើងចេញពីភាពមានទោស និងធ្វើឱ្យយើងមានលទ្ធភាពដើរនៅក្នុងព្រះវត្តមានរបស់ព្រះហើយ ។

៥. **ដោយគ្មានស្លាកស្នាម** - ព្រះគម្ពីរអេភេសូរ ៥:២៧

៦. **មានលទ្ធភាពក្នុងការបម្រើ**

តាមរយៈព្រះលោហិតរបស់ព្រះយេស៊ូវ នោះយើងត្រូវបានសម្អាត ដើម្បីឱ្យយើងអាចបម្រើព្រះបាន ។ ព្រះគម្ពីរហេព្រើរ ៩:១៤ ។

៧. **ការបញ្ជាក់ភស្តុតាង**

គ្រាន់តែលោកអ័ដាមបានដើរជាប្រចាំថ្ងៃ ក្នុងការប្រកបនឹងព្រះវត្តមានរបស់ព្រះ គឺនៅមុនពេលដែលគាត់បានធ្វើបាប ។ ឥឡូវនេះ ដោយសារព្រះលោហិតរបស់ព្រះយេស៊ូវ នោះមនុស្សជាតិត្រូវបានទទួលនូវការដោះឱ្យរួចចេញពីគ្រប់ទាំងទោសកំហុសពីការផ្តន្ទាទោស ហើយអាចដើរចូលទៅក្នុងព្រះវត្តមានរបស់ព្រះដោយក្លាហានម្តងទៀតបានហើយ ។ ព្រះគម្ពីរហេព្រើរ ១០:១៩

៨. **សេចក្តីសុខសាន្ត**

សេចក្តីសុខសាន្ត និងការផ្សះផ្សា គឺបានធ្វើឱ្យមានលទ្ធភាព តាមរយៈព្រះលោហិតរបស់ព្រះអង្គហើយ ។ ព្រះគម្ពីរកូល៉ុស ១:១៩-២០ ។

៩. **មុខងារត្រូវបានកែជាថ្មីឱ្យទៅជាមុខងារដូចពីមុន**

អំពើបាប ធ្វើឱ្យមនុស្សជាតិលែងមានការជិតស្និទ្ធជាមួយនឹងព្រះ ។ ព្រះលោហិតរបស់ព្រះយេស៊ូវបានឈ្នះលើសាតាំង ទ្រង់បានប្រោសលោះ និងបានកែជាថ្មីឡើងវិញ ដល់មនុស្សជាតិឱ្យមានជីវិតរបស់ព្រះតាមរយៈកំណើតថ្មី ។ សាតាំងបានចូលមកលួចសម្លាប់ និងបំផ្លាញមនុស្ស ដែលព្រះទ្រង់បានបង្កើតមក ឱ្យដូចជាព្រះអង្គសិទ្ធសាធនៅលើផែនដីនេះ ។ តាមរយៈអំពើបាប មនុស្សបានបាត់បង់ភាពទំនាក់ទំនងរបស់គេជាមួយនឹងព្រះ ។ មនុស្សគ្មានជំនួយនៅក្នុងការប្រយុទ្ធជាមួយនឹងសាតាំង នៅក្នុងជីវិតរបស់គេ ។ តាមផែនការនៃសេចក្តីប្រោសលោះរបស់ព្រះ គឺតាមរយៈការបង្ហូរព្រះលោហិត របស់ព្រះរាជបុត្រានៃទ្រង់ផ្ទាល់ នោះមនុស្សអាចបានទទួលនូវការកែជាថ្មីឡើងវិញបានពេញលេញ ឱ្យទៅជាតួនាទីដែលបានបង្កើត នៅក្នុងភាពដើមរបស់គេវិញ ព្រមទាំងមានការប្រកបទាក់ទងចំពោះព្រះវិញ ។ តាមរយៈព្រះលោហិតរបស់ព្រះយេស៊ូវ ដោយនូវសេចក្តីជំនឿ និងការស្តាប់បង្គាប់ នោះមនុស្សដែលធ្លាប់បាន នៅក្នុងភាពអស់សង្ឃឹមគ្មានជំនួយចុះចាញ់ក៏បានទទួលនូវ ជ័យជម្នះឈ្នះលើខ្មាំងសត្រូវវិញ ។

១០. **ការគ្របបាំងលើការការពារ**

សូម្បីតែសម្តេចសង្ឃនៅគ្រាសញ្ញាចាស់ ក៏បានចាប់យកឈាមនៃកូនចៀមធ្វើជាយញ្ញបូជា និងបានចាក់ស្រោចវាទៅលើទីសន្តោសប្រោសរបស់ព្រះ គឺបានត្រឡប់ទៅជាការគ្របបាំង ឬការលុបលាងទោស សម្រាប់អំពើបាបរបស់ពួកបណ្តាជន សូម្បីតែរហូតដល់សព្វថ្ងៃនេះ គឺដោយនូវសេចក្តីជំនឿលើឈាមនៃកូនចៀម នោះក៏បានត្រឡប់ទៅជាការ

គ្របបាំងលើការការពារ សម្រាប់ការប្រោសលោះដល់មនុស្សជាតិដែរ ។

**១១. ជ័យជម្នះ**

តាមរយៈព្រះលោហិតរបស់ព្រះយេស៊ូវ នោះយើងមាន ជ័យជម្នះហើយ!

ពេលដែលយើងដើរដោយនូវការអត់ទោស នូវការស្តាប់បង្គាប់ដល់ព្រះ និងដោយសេចក្តីជំនឿ នោះយើងអាចនិយាយយ៉ាងក្លាហានថា:

***"វេលាសាតាំង អញបានទទួលការគ្របបាំងដោយព្រះលោហិតរបស់ព្រះយេស៊ូវហើយ!"***

***"ក្រុមគ្រួសាររបស់អញ និងការកាន់កាប់របស់អញគឺត្រូវបានទទួលការគ្របបាំងដោយព្រះលោហិតរបស់ព្រះ យេស៊ូវហើយ!"***

***"វេលាសាតាំង អញបានទទួលនូវជ័យជម្នះដោយសារព្រះលោហិតរបស់ព្រះយេស៊ូវហើយ!"***

***"ដោយសារតែព្រះលោហិតរបស់ព្រះយេស៊ូវនោះឯង មិនអាចប៉ះពាល់អញបានទេ!"***

សូម្បីតែព្រះយេស៊ូវក៏បានឈ្នះលើសាតាំង ដោយសារព្រះលោហិតរបស់ព្រះអង្គដែរ នោះយើងក៏អាចមានជ័យជម្នះដោយសារព្រះលោហិតរបស់ព្រះយេស៊ូវដែរ! ដោយនូវការការពារនៃព្រះលោហិតរបស់ព្រះអង្គ នោះគ្មានប្រដាប់គ្រឿងសឹកណាមកប្រឆាំងទាស់នឹងយើងឡើយ យើងបានចម្រើនឡើងហើយ ។

ព្រះគម្ពីរវិវរណៈ ១២:១១ក

យើងយកឈ្នះលើសាតាំង ដោយព្រះលោហិតរបស់ព្រះយេស៊ូវ ។ កូនសោរនៃសិទ្ធិអំណាចគឺជាព្រះលោហិតរបស់ព្រះយេស៊ូវ ដែលបានប្រទានមកឱ្យយើងម្នាក់ៗ ដែលតាមរយៈព្រះលោហិតនោះ គឺបានត្រូវទទួលនូវការប្រោសលោះហើយ ។ ដោយនូវកូនសោរដ៏មានពេញដោយអំណាច នៃព្រះលោហិតរបស់ព្រះអង្គ នោះយើងគឺជាអ្នកបានទទួលនូវជ័យជម្នះ ហើយសាតាំងនឹងនៅតែទទួលនូវការបរាជ័យ នៅក្នុងជីវិតរបស់យើង ។

## III. ព្រះបន្ទូលរបស់ព្រះគឺជាកូនសោរជ័យជម្នះ សម្រាប់ការទទួលជោគជ័យ

**ក. ដោយសារសេចក្តីបន្ទាល់**

ព្រះគម្ពីរវិវរណៈ ១២:១១ក

"ពាក្យសម្តីនៃទីបន្ទាល់របស់ពួកគេ" គឺអាចគ្រាន់តែបានបកប្រែទៅតាមន័យត្រង់ទៅលើ "ព្រះបន្ទូលនៅក្នុងទីបន្ទាល់របស់ពួកគេ" តែប៉ុណ្ណោះ ។ រីឯទីបន្ទាល់របស់ពួកយើងវិញគឺជាអ្វីដែលយើងបាននិយាយចេញទៅនោះ ។ នៅពេលដែលយើងឈប់និយាយពីបញ្ហាណាមួយ នោះចិត្តរបស់យើង ឬការភ័យខ្លាចរបស់យើង នឹងចាប់ផ្តើមនិយាយដោយក្លាហានពីអ្វីដែលជាព្រះបន្ទូលរបស់ព្រះបានចែងមក អំពីស្ថានការណ៍របស់យើង បន្ទាប់មក យើងក៏នឹងបានទទួលនូវជ័យជម្នះ ។

**ខ. ព្រះបន្ទូលនាំមកនូវជ័យជម្នះ**

ព្រះបន្ទូលរបស់ព្រះបានមកតាមលំដាប់លំដោយ ជាបន្តចេញពីមាត់របស់យើង វាគឺជាការចាំបាច់ដែលយើងអានសិក្សា និងជញ្ជឹងគិតពិចារណាទៅលើព្រះបន្ទូលនោះ ។ បន្ទាប់

មកវានឹងបានត្រឡប់ទៅជាមានឫសគល់កាន់តែជ្រៅ សេចក្តីជំនឿក៏កាន់តែបានខ្ជាប់ខ្ជួន នៅក្នុងជីវិតរបស់យើង ។

ព្រះគម្ពីរ ១យ៉ូហាន ២:១៣-១៤

មនុស្សកម្លោះទាំងនេះបាននិយាយថា ដើម្បីឱ្យបានទៅជាអ្នកមានជ័យជម្នះដ៏ខ្លាំងក្លា គឺដោយសារតែពួកគេមានព្រះបន្ទូលរបស់ព្រះខ្ជាប់ខ្ជួនជានិច្ចនោះឯង ។ នៅពេលដែលពួកគេបាននិយាយយ៉ាងអង់អាចនូវព្រះបន្ទូលនោះ ចេញពីមាត់របស់ពួកគេ ដោយនូវសិទ្ធិអំណាច និងអំណាចគ្រប់គ្រងដែលបានប្រទានមកពីព្រះរបស់ពួកគេ នោះពួកគេក៏បានត្រូវទទួលនូវជ័យជម្នះពីអ្នកកំណាចឃោរឃៅនោះហើយ ។ នៅពេលដែលត្រូវទទួលនូវសេចក្តីល្បួង នោះព្រះយេស៊ូវទ្រង់បានមានបន្ទូលថា "ណែ៎អារក្ស ត្បិតមានសេចក្តីចែងទុកមកថា" ។

## គ. ដាវរបស់ព្រះវិញ្ញាណ

នៅក្នុងព្រះគម្ពីរអេភេសូរ គ្រឿងសឹករបស់យើងគឺសម្រាប់ទទួលនូវជ័យជម្នះក្នុងសមរភូមិ ដែលត្រូវបានពណ៌នាដូច្នេះ "ដាវរបស់ព្រះវិញ្ញាណ គឺជាព្រះបន្ទូលរបស់ព្រះ" ។ព្រះបន្ទូលរបស់ព្រះ នៅពេលដែលយើងនិយាយចេញពីមាត់របស់យើងទៅ ក៏បានត្រឡប់ទៅជាគ្រឿងសឹកដ៏មានឫទ្ធិអំណាចអាចប្រឆាំងទាស់នឹងសាតាំង ដែលគ្មានការការពារនោះបាន ។ ពេលដែលយើងនិយាយពីព្រះបន្ទូលរបស់ព្រះ ដោយមានសិទ្ធិអំណាច នោះយើងនឹងទទួលជ័យជម្នះលើសាតាំងនៅក្នុងជីវិតរបស់យើងបាន ។ ដាវរបស់ព្រះវិញ្ញាណគឺជាព្រះបន្ទូលរបស់ព្រះ ។ ព្រះគម្ពីរអេភេសូរ ៦:១៧ ។

## ឃ. ព្រះយេស៊ូវគឺជាជ័យជម្នះ

ព្រះគម្ពីរវិវរណៈ ១៩:១៣-១៦

***ទ្រង់ជាស្តេចលើអស់ទាំងស្តេច***
***ជាព្រះអម្ចាស់លើអស់ទាំងព្រះអម្ចាស់***

តើអ្វីទៅជាគ្រឿងសឹកៈ ព្រះបន្ទូលរបស់ព្រះគឺជាដាវរបស់ព្រះបន្ទូល ។

ហើយចុះតើព្រះបន្ទូលព្រះនៅកន្លែងណា គឺនៅក្នុងមាត់របស់ទ្រង់! យើងត្រូវការទទួលនូវព្រះបន្ទូលព្រះ នៅក្នុងវិញ្ញាណរបស់យើង ។ ប៉ុន្តែ សាតាំងគឺមិនអាចទទួលនូវការបរាជ័យបានទេ ទាល់តែយើងនិយាយព្រះបន្ទូលចេញពីមាត់របស់យើងទៅ ។

## ង. និយាយនូវព្រះបន្ទូល

តើព្រះយេស៊ូវទ្រង់បានឈ្នះលើសេចក្តីល្បួងរបស់សាតាំងដោយរបៀបណា? គឺទ្រង់មានព្រះបន្ទូលថា "មានសេចក្តីចែងទុកមកដូច្នេះ" ព្រះគម្ពីរម៉ាថាយ ៤:១០ ។

## ច. ព្រះនាមរបស់ព្រះយេស៊ូវគឺជាព្រះបន្ទូលព្រះ

ព្រះគម្ពីរវិវរណៈ ១៩:១៣ និង ព្រះគម្ពីរយ៉ូហាន ១:១

## ឆ. ព្រះបន្ទូលមិនអាចត្រឡប់ជាទៅទទេបានឡើយ

***យើងខ្ញុំវិសេសជាងអ្នកដែលមានជ័យជម្នះទៅទៀត ។***
***យើងមានជ័យជម្នះដោយនូវព្រះនាមទ្រង់ ។***

ព្រះទ្រង់មានព្រះបន្ទូលដោយនូវអំណាច នៃព្រះបន្ទូលរបស់ទ្រង់ តាមរយៈហោរាអេសាយ ។

ព្រះគម្ពីរអេសាយ ៥៥:១១

ព្រះទ្រង់មានព្រះបន្ទូលដោយនូវអំណាច នៃការប្រោសឱ្យជានៃព្រះបន្ទូលរបស់ទ្រង់ តាមរយៈស្តេចដាវីឌ ។

ព្រះគម្ពីរទំនុកដំកើង ១០៧:២០

ព្រះបន្ទូលដែលយើងនិយាយ ដោយនូវសិទ្ធិអំណាច គឺជាការខិតខំប្រឹងប្រែង ដោយនូវការទទួលស្គាល់រឿងរ៉ាវ ដែលគាប់ព្រះហឫទ័យដល់ព្រះ ។ ព្រះបន្ទូលព្រះបានសន្យានឹងយើងថា នឹងបានសម្រេច!

## ជ. ព្រះបន្ទូលអាចបង្កើត

ព្រះបន្ទូលព្រះមានអំណាចអាចបង្កើតបាន ។ ព្រះគម្ពីរហេព្រើរ ១១:៣ ។

តើព្រះទ្រង់បានបង្កើតផែនដីមកយ៉ាងដូចម្ដេច? គឺទ្រង់មានព្រះបន្ទូល ។

## ឈ. ព្រះបន្ទូលមានសិទ្ធិអំណាច

ព្រះយេស៊ូវទ្រង់មានព្រះបន្ទូលដោយអំណាច។ ព្រះគម្ពីរលូកា ៤:៣៦

## ញ. ព្រះបន្ទូលចូល ព្រះបន្ទូលចេញ!

វាគឺជាការល្អក្នុងការស្គាល់នូវព្រះបន្ទូល ប៉ុន្តែរហូតមកដល់ពេលដែលយើងបានប្រជុំ ពីស្ថានការណ៍របស់យើង ដោយមានព្រះបន្ទូលព្រះ និយាយចេញពីមាត់យើងទៅ នោះយើងនឹងមិនមានជ័យជម្នះឡើយ! ព្រះយេស៊ូវ ទ្រង់មានព្រះបន្ទូលដោយមានសិទ្ធិអំណាច និងអំណាចចេស្ដា ។

អំពីប្រភេទនៃសេចក្ដីជំនឿដែលមកពីព្រះ:

***អ្នកជឿលើព្រះបន្ទូល***
***និយាយព្រះបន្ទូលពីគ្រាប់ពូជខុសឆ្គង***
***មើលឃើញព្រះបន្ទូល បំពេញដោយនូវការអស្ចារ្យ ។***

ព្រះបន្ទូលរបស់ព្រះ គឺមិនមែនខុសឆ្គងឡើយ ពេលដែលយើងនៅតែបន្តនិយាយ ដោយនូវសិទ្ធិអំណាច និងអំណាចគ្រប់គ្រង ។ វាគឺដូចជាគ្រាប់ពូជដែលនឹងដុះលូតលាស់ និងបង្កើតផលផ្លែឡើង ដូចជាគ្រាប់ពូជដ៏តូចល្អិតមួយ ដែលបង្កើតបានជាដើមឈើមួយយ៉ាងធំ ។ កសិករម្នាក់មិនបានដឹងថា គ្រាប់ពូជវាលូតលាស់ឡើងប្រចាំសប្ដាហ៍ ឬប្រចាំខែនោះទេ ។ គាត់ជឿថា ប្រសិនបើវាជាផ្នែកមួយរបស់គាត់ គ្រាប់ពូជនោះនឹងលូតលាស់ឡើងហើយ ។ សម្រាប់យើងគឺគ្រាន់តែអនុវត្តអំណាចគ្រប់គ្រងលើផែនដីនេះ ជាលំដាប់លំដោយប៉ុណ្ណោះ គឺដែលយើងក៏ត្រូវបានបង្កើតមក ហើយព្រះយេស៊ូវទ្រង់បានប្រទានឱ្យយើង នូវពួកជំនុំរបស់ព្រះអង្គ គឺជាកូនសោរនៃសិទ្ធិអំណាច សម្រាប់ជ័យជម្នះក្នុងសង្គ្រាមខាងឯវិញ្ញាណប៉ុណ្ណោះ ។ នៅពេលដែលយើងបានរុករកឃើញកូនសោរទាំងនេះ និងរបៀបប្រើប្រាស់ពួកវាផ្ទឹតផ្ទង់ នោះយើងនឹងរកឃើញដោយខ្លួនឯងនូវការរស់នៅ ដែលមានជ័យជម្នះលើការតស៊ូនៃជីវិត ។ យើងនឹងរកឃើញដោយខ្លួនឯងនូវការបានត្រឡប់មកជាអ្វី ដែលព្រះយេស៊ូវទ្រង់បានប្រកាសរួចទៅហើយថា យើងនឹងមាននៅ:

ចូរស្វែងរកដើម្បីនិយាយ និងធ្វើតាមបំណងព្រះហឫទ័យរបស់ព្រះ ដែលនគររបស់ទ្រង់ និងបំណងព្រះហឫទ័យរបស់ទ្រង់ អាចត្រូវបានសម្រេចនៅលើផែនដីនេះ ។ ព្រះទ្រង់បានឃ្លាំមើលទៅព្រះបន្ទូលរបស់ទ្រង់ ដើម្បីឱ្យបានសម្ដែងចេញមក ។ ព្រះយេស៊ូវទ្រង់បានបង្រៀនយើងឱ្យអធិស្ឋានថា ឱព្រះអម្ចាស់អើយ! សូមឱ្យបំណងព្រះហឫទ័យទ្រង់បានសម្រេចនៅផែនដី ដូចជានៅស្ថានសួគ៌ដែរ ។ តើខ្ញុំកំពុងតែនិយាយពីព្រះបន្ទូលទ្រង់ និងពីបំណងព្រះហឫទ័យរបស់ទ្រង់នៅក្នុងតំបន់នៃសិទ្ធិអំណាចរបស់ខ្ញុំឬ? ចូរចាប់យកកូនសោរជ័យជម្នះ គឺជាព្រះបន្ទូលព្រះ ហើយនិយាយពីព្រះបន្ទូល ។

ព្រះគម្ពីរយេរេមា ១:១២

ព្រះគម្ពីរ ១ពេត្រុស ២:២៤ខ

ព្រះគម្ពីរទំនុកដំកើង ១០៧:២០

ព្រះគម្ពីរអេសាយ ៥៤:១៧

ព្រះគម្ពីរភីលីព ៤:១៩

ព្រះគម្ពីរ ១យ៉ូហាន ២:១៤

យើងអាចមានជ័យជម្នះ ដោយសារព្រះបន្ទូលរបស់ទ្រង់ ។ ចូរអធិស្ឋានដូចជាព្រះយេស៊ូវបានអធិស្ឋាន ។

ព្រះគម្ពីរម៉ាថាយ ៦:១០

## ក្រុមពិភាក្សា

១. ហេតុអ្វីបានជាជីវិតនៃសាច់ព្រះហស្ត ត្រូវតែបាននៅក្នុងឈាម?

២. ចូរពិភាក្សាពីរបៀបឈាមនៃកូនចៀម បានត្រឡប់មកជាការគ្របបាំងលើការការពារ សម្រាប់ការប្រោសលោះដល់មនុស្សជាតិ ។

៣. តើរបស់អ្វីខ្លះដែលសាតាំងបានលួចពីមនុស្សជាតិ បន្ទាប់ពីការធ្លាក់ចុះ ដែលព្រះយេស៊ូវទ្រង់បានកែជាថ្មីឡើងវិញបន្ទាប់ពីការរស់ពីសុគតឡើងវិញ?

## ការសិក្សាដោយខ្លួនឯង

១. ព្រះបន្ទូលគឺមានពេញដោយអំណាច ។ ព្រះបន្ទូលទ្រង់បានបង្កើត ។ ចូរសរសេរចុះនូវពេលវេលាទាំងពីរ ដែលលោកអ្នកបានបង្កើតរបស់ខ្លះ ដោយពាក្យសម្ដីរបស់លោកអ្នក ដែលល្អ ឬអាក្រក់ ។

២. យើងឈ្នះដោយសារឈាមនៃកូនចៀម និងដោយសារពាក្យសម្ដីរបស់យើង: ...............។ ចូរមើលទៅខគម្ពីរ ហើយបំពេញនៅកន្លែងដែលខ្វះ ...............។

៣. សាតាំងមិនបានទទួលបរាជ័យ ទាល់តែលោកអ្នកនិយាយពីព្រះបន្ទូល (នោះគឺជាវិញ្ញាណរបស់លោកអ្នក) ចេញពីមាត់របស់លោកអ្នកទៅ ។ ចូរធ្វើការអនុវត្តន៍នូវការនិយាយព្រះបន្ទូរបស់ព្រះឱ្យខ្លាំងៗ (កុំគ្រាន់តែគិតពីវាឡើយ) ។

# សិទ្ធិអំណាចរបស់អ្នកជឿ

## *មេរៀនទី ៧: ព្រះនាមព្រះយេស៊ូវ*

### I. ព្រះនាមព្រះយេស៊ូវ គឺជាកូនសោរជ័យជម្នះសម្រាប់ការយកផោតជ័យ

នៅពេលដែលយើងប្រើព្រះនាមព្រះយេស៊ូវ នោះយើងកំពុងតែនិយាយដោយនូវព្រះនាមនោះ ដែលយើងនិយាយពីព្រះនាមព្រះយេស៊ូវនោះ ទុកដូចជាទ្រង់បានគង់នៅក្នុងស្ថានការណ៍នោះឯង ។ ទ្រង់បានប្រទានឱ្យយើងនូវសិទ្ធិ ដើម្បីប្រើព្រះនាមព្រះអង្គ ។ ពេលដែលយើងប្រើនូវសិទ្ធិអំណាចនោះ គឺយើងអាចធ្វើឱ្យមានពីជ័យជម្នះមួយ ទៅជ័យជម្នះមួយទៀតបាន ។

### ក. សិទ្ធិគួរឱ្យភ័យព្រួយ

ការងាររបស់ព្រះយេស៊ូវគឺពេញលេញ តាំងពីមុនមកម្លេះ គឺដែលព្រះអង្គបានបំពេញនៅលើឈើឆ្កាងនោះឯង គ្មានអ្នកណាម្នាក់ហ៊ាននិយាយពីព្រះនាមរបស់ព្រះបានឡើយ ។ ពួកគេត្រូវបានទទួលនូវការរាប់បញ្ចូល ទៅក្នុងទីដ៏បរិសុទ្ធបំផុត ហើយដែលបានដឹងត្រឹមតែសម្តេចសង្ឃមួយអង្គប៉ុណ្ណោះ ។ មានព្រះគម្ពីរមួយដែលបានចែងមកពីប្រវត្តិ គឺពីហេតុផលនៃអ្នកដឹកនាំជនជាតិយូដា ក៏បានបាក់ទឹកចិត្តជាមួយនឹងព្រះយេស៊ូវ គឺដោយសារតែទ្រង់បានដឹង និងធ្លាប់បានប្រើព្រះនាមរបស់ទ្រង់ ដែលជាឯកសិទ្ធិដ៏គួរឱ្យខ្លាច គឺវាមិនគួរនឹងត្រូវបានចាប់យកនូវពន្លឺនោះទេ ។

### ខ.ទីសម្គាល់នឹងជាប់តាមអ្នកជឿព្រះនាមព្រះយេស៊ូវ

ព្រះគម្ពីរម៉ាកុស ១៦:១៥-១៨

ចាប់តាំងពីភាសាដើមដែលមិនបានដាក់វណ្ណយុត្តិ ឱ្យបានគ្រប់នោះមក វាអាចគ្រាន់តែត្រូវបានបកប្រែដោយមានភាពទៀងទាត់យ៉ាងដូច្នេះ "ទីសម្គាល់នេះនឹងជាប់តាមដល់អស់អ្នកដែលជឿលើព្រះនាមរបស់ខ្ញុំ ..."

### គ. ការព្ញមកពីព្រះ

នៅពេលដែលព្រះយេស៊ូវទ្រង់បានកំពុងតែបំពេញ ព្រះរាជកិច្ចនៅលើផែនដីនេះ នោះទ្រង់បានធ្វើការដើម្បីជាប្រយោជន៍ដល់ព្រះវរបិតារបស់ទ្រង់ ។

ព្រះគម្ពីរយ៉ូហាន ៥:១៩

ឥឡូវនេះ នៅពេលដែលយើងបំពេញការងារនៅលើផែនដីនេះ យើងត្រូវតែធ្វើឱ្យបានជាប្រយោជន៍ដល់ព្រះរាជបុត្រា ។ យើងមិនត្រូវប្រើព្រះនាមព្រះយេស៊ូវ ឱ្យបានតែការទទួលស្គាល់នូវការសម្រេចចិត្តរបស់យើងផ្ទាល់ ដោយគ្មានការចាប់យកពេលវេលាជាដំបូងនោះទេ គឺឱ្យបានស្តាប់ព្ញមកពីព្រះវិញ ។

### ឃ. ការប្រើព្រះនាមជាអសាឥតការ

ដើម្បីខិតខំប្រឹងប្រែងប្រើព្រះនាមព្រះយេស៊ូវ ឱ្យបានតែការទទួលស្គាល់ពីការសម្រេចចិត្តផ្ទាល់ខ្លួន ដោយគ្មានការវិនិច្ឆ័យតាមបំណងព្រះហឫទ័យព្រះ នោះបានន័យប្រើព្រះនាមរបស់ទ្រង់ជាអសាឥតការហើយ ។ វាជាឯកសិទ្ធិដ៏គំរក់ក្នុងការប្រើព្រះនាមរបស់ព្រះយេស៊ូវនោះ ។ ចូរស្តាប់ព្ញផ្ទាល់ពីព្រះមុនពេលប្រើព្រះនាមរបស់ទ្រង់ ។

ព្រះគម្ពីរចោទិយកថា ៥:១១

### ង. ព្រះនាមលើអស់ទាំងនាមផង

ព្រះនាមរបស់ព្រះយេស៊ូវ គឺខ្ពស់លើអស់ទាំងនាមផង ។

ព្រះគម្ពីរភីលីព ២:៩-១១

១. គ្រប់ទាំងជម្ងឺនិងជម្ងឺរោគា គឺសុទ្ធតែមានឈ្មោះ ។

២. គ្រប់ទាំងអំណាចនៃវិញ្ញាណអាក្រក់ ក៏មានឈ្មោះរបស់វាដែរ ។

៣. គ្រប់មនុស្សទាំងអស់សុទ្ធតែមានឈ្មោះ ។

៤. គ្រប់ទាំងគម្រោងការណ៏របស់អារក្ស គឺសុទ្ធតែមានឈ្មោះ ។

៥. ពេលដែលព្រះនាមព្រយេស៊ូវ ត្រូវបាននិយាយចេញទៅ អំណាចវិញ្ញាអាក្រក់ក៏ត្រូវចាកចេញទៅដែរ ។

៦. ពេលដែលព្រះនាមព្រះយេស៊ូវ ត្រូវបាននិយាយចេញទៅជម្ងឺមហារីក និងគ្រប់ជម្ងឺដទៃទៀត ត្រូវតែក្រាបចុះ ។

៧. ពេលដែលព្រះនាមព្រះយេស៊ូវ ត្រូវបាននិយាយចេញទៅ គម្រោងការណ៏របស់សាតាំងក៏ត្រូវបរាជ័យ ។

៨. ព្រះនាមព្រះយេស៊ូវ គឺជានាមលើអស់ទាំងនាមផង ។ គ្រប់ទាំងជង្គង់ត្រូវក្រាប គឺចុះចូលចំពោះជាព្រះរបស់ព្រះយេស៊ូវ នៅពេលដែលព្រះនាមព្រះយេស៊ូវត្រូវបាននិយាយចេញទៅ ដោយសេចក្តីជំនឿ ។

## ច. ពួកវិញ្ញាណអាក្រក់ចុះចូលនឹងព្រះនាម

ពួកវិញ្ញាណអាក្រក់ស្គាល់អំណាច នៃព្រះនាមព្រះយេស៊ូវ ហើយពួកវានឹងចុះចូលចំពោះព្រះនាមនោះ ។

ព្រះគម្ពីរលូកា ១០:១៧-១៩ និង ម៉ាថាយ ២៨:១៨

សិទ្ធិអំណាចទាំងអស់បានត្រូវប្រទានមកព្រះយេស៊ូវ ។ ទ្រង់ក៏បានប្រទានសិទ្ធិអំណាចនោះមកយើងរាល់គ្នា ដោយសារយើងប្រើព្រះនាមព្រះយេស៊ូវ ។

ដោយសារព្រះយេស៊ូវ ទ្រង់ជាព្រះរាជបុត្រារបស់ព្រះ ទ្រង់មានគ្រប់ទាំងសិទ្ធិអំណាច នៅក្នុងនគរស្ថានសួគ៌ ។

ដោយសារព្រះយេស៊ូវ ទ្រង់ជាកូនមនុស្ស ទ្រង់មានគ្រប់ទាំងសិទ្ធិអំណាចនៅលើផែនដី ។

## ឆ. ជឿលើព្រះនាម

យើងបានទទួលបញ្ជាឱ្យជឿលើព្រះនាមព្រះយេស៊ូវ ។

ព្រះគម្ពីរ ១យ៉ូហាន ៣:២៣

យើងត្រូវជឿលើព្រះនាមព្រះយេស៊ូវ ឱ្យបានជីវិតអស់កល្បជានិច្ច ។

ព្រះគម្ពីរយ៉ូហាន ៣:១៨

ព្រះគម្ពីរយ៉ូហាន ២០:៣១

យើងអាចមានការធានារ៉ាប់រងដ៏ពេញលេញ នៃសេចក្តីសង្គ្រោះរបស់យើង ពីព្រោះយើងជឿលើព្រះនាមទ្រង់ ។

## ជ. ទូលសូមដោយនូវព្រះនាមទ្រង់

យើងបានទទួលនូវការបង្រៀន ក្នុងការទូលសូមដោយនូវព្រះនាមព្រះយេស៊ូវ ។

ព្រះគម្ពីរយ៉ូហាន ១៤:១២-១៤

ពេលដែលព្រះយេស៊ូវទ្រង់បានចាកចេញ ទៅឯព្រះវរបិតា នោះទ្រង់បានបង្រៀនដល់អ្នកដើរតាមទ្រង់ ឱ្យប្រើព្រះនាមរបស់ទ្រង់ ។ ទ្រង់បានប្រាប់ពួកគេថា អ្វីដែលពួកគេនឹងទូលសូម នោះទ្រង់នឹងប្រទានឱ្យ ដើម្បីឱ្យព្រះវរបិតាទ្រង់បានតម្កើងឡើងនៅក្នុងព្រះរាជបុត្រា ។

ព្រះគម្ពីរយ៉ូហាន ១៥:១៦

ព្រះគម្ពីរយ៉ូហាន ១៦:២៣-២៤

យើងបានទទួលនូវការបង្រៀន ឱ្យទូលសូមក្នុងព្រះនាម

ព្រះយេស៊ូវ ។ ចយ និងខ្ញុំក៏បានទូលសូមសម្រាប់ជាតិសាសន៍ទាំងផងដែរ ។

ព្រះគម្ពីរទមនុកដំកើង ២:៨

យើងបានទូលសូមតិចពេច ។

### ឈ. ចូរធ្វើគ្រប់ការនៅក្នុងព្រះនាមទ្រង់

យើងត្រូវតែធ្វើគ្រប់ការនៅក្នុងព្រះនាមព្រះយេស៊ូវ ។ អ្វីទៅដែលជាការអស្ចារ្យដ៏ចម្បងនេះ!

ព្រះគម្ពីរកូល៉ុស ៣:១៧

យើងគួរតែប្រឹក្សាពីគ្រប់យ៉ាង ដែលយើងគួរតែធ្វើឱ្យបានសមរម្យ នៅក្នុងព្រះនាមព្រះយេស៊ូវ ។ ដើម្បីធ្វើយ៉ាងដូច្នេះនោះអាចឱ្យមានការរំជើបរំជួល ទៅតាមផ្លូវជីវិតរបស់យើង ។

## II. ពួកសាវ័កបានប្រើព្រះនាមព្រះយេស៊ូវ

ពួកសាវ័កនិងពួកអ្នកជឿដំបូង ដែលនៅក្នុងព្រះគម្ពីរកិច្ចការ ក៏បានប្រើយ៉ាងអង់អាចពីព្រះនាមព្រះយេស៊ូវ ដោយមានលទ្ធផលនៃការអស្ចារ្យជាច្រើន ។

### ក.អំណាចចេស្តានៅក្នុងព្រះនាម

ព្រះគម្ពីរកិច្ចការ ៣:១-១០

### ខ. សេចក្តីជំនឿនៅក្នុងព្រះនាម

លោកសាវ័កពេត្រុសបានពន្យល់ថា កូនសោរដើម្បីប្រើព្រះនាមព្រះយេស៊ូវ គឺជាការបញ្ចេញនូវសិទ្ធិអំណាចនៃព្រះនាមដោយសេចក្តីជំនឿ ។ ព្រះគម្ពីរកិច្ចការ ៣:១៦ ។

### គ. ការប្រោសឱ្យជានៅក្នុងព្រះនាម

ជាលទ្ធផលនៃការប្រោសឱ្យជានេះ លោកសាវ័កពេត្រុសនិងយ៉ូហានត្រូវបានគេចាប់ខ្លួន គឺចាប់ឃុំទុកអស់រយៈពេលមួយយប់ ហើយក៏មានការគម្រាមកំហែង ដោយពួកអ្នកដឹកនាំសាសនា មិនឱ្យនិយាយពីព្រះនាមព្រះយេស៊ូវទៅទៀត ។ លោកសាវ័កពេត្រុសបានឆ្លើយយ៉ាងអង់អាច ទៅនឹងសំណួររបស់ពួកគេអំពីការប្រោសឱ្យជា ដោយការនិយាយនេះ ។

ព្រះគម្ពីរកិច្ចការ ៤:១០

ចូរជឿលើព្រះនាមព្រះយេស៊ូវទៅ ទ្រង់នឹងនាំមកនូវការអស្ចារ្យ តាមរយៈជីវិតរបស់អ្នកជឿ ។

### ឃ. សេចក្តីសង្គ្រោះនៅក្នុងព្រះនាម

ជាលទ្ធផលរបស់លោកសាវ័កពេត្រុស និងយ៉ូហានក្នុងការប្រើព្រះនាមព្រះយេស៊ូវ ក្នុងការបំពេញការងារប្រោសឱ្យជាដល់មនុស្សពិការ ចំនួនអ្នកជឿកើនឡើងរហូតដល់៥000 នាក់ ។ ព្រះគម្ពីរកិច្ចការ ៤:៤ ។

សេចក្តីសង្គ្រោះដើមដំបូងរបស់យើង គឺនៅក្នុងអំណាចព្រះនាមព្រះយេស៊ូវ ។

### ង. ការភ័យខ្លាចរបស់មនុស្សចំពោះព្រះនាមទ្រង់

លោកសាវ័កពេត្រុស និងយ៉ូហាន បានទទួលនូវការគំរាមកំហែងដោយពួកអ្នកដឹកនាំសាសនា មិនឱ្យនិយាយពីព្រះនាមនោះទៀត ។

ព្រះគម្ពីរកិច្ចការ ៤:១៧-១៨

### ច. ភាពអង់អាចនៅក្នុងព្រះនាម

នៅពេលមួយរំពេចនោះ វិញ្ញាណនៃភាពអង់អាចក៏បានមកសណ្ឋិតលើលោកសាវ័កពេត្រុស និងយ៉ូហាន ។

ព្រះគម្ពីរកិច្ចការ ៤:២៩-៣០

**ឆ. លោកភីលីពអធិប្បាយពីព្រះនាម**

ព្រះគម្ពីរកិច្ចការ ៨:១២

**ជ. ការចាប់ចងដោយសារព្រះនាម**

លោកសូលពីក្រុងតេសុសត្រូវបានបញ្ជូន ឱ្យទៅចាប់ចងអស់អ្នកណាដែលបានហៅតាមព្រះនាមព្រះយេស៊ូវ ។

ព្រះគម្ពីរកិច្ចការ ៩:១៤

**ឈ. ការជ្រើសរើសដើម្បីនាំព្រះនាមទ្រង់ទៅ**

លោកសាវ៉កប៉ុលត្រូវបានជ្រើសរើស ដោយព្រះដើម្បីនាំយកព្រះនាមព្រះយេស៊ូវ ទៅដល់លោកិយទាំងមូល ។

ព្រះគម្ពីរកិច្ចការ ៩:១៥

**ញ.ការអធិប្បាយដោយគ្មានការភ័យខ្លាចនៅក្នុងព្រះនាម ។**

ព្រះគម្ពីរកិច្ចការ ៩:២៧

## ក្រុមពិភាក្សា

១. ព្រះនាមព្រះយេស៊ូវ គឺខ្ពស់លើសអស់ទាំងនាមដទៃទៀត ។ ចូរធ្វើការពិភាក្សាពីរឿងរ៉ាវដាច់ខាតផ្សេងៗគ្នាពីការកត់ត្រារបស់លោកអ្នក ដែលមានព្រះនាម ។

២. តើមូលហេតុដូចម្តេចបានជាវិញ្ញាណអាក្រក់ ចុះចូលនឹងព្រះនាមព្រះយេស៊ូវ?

៣. ហេតុអ្វីបានជាគ្រប់យ៉ាង ត្រូវតែមានព្រះនាម?

## ការសិក្សាដោយខ្លួនឯង

១. ចូរគិតអំពីសេចក្តីសំខាន់របស់ព្រះនាម ។ តើលោកអ្នកមានមិត្តភក្តិជិតស្និទ្ធណានៅជាមួយ ដែលលោកអ្នកមិនស្គាល់ឈ្មោះរបស់គេ? ហេតុអ្វីបានជាលោកអ្នកគិតពីឈ្មោះរបស់មនុស្ស គឺជាការសំខាន់សម្រាប់ភាពជិតស្និទ្ធ?

២. ជាការពិតណាស់ ដែលការប្រើព្រះនាមព្រះយេស៊ូវ គឺជាលក្ខណៈចម្បង ។ ចូរចំណាយពេលស្តាប់ឮមកពីព្រះដើម្បីធ្វើការយល់ដឹងពីបំណងព្រះហឫទ័យព្រះ មុនពេលដែលលោកអ្នកប្រើព្រះនាមព្រះយេស៊ូវ ។

៣. ចូរធ្វើការអនុវត្តន៍ប្រើព្រះនាមព្រះយេស៊ូវ ដោយមានសេចក្តីជំនឿរឹងប៉ឹង ។ តើមានលទ្ធផលអស្ចារ្យអ្វីខ្លះបានកើតឡើង?

# សិទ្ធិអំណាចរបស់អ្នកជឿ

## *មេរៀនទី ៨: ជ័យជម្នះលើសង្គ្រាមខាងឯវិញ្ញាណ*

## I. ទីសម្គាល់ និងការអស្ចារ្យក្នុងព្រះនាមព្រះយេស៊ូវ

គ្រប់ទាំងជង្គង់ គ្រប់ទាំងវិញ្ញាណអាក្រក់ គ្រប់ទាំងជម្ងឺរោគាត្រូវតែចុះចូលចំពោះព្រះនាមព្រះយេស៊ូវ ។ គឺមានអំណាចនៅក្នុងព្រះនាមព្រះយេស៊ូវ ។

### ក. ការរំដោះតាមរយៈព្រះនាម

ព្រះគម្ពីរកិច្ចការ ១៦:១៨

រឿងរ៉ាវទាំងឡាយដែលនាងបាននិយាយបញ្ចេញសម្លេងទៅ គឺលោកសាវ័កប៉ុលបានស្គាល់លក្ខណៈថាមានវិញ្ញាណនៅពីក្រោយខ្នងពាក្យសម្ដីរបស់នាង និងវិញ្ញាណដែលនិយាយចេញទៅនោះ ។

### ខ. កិត្តិយសដ៏ខ្ពស់សម្រាប់ព្រះនាមទ្រង់

ព្រះគម្ពីរកិច្ចការ ១៩:១៧-១៨

នៅពេលដែលយើងស្ដាប់ព្រះ ធើយស្ដាប់បង្គាប់ដល់ព្រះសូរសៀងរបស់ព្រះអង្គនោះ យើងត្រូវត្រូវតែឈានចេញទៅយ៉ាងអង់អាច ហើយដោយនូវសេចក្ដីជំនឿ ក្នុងការប្រើសិទ្ធិអំណាចដ៏កំណាច នៅក្នុងព្រះនាមព្រះយេស៊ូវវិញ ។ នៅពេលដែលយើងធ្វើ យើងនឹងមានបទពិសោធន៍នូវទីសម្គាល់ និងការអស្ចារ្យនៅក្នុងជីវិតប្រចាំថ្ងៃរបស់យើង និងការបំពេញការងាររបស់យើងនោះឯង ។

ព្រះគម្ពីរកិច្ចការ ៤:២៩-៣១

នៅពេលដែលយើងបន្តប្រើសិទ្ធិអំណាច និងអំណាចចេស្ដានៃព្រះនាមព្រះយេស៊ូវ នោះយើងត្រូវបានអង្រួនដល់លោកិយរបស់យើងដោយនូវព្រះវត្តមាន និងអំណាចចេស្ដានៃព្រះដ៏មានមហិទ្ធិឫទ្ធិនោះ ។ សិទ្ធិអំណាចខាងឯវិញ្ញាណដែលបានប្រទានមកឱ្យពួកអ្នកជឿនៅលើផែនដីនេះ និងគ្រប់យ៉ាងនៅក្នុងវា ។ ទោះជាយ៉ាងណាក៏ដោយ ក៏យើងនៅតែមិនទាន់បានប្រើសិទ្ធិអំណាចនោះ ក្នុងការគ្រប់គ្រងដល់មនុស្សទេ នោះគឺជាតាក់ទិចរបស់អារក្សសាតាំងហើយ ។ កូនសោរសម្រាប់ជ័យជម្នះក្នុងជីវិតគ្រីស្ទាន គឺបានរកឃើញនៅក្នុងអំណាចនៃព្រះនាមព្រះយេស៊ូវ ។ យើងអាចដើរជាមួយនឹងអំណាចដដែលនេះ គឺដែលបានពណ៌នានៅក្នុងព្រះគម្ពីរកិច្ចការ គឺនៅពេលដែលយើងចូលរួមជាមួយនឹងពួកជំនុំគឺពួកអ្នកជឿជំនាន់មុន ក្នុងការប្រើសិទ្ធិអំណាចនៃព្រះនាមព្រះយេស៊ូវនោះឯង ។

## II. គ្រឿងបរិក្ខាសព្វចប់សមរភូមិ!

### ក. អំណាចចេស្ដានៃទេវភាព

ឥឡូវនេះដែលយើងយល់ដឹង នូវការពើបប្រយុទ្ធដ៏អស់កល្ប ហើយនិងការដឹងស្គាល់នូវសិទ្ធិអំណាចរបស់យើង ព្រមទាំងគ្រឿងសឹកដែលមានពេញដោយអំណាចចេស្ដា នោះហើយដែលយើងត្រូវមានគ្រឿងបរិក្ខាសម្រាប់អំណាចចេស្ដាដើម្បីយកជ័យជម្នះ ឈ្នះនៅក្នុងសង្គ្រាម ។

ព្រះគម្ពីរ ២កូរិនថូស ១០:៤

មានមនុស្សជាច្រើនបានព្យាយាម ចូលមកក្នុងទីចម្បាំងដោយគ្មានការបើកសម្ដែងយ៉ាងដូច្នេះ ។ ពួកគេមិនបានយល់ដឹងនូវសិទ្ធិអំណាចដែលពួកគេមាន គឺពីព្រោះតែពួកគេបាននៅក្នុងព្រះយេស៊ូវនោះឯង ។

ចំពោះពួកគេ សង្គ្រាមខាងឯវិញ្ញាណគឺបានត្រឡប់មកជាការតស៊ូយ៉ាងខ្លាំងក្លា យ៉ាងមាំមួន ជាមួយនឹងខ្មាំងសត្រូវដ៏មានអំណាចនោះ ។ ពួកគេបានត្រឡប់មកជាបានធ្វើការកាន់កាប់ជាមួយនឹងអារក្ស និងពពួកវិញ្ញាណអាក្រក់របស់វា ។ ដោយមានការប្រុងប្រយ័ត្នរបស់ពួកគេច្រើនប៉ុណ្ណា ក៏ត្រូវបានដាក់ឱ្យនៅជាកណ្ដាលអារក្ស និងវិញ្ញាណអាក្រក់របស់វាច្រើនប៉ុណ្ណោះដែរ ដូចជាកាន់តែធំឡើង កាន់មាំឡើង និងកាន់តែមានពេញដោយអំណាចផងដែរ គឺពួកគេហាក់ដូចមានការយ៉ាងដូច្នោះ ។ បញ្ហាគឺតែងតែកើតដល់ពួកគ្រីស្ទានស្ទើរតែទាំងអស់ ដែលមិនបានដឹងស្គាល់នូវសិទ្ធិអំណាចនោះ ។

ការស្គាល់សិទ្ធិអំណាចរបស់យើង គឺដើរពីមុខសង្គ្រាមដ៏មានជ័យជម្នះ ។

## ខ. ការធ្វើឱ្យខ្មាំងសត្រូវបរាជ័យ

ហោរាអេសាយបានសរសេរចែងទុកមក សម្រាប់អនាគតរបស់សាតាំង ។ គាត់បានផ្ដល់ឱ្យយើងនូវរូបភាពដ៏ច្បាស់លាស់នៃគ្រោះកម្មរបស់វា ។

ព្រះគម្ពីរអេសាយ ១៤:១៥-១៧

មនុស្សនឹងសម្លឹងមើលទៅឯអាមួយនេះ ដែលត្រូវបានហៅថាសាតាំង គឺដែលវាបានទទួលនូវការបរាជ័យយ៉ាងគ្មានទីសង្ឃឹម និងត្រូវបានបន្ទាបចុះ ។ ពួកគេនឹងសម្លឹងមើលទៅដោយមានការភ្ញាក់ផ្អើលទៅឯអាមួយនោះ ដែលពួកគេបានគិតថា វាបានជាធំ និងអស្ចារ្យយ៉ាងដូច្នោះ ។ ពួកគេនឹងសួរថា "តើមនុស្សនេះជាអ្វីទៅ ...?" "តើមនុស្សនេះជាអ្នកណាដែលគ្រប់គ្នាបានបង្កើតនូវភាពទំនាក់ទំនងកាន់តែធំ និងខ្ពស់ឡើងដោយរបៀបនេះ?" ពួកគេនឹងសម្លឹងមើលទៅឯមនុស្សម្នាក់នេះដែលបានត្រូវនាំមក ឱ្យគ្មានអ្វីសោះដូច្នេះ ។ ពួកគេនឹងសម្លឹងមើលទៅវាដោយការមើលងាយ ។ ពួកគេនឹងមើលឃើញវា ដែលបានទទួលនូវភាពបរាជ័យទាំងស្រុង ។

នៅពេលដែលយើងមានការបើកសម្ដែងទៅដល់ អ្នកដែលនៅក្នុងព្រះយេស៊ូវ នោះយើងនឹងមិនត្រូវនៅក្រោមការកាន់កាប់របស់អារក្សតទៅទៀតឡើយ ។ យើងត្រូវបន្តការកាន់កាប់ជាមួយនឹងព្រះយេស៊ូវហើយ!

អារក្សត្រូវបរាជ័យនៅពីក្រោមជើងយើងហើយ ។ រីឯអំណាចរបស់វាត្រូវបានបំផ្លាញហើយ ។ ព្រះយេស៊ូវទ្រង់បានធ្វើឱ្យវាបានទៅជា "ចំណុចសូន្យ" ហើយ ។ វាបានត្រូវទទួលការខ្វះខាតខាងផ្នែកប្រដាប់អាវុធ គ្មានលទ្ធភាព និងត្រូវបានដាក់ចូលទៅក្នុងភាពអាម៉ាសហើយដែរ ។

## គ. ត្រូវនាំចូលមកដល់ការគ្មានអ្វីសោះ

ព្រះគម្ពីរហេព្រើរ ២:១៤ខ

យើងមិនត្រូវស្ថិតនៅក្នុងការចាញ់ប្រៀបគេ ក្នុងការទាក់ទងជាមួយអារក្ស និងពួកវិញ្ញាណអាក្រក់របស់វាទៀតទេ ។ យើងបានត្រូវប្រទានឱ្យនូវអំណាចចេស្ដា លើគ្រប់ទាំងអំណាចរបស់ខ្មាំងសត្រូវហើយ ។

នៅពេលដែលយើងចូលទៅក្នុងការធ្វើសង្គ្រាម នោះវាត្រូវតែបានចេញមកពីតួនាទី ដែលបញ្ជាក់ពីការធានារ៉ាប់រង និងសេចក្ដីជំនឿថា យើងនឹងបានទទួលនូវជ័យជម្នះហើយ ។ យើងត្រូវតែចូលទៅក្នុងសង្គ្រាមពីតួនាទី នៃចំណេះដឹងរបស់អ្នកដែលនៅក្នុងព្រះយេស៊ូវ ។ យើងមិនត្រូវដាក់ផែនការទៅលើការតស៊ូយ៉ាងខ្លាំងក្លា ជាមួយនឹងខ្មាំងសត្រូវដែលមានពេញដោយអំណាចនោះទេ ។ ជំនួសឱ្យនូវការនេះ យើងត្រូវ

តែសម្លឹងមើលទៅលើសេចក្ដីអំណរ ជ័យជម្នះ គឺនៅពេលដែលយើងសម្ដែងពីសេចក្ដីពិត ដែកអារក្សបានត្រូវទទួលនូវការបរាជ័យ រួចទៅហើយនោះ ។

**១. អារក្សអត់មាន"ទំនាក់ទំនងធំៗ" តទៅទៀតឡើយ ។**

**២. ព្រះយេស៊ូវទ្រង់មាន "ទំនាក់ទំនងដ៏ធំ" វិញ ។**

**៣. យើងអាចធ្វើគ្រប់យ៉ាងបានតាមរយៈទ្រង់!**

## III. ជំហានឆ្ពោះទៅរកជ័យជម្នះ

អំណាចចេស្ដា និងសិទ្ធិអំណាចរបស់អ្នកជឿ គឺមិនមែនជា "តុក្កតា" ក្នុងការទទួលស្គាល់នូវការសម្រេចចិត្តផ្នែកអាត្មានិយមផ្ទាល់របស់យើងនោះទេ ។ យើងត្រូវតែមានការស៊ីសង្វាក់ពេញលេញ ជាមួយនឹងបំណងព្រះហឫទ័យរបស់ព្រះ ។

### ក. ការសារភាពបាប

ប្រសិនបើយើងទទួលបាននូវជ័យជម្នះ ក្នុងសង្គ្រាមខាងឯវិញ្ញាណរបស់យើង នោះយើងត្រូវតែប្រែចិត្តនិងសារភាពនូវអំពើបាបរបស់យើងទៅចំពោះព្រះ ហើយទទួលយកនូវការអត់ទោសរបស់ព្រះអង្គ ។ ត្រូវបញ្ជាក់ថាមិនព្រមបើកទ្វារឱ្យអារក្សចូលមកប្រយុទ្ធជាមួយនឹងយើង តាមរូបភាពណាទៀត ដូចជាពួកកូនប្រុសរបស់លោកស្កេវ៉ា ដែលបានរត់ចេញទាំងអាក្រាត និងមានរបួសនោះឡើយ ។

ព្រះគម្ពីរកិច្ចការ ១៩:១៦

លោកសាវ័កយ៉ូហានបានប្រាប់យើង ពីរបៀបធ្វើយ៉ាងដូច្នេះ ។ ព្រះគម្ពីរ ១យ៉ូហាន ១:៩ ។

### ខ. ការប្ដេជ្ញា

យើងត្រូវតែបេជ្ញាក្នុងជីវិតរបស់យើងថា ១០០% ថ្វាយទៅព្រះយេស៊ូវជាព្រះអម្ចាស់នៃជីវិតរបស់យើង ។ ព្រះគម្ពីររ៉ូម ១២:១-២

### គ. ការញែកខ្លួនចេញពីលោកិយ

យើងត្រូវតែញែកខ្លួនយើងចេញពីការចូលរួម ជាមួយនឹងក្នុងករណីយកិច្ចរបស់លោកិយ ។

ព្រះគម្ពីរ ២ធីម៉ូថេ ២:៤

### ឃ. ការដាក់ដៃទៅម្ខាងក្នុងការសម្រេចចិត្តរបស់យើង

យើងត្រូវតែដាក់ដៃរបស់យើងទៅម្ខាង ក្នុងការសម្រេចចិត្ត ហើយបើកឱ្យព្រះវិញ្ញាណរបស់ព្រះធ្វើការវិញ ។ យើងត្រូវតែនិយាយដូចជាព្រះយេស៊ូវថា "ខ្ញុំធ្វើការអ្វីដែលខ្ញុំបានឃើញព្រះវរបិតាធ្វើប៉ុណ្ណោះ" ។

ព្រះគម្ពីរយ៉ូហាន ៥:១៩

### ង. ព្រះទ្រង់បានប្រទានគ្រប់បែបយ៉ាងដល់អ្នកជឿ គឺនៅក្នុងតំបន់ដ៏ពិតប្រាកដនៃសិទ្ធិអំណាចពីលើ:

១. ជីវិតរបស់យើង

២. អាពាហ៍ពិពាហ៍ កូនរចៅ គ្រួសាររបស់យើង ។ យើងគឺជាអ្នករស់នៅដោយវិញ្ញាណ ។

៣. ទីណាដែលយើងរស់នៅ ជាអ្នកជិតខាង អ្នកនៅទីក្រុង និងជាជាតិសាសន៍របស់យើងនោះឯង ។

៤. ទីណាដែលយើងត្រូវព្រះទ្រង់បានបញ្ជូនទៅ ឱ្យបានបំពេញការងារ ។

ជានិច្ចកាល យើងនឹងមិនបញ្ចេញវិញ្ញាណរបស់យើងទៅក្នុងទីសង្គ្រាម ឱ្យបានឈ្នះលើទីមាំមួនរបស់អារក្ស គឺនៅក្នុងតំបន់ផ្នែកខាងក្រៅសិទ្ធិអំណាច

ដែលព្រះ ទ្រង់បានប្រទានឱ្យមកយើងហើយនោះ ។ ព្រះទ្រង់សព្វព្រះហឫទ័យដល់ពួកអ្នកជឿ ឱ្យស្ថិតនៅក្នុងការសិក្សារៀនសូត្រ ពីសិទ្ធិអំណាចរបស់ពួកគេ ហើយធ្វើការរុញច្រានទីមាំមួនទាំងនោះចុះទៅ ។ ជានិច្ចកាល យើងនឹងមិនត្រូវបានបញ្ចេញនូវវិញ្ញាណរបស់យើង ឱ្យចូលទៅក្នុងទីសង្គ្រាម ដែលឈ្នះលើទីមាំមួនរបស់អារក្ស ដែលនៅក្នុងតំបន់ខាងក្រៅសិទ្ធិអំណាចរបស់យើង ដែលព្រះទ្រង់បានប្រទានឱ្យមកយើងនោះទេ ។ ព្រះទ្រង់សព្វព្រះហឫទ័យដល់ពួកអ្នកជឿ ឱ្យមានសិទ្ធិអំណាច ដែលអាចរុញច្រានទីមាំមួនទាំងឡាយនោះចុះ ។ យើងត្រូវការចាប់យកអំណាចគ្រប់គ្រង ពីលើគ្រប់របស់ទាំងនោះ ដែលព្រះទ្រង់បានដឹកនាំយើងឱ្យធ្វើ ។

## ច. គ្មានអ្នកឯកទេសក៏ខាងឯវិញ្ញាណទេ

នៅក្នុងនគររបស់ព្រះ វាមិនមែនជាផែនការរបស់ទ្រង់ដែលត្រូវធ្វើសង្គ្រាម និងធ្វើការរំដោះខាងឯវិញ្ញាណ ឱ្យបាននូវការទទួលស្គាល់ ដោយការត្រាស់ហៅចូល ឬក៏ចេញទៅតាមអ្នកឯកទេសក៏ ឬក៏ជា "វិញ្ញាណកាន់លុយដ៏មានអំណាចខ្ពស់" នោះទេ ។ ជំនួសឱ្យនូវការនេះ នៅពេលដែលលោកសាវ័កយ៉ាកុបបានសរសេរ ទៅកាន់អ្នកជឿគ្រប់រូបថា ត្រូវតែទប់ទល់ជាមួយនឹងអារក្ស នោះវានឹងរត់ចេញពីយើងទៅ ។

ព្រះគម្ពីរយ៉ាកុប ៤:៧

## ច. ត្រូវមានអាកប្បកិរិយានៃសេចក្ដីស្រឡាញ់

យើងជាទាហាន: មនុស្សប្រុសស្រីនៃក្ដីជំនឿលើទាហានរបស់ព្រះ នោះយើងមិនត្រូវបានត្រឡប់មកជាអ្នកអួតអាង និងធ្វើឱ្យមានការមិនពិរោះស្ដាប់ នៅក្នុងទម្លាប់របស់យើងទៅចំពោះអ្នកដទៃនោះឡើយ ។

ព្រះគម្ពីរភីលេម៉ូន ១:៤-៥

យើងត្រូវតែបានរឹងមាំចំពោះអារក្ស និងពួកវិញ្ញាណរបស់វា ប៉ុន្តែ យើងត្រូវតែបន្តដើរដោយនូវសេចក្ដីស្រឡាញ់ចំពោះមនុស្សដទៃទៀត ។ យើងស្អប់ដល់អារក្ស ប៉ុន្តែ យើងស្រឡាញ់ដល់មនុស្ស ។

## ឆ. គ្មានការសម្រុះសម្រួល

ពេលដែលយើងដើរដោយមានភាពទំនាក់ទំនង ជិតស្និទ្ធជាមួយនឹងព្រះ ដោយគ្មានលាយឡំនឹងការសម្រុះសម្រួលនូវអំពើបាប ឬភាពជាលោកិយ ដែលនៅក្នុងជីវិតរបស់យើងនោះឡើយ គឺព្រះទ្រង់នឹងទូន្មានដល់យើងពីយុទ្ធសាស្ត្ររបស់សាតាំង សម្រាប់ធ្វើឱ្យយើងបរាជ័យ ដោយការអនុវត្តន៍នូវអំណោយទានខាងឯវិញ្ញាណ នៃការសង្កេតខាងឯវិញ្ញាណនោះឯង ។ យើងគឺជាអ្នកជិតដឹតនឹងព្រះ ដែលយើងមានការដឹងខ្លួនច្រើនប៉ុណ្ណា នោះក៏មានវត្តមានរបស់អារក្ស ការឆបោក ការចុះសម្រុង ឬក៏ជាការលាយបញ្ចូលគ្នា នៅពេលដែលវាចូលមកច្រើនប៉ុណ្ណោះដែរ ។

យើងត្រូវតែរក្សាភ្នែកយើង ឱ្យនៅជាប់នឹងព្រះយេស៊ូវ ។ ប្រសិនបើសាតាំង ឬពួកវិញ្ញាណអាក្រក់របស់វាចូលមកក្នុងផ្លូវមកទាក់ទងជាមួយ នោះត្រូវរារាំងពួកវា បណ្ដេញពួកវាឱ្យ ចេញពីចិត្តគំនិត និងពីការស្រមើស្រមៃ ដែលមិនជាព្រះនោះចេញ ។ បន្ទាប់មក យើងត្រូវតែរក្សាភ្នែកយើងមើលទៅឯព្រះយេស៊ូវនៅពេលដែលយើងសរសើរព្រះអង្គសម្រាប់ជ័យជម្នះនោះ ។ ព្រះគម្ពីរ ២កូរិនថូស ២:១៤ ។

## IV. គ្រឿងសឹករបស់ព្រះ

ព្រះទ្រង់បានប្រទានពរឱ្យយើង នូវគ្រឿងសឹកសម្រាប់សមរភូមិដែលយើងនៅនោះ ។ លោកសាវ័កប៉ុលមិនបានសរសេរថា យើងត្រូវតែពាក់គ្រឿងសឹករបស់យើងនោះទេ គឺគាត់បានសរសេរថា យើងត្រូវតែពាក់គ្រឿងសឹករបស់ព្រះវិញ។ នៅយុគ្គសម័យកណ្តាលនៃអប្បប្ញទ្ធិ គឺពេលដែលពួកគេពាក់គ្រឿងសឹករបស់ពួកគេ និងមួកសឹករបស់ពួកគេ ព្រមទាំងទម្លាក់ក្បាំងមុខគ្របលើមុខរបស់ពួកគេ នោះពួកគេមើលទៅដូចជាមានអំណាច មានសាច់ដុំ គួរឱ្យគ្រោះថ្នាក់ ជាអ្នកចម្បាំងចំពោះខ្មាំងសត្រូវ ។ ការគ្មានការប្រុងប្រយ័ត្ន នៅក្នុងពេលដ៏ខ្លីនោះឯង ដែលរូបកាយផ្នែកខាងក្នុងគឺមានគ្រឿងសឹកនោះ ពួកគេហាក់ដូចជាកងកម្លាំងដែលមានឫទ្ធិអំណាច ។

នៅពេលដែលយើងបានពាក់គ្រឿងសឹករបស់ព្រះ នោះយើងមើលទៅហាក់ដូចជាព្រះ លើអារក្សសាតាំងនោះ ។ បន្ទាប់មក គ្រប់ទាំងអស់យើងត្រូវតែធ្វើដោយជ័យជម្នះនៅសមរភូមិ គឺជាការនិយាយដូចជាព្រះ ដើរដូចជាព្រះ និងធ្វើការប្រព្រឹត្តដូចជាព្រះអញ្ចឹង!

### ក. អំណាចចេស្តារបស់យើង

យើងត្រូវតែអនុវត្ត ដោយនូវឫទ្ធិអំណាចរបស់ព្រះ ។ យើងត្រូវតែដើរចូលទៅក្នុងសមរភូមិ ដោយនូវកម្លាំងផ្ទាល់ខ្លួនរបស់យើងបាន ។

ព្រះគម្ពីរអេភេសូរ ៦:១០-១១

### ខ. ការតស៊ូរបស់យើង - អេភេសូរ ៦:១២

លោកសាវ័កប៉ុលបានរំឭកយើងថា ការតស៊ូរបស់យើង គឺមិនមែនជាមួយនឹងសាច់ឈាមទេ គឺនឹងពួកអ្នកគ្រប់គ្រង ពួកមានអំណាច និងពួកម្ចាស់នៃសេចក្តីងងឹតវិញ ។ ការតស៊ូរបស់យើង គឺមិនមែននៅក្នុងតំបន់ខាងធម្មជាតិលោកិយនេះទេ គឺនៅក្នុងតំបន់ខាងវិញ្ញាណវិញ ។

### គ. គ្រឿងសឹករបស់យើង

**១. ក្រវាត់សេចក្តីពិត**

**២. ពាក់ប្រដាប់ការពារទ្រូងនៃសេចក្តីសុចរិត**

**៣. ទាំងពាក់សេចក្តីប្រុងប្រៀបរបស់ដំណឹងល្អ**

ព្រះគម្ពីរអេភេសូរ ៦:១៣-១៥

លោកសាវ័កប៉ុល ក៏បានពោលពាក្យដដែលៗថា "ចូរឈរ" ចំនួនបីដង ។ ទីមួយគាត់បាននិយាយថា នៅពេលដែលថ្ងៃ អាក្រក់បានចូលមកដល់ នោះយើងនឹងអាចឈរយ៉ាងមាំមួនបាន ។ បន្ទាប់មកគាត់ក៏បាននិយាយទៀតថា បន្ទាប់ពីយើងបានធ្វើការគ្រប់យ៉ាងហើយ យើងនឹងអាចឈរយ៉ាងមាំមួនបាន។ ចំពោះពាក្យសម្តីចុងក្រោយ គាត់បាននិយាយថា ចូរឈរឱ្យបានមាំមួន ហើយពាក់ប្រដាប់ការពារទ្រូងនៃសេចក្តីសុចរិត ទាំងពាក់សេចក្តីប្រុងប្រៀបរបស់ដំណឹងល្អនៃសេចក្តីសុខសាន្ត ។ យើងមិនត្រូវស្ថិតនៅក្នុងការចាញ់ប្រៀបគេឡើយ ។

សេចក្តីពិតគឺជាព្រះបន្ទូលព្រះ ។ គឺព្រះបញ្ចូលព្រះនេះ ហើយដែលការពារយើងបាន យើងត្រូវតែស្គាល់នូវអ្វីដែលព្រះបន្ទូលទ្រង់បានចារទុកមក ។ សេចក្តីពិតបានដោះយើង ឱ្យមានសេរីភាព ។

ការពាក់ប្រដាប់ការពារទ្រូង នៃសេចក្តីសុចរិតរបស់យើង គឺជាសេចក្តីសុចរិតរបស់ព្រះ ។ យើងមិន

ត្រូវបានតម្រូវឱ្យបានគ្រប់លក្ខណ៍នោះទេ ប៉ុន្តែ យើងបានតម្រូវមិនឱ្យបានស្គាល់នូវអំពើបាប ក្នុងជីវិតរបស់យើងសម្រាប់ប្រដាប់ការពារទ្រូង បានតាំងនៅនោះវិញ ។

ជើងរបស់យើង គឺត្រូវតែមានការប្រុងប្រៀបនូវដំណឹងល្អនៃសេចក្ដីសុខសាន្តវិញ ។ ការប្រុងប្រៀបរៀបចំ គឺជាចំណែករបស់យើង ហើយចំណែកនោះឯង គឺដោយការសិក្សាព្រះ បន្ទូលរបស់ព្រះ ។

លោកសាវ័កប៉ុល បានសរសេរទៅកាន់លោកធីម៉ូថេ (២ធីម៉ូថេ ២:១៥) ។

**៤. ខែលនៃសេចក្ដីជំនឿ**

**៥. មួកសឹកនៃសេចក្ដីសង្គ្រោះ**

**៦. ដាវនៃព្រះវិញ្ញាណ**

ព្រះគម្ពីរអេភេសូរ ៦:១៦-១៧

យើងត្រូវតែប្រើខែលនៃសេចក្ដីជំនឿ ដើម្បីរំលត់អស់ទាំងព្រួញឆេះរបស់មេកំណាចនោះចេញ ។ ព្រួញឆេះគឺជាចិត្ត គំនិត ជាសេចក្ដីល្បួង ជាជម្ងឺរោគា និងជាយុទ្ធសាស្ត្រដទៃ ទៀតដែលសាតាំងធ្វើតាមរយៈយើង ។ យើងត្រូវតែពន្លត់ពួកវា តាមរយៈសេចក្ដីជំនឿលើព្រះ ហើយសេចក្ដីជំនឿនោះ ឯងត្រូវនៅក្នុងព្រះបន្ទូលទ្រង់ ។

ព្រះគម្ពីរអេសាយ ៥៩:១៧

មួកសឹកនៃសេចក្ដីសង្គ្រោះ គឺត្រូវពាក់នៅលើខ្លួនរបស់យើង ពេលដែលយើងបានទទួលនូវសេចក្ដីសង្គ្រោះនោះ ។ នេះគឺជាសេចក្ដីសង្គ្រោះ ដែលមិនមែនគ្រាន់តែជាអ្នកតាំងភូមិលំនៅ ជាវាសនាដ៏អស់កល្បរបស់យើងនោះទេ គឺវាការមួយដែលបានកែយើងជាថ្មីឡើងវិញ ដើម្បីឱ្យគ្រប់ទាំងអស់ដែលយើងត្រូវបានបង្កើតមក ឱ្យមានរូបភាពរបស់ទ្រង់នោះឯង ។ មួកសឹកនៃសេចក្ដីសង្គ្រោះ គឺបានបើកឱ្យយើង ដើម្បីរំឭកពីគំនិតរបស់យើង ឱ្យបានពេញដោយការបើកសម្ដែង ពីសេចក្ដីសង្គ្រោះរបស់យើងនោះឯង ។

ព្រះគម្ពីររ៉ូម ១២:២ក

ការរំឭកពីគំនិតឡើងវិញនេះ គឺបានមកតាមរយៈការលាងសម្អាតចិត្តគំនិតរបស់យើង ដោយ "ទឹក" រស់នៃព្រះបន្ទូលរបស់ព្រះ គឺនៅពេលដែលយើងអាន សិក្សា និងជញ្ជឹងគិតពិចារណា រហូតដល់គំនិតរបស់យើង បានត្រឡប់មកជាគំនិតរបស់ផងទ្រង់វិញ ។

ព្រះគម្ពីរអេភេសូរ ៥:២៦

យើងត្រូវបានប្រទានមក នូវគ្រឿងសឹកដែលនាំឱ្យរវាទចិត្ត ហើយក៏ជាដាវរបស់វិញ្ញាណ គឺជាព្រះបន្ទូលរបស់ព្រះ ។ លោកសាវ័កប៉ុលប្រាប់យើងបន្ថែមទៀត អំពីដាវរបស់ព្រះវិញ្ញាណ ដែលមាននៅក្នុងព្រះគម្ពីរហេព្រើរ ។

ព្រះគម្ពីរហេព្រើរ ៤:១២

ព្រះបន្ទូលរបស់ព្រះ គឺជាខ្សែក្រវាត់នៃសេចក្ដីពិត គឺជាការគ្របបាំងដល់ជើងរបស់យើង និងជាដាវរបស់យើងនោះឯង! តើអាចមានការសង្ស័យណាមួយចំពោះការសិក្សានូវព្រះ បន្ទូលថាជាការសំខាន់នោះ?

### ឃ. សេចក្តីអធិស្ឋានដែលមានជ័យជម្នះ

ម្យ៉ាងទៀត យើងមានសេចក្តីជំនឿហើយ ចូរពាក់គ្រឿងសឹករបស់ព្រះឱ្យបានគ្រប់គ្រាន់ គឺយើងត្រូវអធិស្ឋានដោយនូវវិញ្ញាណទៅលើឱកាសទាំងអស់នោះ ។

ព្រះគម្ពីរអេភេសូរ ៦:១៨

ពេលដែលយើងនៅតែអធិស្ឋាន ដោយនូវសេចក្តីជំនឿ សម្រាប់ពួកបរិសុទ្ធទាំងអស់ ក្នុងការប្រើនូវសិទ្ធិអំណាច ដែលបានកែជាថ្មីឡើងវិញរបស់យើង នោះយើងនឹងមើលឃើញទីមាំមួនទាំងឡាយរបស់សាតាំងត្រូវធ្លាក់ចុះ ។ យើងនឹងបានត្រឡប់មកជាអ្នកក្លាហាននៅក្នុងសមរភូមិ ហើយយើងនឹងកំចាត់កំចាយ នូវកងកម្លាំងរបស់សាតាំងនោះ ។

ព្រះគម្ពីរហេព្រើរ ១១:៣៣-៣៤

ព្រះគម្ពីរ ២កូរិនថូស ១០:៤

ព្រះគម្ពីររ៉ូម ៨:៣៧

***គ្រឿងសឹកធ្វើចម្បាំងរបស់យើង គឺជាប្ញទ្ធិអំណាច ។***

***ចូរដើរដោយមានជ័យជម្នះ***

***ក្នុងព្រះនាមដ៏មានអំណាច គឺជាព្រះយេស៊ូវ ។***

## ក្រុមពិភាក្សា

១. នៅក្នុងការពិភាក្សាពីគ្រឿងសឹករបស់ព្រះ លោកសាវ័កប៉ុលបានពោលពាក្យដដែលៗថា "ចូរឈរ" ចំនួនបីដង ។ ហេតុអ្វីបានជា "ការឈរ" គឺជាការសំខាន់បំផុតនៅក្នុងការធ្វើសឹកសង្គ្រាម?

២. វាមិនមែនជាការសំខាន់ក្នុងការបើកទ្វារ ដែលអាចបើកឱ្យសាតាំងចូលមកបានក្នុងជីវិតយើងនោះទេ ។ តើយើងដឹងដោយរបៀបណា ប្រសិនបើយើងបានបើកទ្វារណាមួយនោះ?

៣. ហេតុអ្វីបានជាយើងត្រូវបានប្រទានមក ត្រឹមតែជាគ្រឿងសឹកដែលមានការរវាទចិត្ត នៅក្នុងគ្រឿងសឹករបស់ព្រះនោះ?

## ការសិក្សាដោយខ្លួនឯង

១. នៅក្នុងជីវិតរបស់លោកអ្នក តើលោកអ្នករកឃើញដោយខ្លួនឯងបន្ថែមទៀត នូវការកាន់កាប់ជាមួយនឹងព្រះយេស៊ូវ ឬក៏ក្នុងការកាន់កាប់នៅមុនជាមួយនឹងអារក្ស? ប្រសិនបើក្រោយមកបានក្លាយទៅជាការពិត តើអ្វីទៅដែលលោកអ្នកអាចធ្វើជាលក្ខណៈបុគ្គល ដើម្បីឱ្យបានទទួលការកាន់កាប់បន្ថែមទៀតជាមួយនឹងព្រះយេស៊ូវ?

២. តើលោកអ្នកអាចប្រុងប្រៀបរៀបចំ នូវជើងរបស់ខ្លួនជាមួយនឹងដំណឹងនៃសេចក្តីសុខសាន្ត?

៣. ចូរអធិស្ឋានថា ក្នុងចិត្តរបស់យើងគឺត្រូវតែបានរំឭកសារជាថ្មីឡើងវិញ នូវការបើកសម្តែងដ៏ពេញលេញនៃសេចក្តីសង្គ្រោះរបស់លោកអ្នក ។ ចូរចងចាំផងដែរ

ពីរបៀបដ៏សំខាន់ ដែលវាត្រូវបានពាក់គ្រឿងសឹករបស់ព្រះ នៅក្នុងជីវិតប្រចាំថ្ងៃរបស់លោកអ្នកនោះ ។